

ធនាគារជាតិ នៃ កម្ពុជា
ប្រាក់រៀល. ស្ថិរភាព. អភិវឌ្ឍន៍.

# របាយការណ៍ស្តីពីស្ថានភាពស្ថិរភាពហិរញ្ញវត្ថុប្រចាំឆ្នាំ ២០២០

ស្ថានភាពនិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច
ស្ថានភាពនិងការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុ
ទំនាក់ទំនងម៉ាក្រូហិរញ្ញវត្ថុ និងហានិភ័យ
ប្រឈមចំពោះស្ថិរភាពហិរញ្ញវត្ថុ

# មាតិកា


**អារម្ភកថា**........................................ ១
**ខ្លឹមសារសង្ខេប**........................................ ៣
**១. ស្ថានភាពនិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច** ........................................ ៦
**១.១ ស្ថានភាពនិងស្ថិរភាពវិស័យខាងក្រៅ**........................................ ៦
ក- ស្ថានភាពវិស័យខាងក្រៅ ........................................ ៦
ខ- ស្ថិតិជញ្ជីងទូទាត់ ........................................ ៧
គ- ពាណិជ្ជកម្ម ........................................ ៨
ឃ- គណនីសេវា........................................ ៩
ង- ប្រាក់បង្វែររបស់ពលករក្រៅប្រទេស ........................................ ១០
ច- គណនីហិរញ្ញវត្ថុ........................................ ១១
ឆ- អត្រាប្តូរប្រាក់ និងស្ថិរភាពវិស័យខាងក្រៅ........................................ ១៣
**១.២ ស្ថានភាព និងស្ថិរភាពសេដ្ឋកិច្ចកម្ពុជា** ........................................ ១៥
ក- កំណើនសេដ្ឋកិច្ច ........................................ ១៥
ខ- វិស័យសំណង់និងអចលនទ្រព្យ ........................................ ១៦
គ- វិស័យរូបិយវត្ថុ ........................................ ១៨
ឃ- ស្ថានភាពអតិផរណា........................................ ១៩
ង- វិស័យសារពើពន្ធ ........................................ ២០
**២. ស្ថានភាពនិងការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុ** ........................................ ២៥
**២.១ ទិដ្ឋភាពទូទៅ ស្ថានភាព និងការវាយតម្លៃប្រព័ន្ធធនាគារ** ........................................ ២៥
ក- ទិដ្ឋភាពទូទៅនៃប្រព័ន្ធធនាគារ ........................................ ២៥
ខ- ការវិភាគឥណទានតាមវិស័យ........................................ ២៦
គ- កំណើនឥណទានតាមវិស័យរបស់វិស័យធនាគារ........................................ ២៨
ឃ- វិស័យមីក្រូហិរញ្ញវត្ថុ........................................ ៣១
ង- គុណភាពឥណទាន ........................................ ៣៣
ច- គុណភាពឥណទានតាមវិស័យ ........................................ ៣៣
ឆ- ស្ថានភាពសន្ទនីយភាព និងប្រភពមូលនិធិ ........................................ ៣៧
ជ- លទ្ធភាពស្វែងរកប្រាក់ចំណេញ ........................................ ៤១
ឈ- ស្ថានភាពដើមទុន ........................................ ៤៣
**២.២ ការអភិវឌ្ឍនៅក្នុងវិស័យមូលបត្រនិងធានារ៉ាប់រង**........................................ ៤៤
ក- ផ្សារភាគហ៊ុន........................................ ៤៤
ខ- ផ្សារមូលបត្របំណុល........................................ ៤៥
គ- វិស័យធានារ៉ាប់រង ........................................ ៤៦
**៣. ទំនាក់ទំនងម៉ាក្រូហិរញ្ញវត្ថុ**........................................ ៤៨
**៣.១ គម្លាតឥណទានធៀបនឹង ផ.ស.ស** ........................................ ៤៨
**៣.២ ការវិភាគតារាងតុល្យការ** ........................................ ៤៩
**៤. ទស្សនវិស័យ និងហានិភ័យ**........................................ ៥១
**ឧបសម្ព័ន្ធ**........................................ ៥៥

# បញ្ជីនៃក្រាហ្វ

ក្រាហ្វ ១៖ ការព្យាករសេដ្ឋកិច្ចពិភពលោក ........ ៧
ក្រាហ្វ ២៖ ជញ្ជីងទូទាត់របស់ប្រទេសកម្ពុជា ........ ៨
ក្រាហ្វ ៣៖ ការនាំចេញ ការនាំចូល និងសមតុល្យពាណិជ្ជកម្មទំនិញ ........ ៩
ក្រាហ្វ ៤៖ ចំនួនភ្ញៀវទេសចរអន្តរជាតិ (កំណើនភ្ញៀវទេសចរអន្តរជាតិ និងគោលដៅនៃការធ្វើដំណើរ) ........ ១០
ក្រាហ្វ ៥៖ ចំនួនភ្ញៀវទេសចរអន្តរជាតិមកប្រទេសកម្ពុជា ........ ១០
ក្រាហ្វ ៦៖ ប្រាក់បង្វែររបស់ពលករតាមប្រទេស ........ ១១
ក្រាហ្វ ៧៖ សមាមាត្រនៃប្រាក់បង្វែររបស់ពលករតាមប្រទេស ........ ១១
ក្រាហ្វ ៨៖ លំហូរវិនិយោគផ្ទាល់បរទេសតាមវិស័យ ........ ១២
ក្រាហ្វ ៩៖ លំហូរវិនិយោគផ្ទាល់បរទេសចំពោះវិស័យហិរញ្ញវត្ថុ ........ ១២
ក្រាហ្វ ១០៖ លំហូរវិនិយោគផ្ទាល់បរទេសតាមប្រទេស ........ ១២
ក្រាហ្វ ១១៖ សមាសធាតុនៃបំណុលក្រៅប្រទេសដុល ........ ១៣
ក្រាហ្វ ១២៖ សម្ពាធទីផ្សារប្តូរប្រាក់ (EMP) ........ ១៣
ក្រាហ្វ ១៣៖ អត្រាប្តូរប្រាក់ទ្វេភាគី និងអត្រាប្តូរប្រាក់ប្រសិទ្ធភាព ........ ១៣
ក្រាហ្វ ១៤៖ ទុនបម្រុងអន្តរជាតិ ........ ១៤
ក្រាហ្វ ១៥៖ សូចនាករភាពគ្រប់គ្រាន់នៃទុនបម្រុងអន្តរជាតិ ........ ១៤
ក្រាហ្វ ១៦៖ ការរួមចំណែកក្នុងកំណើនសេដ្ឋកិច្ចតាមវិស័យចម្បងៗ ........ ១៦
ក្រាហ្វ ១៧៖ ចំនួនគម្រោងសំណង់តាមវិស័យ ........ ១៧
ក្រាហ្វ ១៨៖ តម្លៃគម្រោងសំណង់ ........ ១៧
ក្រាហ្វ ១៩៖ សមាមាត្រនៃផ្ទៃក្រឡាគម្រោងសំណង់តាមវិស័យ ........ ១៨
ក្រាហ្វ ២០៖ កំណើននៃការនាំចូលសម្ភារនិងបរិក្ខារសំណង់ ........ ១៨
ក្រាហ្វ ២១៖ ប្រាក់បញ្ញើនិងកម្ចីជារូបិយប័ណ្ណ ........ ១៨
ក្រាហ្វ ២២៖ ការរួមចំណែកក្នុងអតិផរណា ........ ២០
ក្រាហ្វ ២៣៖ គណនីសារពើពន្ធ ........ ២០
ក្រាហ្វ ២៤៖ ស្ថានភាពសារពើពន្ធនៃប្រទេសអាស៊ាន ........ ២០
ក្រាហ្វ ២៥៖ ការរួមចំណែកក្នុងកំណើនប្រាក់ចំណូល ........ ២១
ក្រាហ្វ ២៦៖ ការរួមចំណែកក្នុងកំណើនប្រាក់ចំណាយ ........ ២២
ក្រាហ្វ ២៧៖ សមាមាត្របំណុលសាធារណៈក្រៅប្រទេស បែងចែកតាមប្រទេសចម្បងៗ ........ ២២
ក្រាហ្វ ២៨៖ ប្រព័ន្ធធនាគារកម្ពុជានៅឆ្នាំ២០២០ ........ ២៥

ក្រាហ្វ ២៩៖ សមាមាត្រទ្រព្យសកម្ម ........................................................... ២៦
ក្រាហ្វ ៣០៖ សមាមាត្រឥណទាន ........................................................... ២៦
ក្រាហ្វ ៣១៖ ឥណទានធនាគារតាមវិស័យសេដ្ឋកិច្ច ........................................................... ២៧
ក្រាហ្វ ៣២៖ ឥណទានមីក្រូហិរញ្ញវត្ថុតាមវិស័យសេដ្ឋកិច្ច ........................................................... ២៧
ក្រាហ្វ ៣៣៖ កំណើនឥណទានក្នុងប្រព័ន្ធធនាគារ ........................................................... ២៧
ក្រាហ្វ ៣៤៖ ការរួមចំណែកនៃឥណទានតាមវិស័យទៅកាន់កំណើនឥណទានធនាគារសរុប .. ២៨
ក្រាហ្វ ៣៥៖ ចំណែកឥណទានធនាគារតាមវិស័យ ........................................................... ២៩
ក្រាហ្វ ៣៦៖ កំណើនឥណទានក្នុងវិស័យចម្បងៗ ........................................................... ២៩
ក្រាហ្វ ៣៧៖ ចំណែកឥណទានធនាគារទាក់ទងវិស័យអចលនទ្រព្យ ........................................................... ៣០
ក្រាហ្វ ៣៨៖ កំណើនឥណទានក្នុងវិស័យទាក់ទងនឹងអចលនទ្រព្យ ........................................................... ៣០
ក្រាហ្វ ៣៩៖ ចំណែកនៃកំណើនឥណទានក្រុមគ្រួសារ ........................................................... ៣១
ក្រាហ្វ ៤០៖ ចំណែកនៃកំណើនឥណទានសាជីវកម្ម ........................................................... ៣១
ក្រាហ្វ ៤១៖ ការរួមចំណែកកំណើនឥណទានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើតាមវិស័យ .. ៣២
ក្រាហ្វ ៤២៖ ការរួមចំណែកកំណើនឥណទានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ តាមវិស័យ ........................................................... ៣២
ក្រាហ្វ ៤៣៖ ឥណទានមិនដំណើរការ ........................................................... ៣៣
ក្រាហ្វ ៤៤៖ អនុបាតឥណទានមិនដំណើរការតាមវិស័យធុរកិច្ចចម្បងៗរបស់គ្រឹះស្ថានធនាគារ ... ៣៤
ក្រាហ្វ ៤៥៖ អនុបាតឥណទានមិនដំណើរការក្នុងវិស័យអចលនទ្រព្យនិងការប្រើប្រាស់ផ្ទាល់ខ្លួន ... ៣៤
ក្រាហ្វ ៤៦៖ ចំនួនគណនីឥណទានរៀបចំឡើងវិញ ........................................................... ៣៥
ក្រាហ្វ ៤៧ ៖ ចំនួនឥណទានរៀបចំឡើងវិញ ........................................................... ៣៥
ក្រាហ្វ ៤៨៖ គណនីឥណទានរៀបចំឡើងវិញក្នុងប្រព័ន្ធធនាគារ តាមវិស័យអាទិភាព ............ ៣៦
ក្រាហ្វ ៤៩៖ គណនីឥណទានរៀបចំឡើងវិញរបស់គ្រឹះស្ថានធនាគារ តាមវិស័យអាទិភាព...... ៣៦
ក្រាហ្វ ៥០៖ គណនីឥណទានរៀបចំឡើងវិញរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ តាមវិស័យអាទិភាព ........................................................... ៣៧
ក្រាហ្វ ៥១៖ គណនីឥណទានរៀបចំឡើងវិញរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ តាមវិស័យអាទិភាព ........................................................... ៣៧
ក្រាហ្វ ៥២៖ អនុបាតក្របខ័ណ្ឌសន្ទនីយភាព ........................................................... ៣៨
ក្រាហ្វ ៥៣៖ ស្ថានភាពសន្ទនីយភាព ........................................................... ៣៨
ក្រាហ្វ ៥៤៖ ប្រភពមូលនិធិក្នុងវិស័យធនាគារ ........................................................... ៣៨
ក្រាហ្វ ៥៥៖ មូលនិធិកម្ចីក្នុងវិស័យធនាគារ ........................................................... ៣៨

ក្រាហ្វ ៥៦៖ ប្រភពមូលនិធិក្នុងវិស័យមីក្រូហិរញ្ញវត្ថុ....................................................................................................៣៩
ក្រាហ្វ ៥៧៖ មូលនិធិកម្ចីក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ....................................................................................................៣៩
ក្រាហ្វ ៥៨៖ ប្រទេសចម្បងទាំង១០ ដែលជាប្រភពហិរញ្ញប្បទានរបស់វិស័យមីក្រូហិរញ្ញវត្ថុ..... ៤០
ក្រាហ្វ ៥៩៖ សមាមាត្រប្រភពមូលនិធិកម្ចី.................................................................................................... ៤០
ក្រាហ្វ ៦០៖ អនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម.................................................................................................... ៤១
ក្រាហ្វ ៦១៖ អនុបាតប្រាក់ចំណេញធៀបនឹងដើមទុន .................................................................................................... ៤១
ក្រាហ្វ ៦២៖ អនុបាតប្រសិទ្ធភាពនៃការគ្រប់គ្រងចំណាយ .................................................................................................... ៤១
ក្រាហ្វ ៦៣៖ ធាតុនៃប្រាក់ចំណេញរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ................. ៤២
ក្រាហ្វ ៦៤៖ ធាតុនៃប្រាក់ចំណេញរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ............ ៤២
ក្រាហ្វ ៦៥៖ អនុបាតសាធនភាព ....................................................................................................៤៣
ក្រាហ្វ ៦៦ ៖ សន្ទស្សន៍ ផ.ម.ក.................................................................................................... ៤៤
ក្រាហ្វ ៦៧ ៖ ទំហំមូលធននីយកម្មទីផ្សារ.................................................................................................... ៤៥
ក្រាហ្វ ៦៨ ៖ ទំហំនិងតម្លៃជួញដូរជាមធ្យម .................................................................................................... ៤៥
ក្រាហ្វ ៦៩ ៖ បុព្វលាភដុល....................................................................................................៤៧
ក្រាហ្វ ៧០ ៖ សំណងធានារ៉ាប់រងដុល....................................................................................................៤៧
ក្រាហ្វ ៧១ ៖ សមាមាត្រនៃបុព្វលាភធានារ៉ាប់រងទូទៅ....................................................................................................៤៧
ក្រាហ្វ ៧២ ៖ សមាមាត្រនៃបុព្វលាភធានារ៉ាប់រងអាយុជីវិត....................................................................................................៤៧
ក្រាហ្វ ៧៣ ៖ អនុបាតឥណទានធៀបនឹង ផ.ស.ស និងគម្លាតឥណទាន................................ ៤៨
ក្រាហ្វ ៧៤ ៖ ស្ថានភាពហិរញ្ញវត្ថុរួមតាមវិស័យឆ្នាំ២០២០ .................................................................................................... ៤៩
ក្រាហ្វ ៧៥ ៖ ស្ថានភាពហិរញ្ញវត្ថុអន្តរវិស័យ.................................................................................................... ៥០

# អក្សរកាត់

| | | |
|---|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី | Asian Development Bank |
| AFD | ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ | Agence Francaise de Development |
| ATM | ម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ | Automated Teller Machine |
| BCBS | គណៈកម្មាធិការបាសែលស្តីពីការត្រួតពិនិត្យធនាគារ | Basel Committee on Banking Supervision |
| BIS | ធនាគារសម្រាប់ការទូទាត់អន្តរជាតិ | Bank for International Settlements |
| BOP | ស្ថិតិជញ្ជីងទូទាត់ | Balance of Payments |
| Brexit | ការចាកចេញរបស់អង់គ្លេសពីសហភាពអឺរ៉ុប | Withdrawal of the United Kingdom from the European Union |
| CAR | អនុបាតសាធនភាព | Capital Adequacy Ratio |
| CBC | ក្រុមហ៊ុនក្រេឌីត ប្យូរ៉ូ (ខេមបូឌា) | Credit Bureau Cambodia |
| CCyB | ទ្រនាប់ដើមទុនខោនធើស៊ីឃ្លីខល | Countercyclical Capital Buffer |
| CCB | ទ្រនាប់ដើមទុនខនស៊ើវេសិន | Capital Conservation Buffer |
| CSX | ផ្សារមូលបត្រកម្ពុជា | Cambodia Securities Exchange |
| EBA | ប្រព័ន្ធអនុគ្រោះពន្ធអ្វីៗគ្រប់យ៉ាងលើកលែងអាវុធ | Everything But Arms |
| ECB | ធនាគារកណ្តាលអឺរ៉ុប | European Central Bank |
| EMP | សម្ពាធទីផ្សារប្តូរប្រាក់ | Exchange Market Pressure |
| EU | សហភាពអឺរ៉ុប | European Union |
| FCD | ប្រាក់បញ្ញើជារូបិយប័ណ្ណ | Foreign Currency Deposits |
| FDI | វិនិយោគផ្ទាល់បរទេស | Foreign Direct Investment |
| FI | គ្រឹះស្ថានហិរញ្ញវត្ថុ | Financial Institution |
| FOB | ទំនិញដែលត្រូវបានទទួលខុសត្រូវក្នុងពេលដឹកជញ្ជូនដោយអ្នកលក់ឬអ្នកទិញ | Free-on-Board |
| FSI | សូចនាករភាពរឹងមាំហិរញ្ញវត្ថុ | Financial Soundness Indicators |
| GDP | ផលិតផលក្នុងស្រុកសរុប | Gross Domestic Product |
| GFSR | របាយការណ៍ស្ថិរភាពហិរញ្ញវត្ថុសកល | Global Financial Stability Report |
| GTF | សម្លៀកបំពាក់,វាយនភ័ណ្ឌ និងស្បែកជើង | Garments, Textiles, and Footwear |
| GTI | ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល | Grand Twins International |
| IFAD | មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍន៍វិស័យកសិកម្ម | International Fund for Agricultural Development |

| | | |
|---|---|---|
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ | International Monetary Fund |
| KHR | រូបិយវត្ថុជាតិ | Khmer Riel |
| LCR | អនុបាតក្របខ័ណ្ឌសន្ទនីយភាព | Liquidity Coverage Ratio |
| LTV | ឥណទានធៀបនឹងទ្រព្យបញ្ចាំ | Loan-to-Value |
| MDI | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | Microfinance Deposit-taking Institutions |
| MEF | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | Ministry of Economy and Finance |
| MFI | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ | Microfinance Institution |
| MLMUPC | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | Ministry of Land Management, Urban Planning and Construction |
| NBC | ធនាគារជាតិនៃកម្ពុជា | National Bank of Cambodia |
| NIS | វិទ្យាស្ថានជាតិស្ថិតិ | National Institute of Statistics |
| NPL | ឥណទានមិនដំណើរការ | Non-Performing Loan |
| OECD | អង្គការដើម្បីអភិវឌ្ឍនិងសហប្រតិបត្តិការសេដ្ឋកិច្ច | Organization for Economic Co-Operation and Development |
| OPEC | អង្គការនៃប្រទេសនាំចេញប្រេង | Organization of the Petroleum Exporting Countries |
| PAS | កំពង់ផែស្វយ័តក្រុងព្រះសីហនុ | Sihanoukville Autonomous Port |
| PPAP | កំពង់ផែស្វយ័តភ្នំពេញ | Phnom Penh Autonomous Port |
| PPSEZ | តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ | Phnom Penh Special Economic Zone |
| PPWSA | រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ | Phnom Penh Water Supply Authority |
| RE | អចលនទ្រព្យ | Real Estate |
| RGC | រាជរដ្ឋាភិបាលកម្ពុជា | Royal Government of Cambodia |
| ROA | អនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម | Return on Assets |
| ROE | អនុបាតប្រាក់ចំណេញធៀបនឹងដើមទុន | Return on Equity |
| SQM | ម៉ែត្រការ៉េ | Square Meter |
| TA | ជំនួយបច្ចេកទេស | Technical Assistance |
| U.K. | ចក្រភពអង់គ្លេស | United Kingdom |
| USD | ដុល្លារអាមេរិក | US Dollar |
| WB | ធនាគារពិភពលោក | World Bank |
| Y-O-Y | ឆ្នាំលើឆ្នាំ | Year-on-Year |

# អារម្ភកថា

ឆ្នាំ២០២០ គឺជាឆ្នាំដែលមានបញ្ហាប្រឈមច្រើនជាងគេ ធៀបនឹងបណ្តាឆ្នាំមុនៗ ដោយសារការរីករាលដាលជំងឺកូវីដ-១៩ បានជះឥទ្ធិពលដល់សេដ្ឋកិច្ចនិងទីផ្សារហិរញ្ញវត្ថុពិភពលោក។ កម្ពុជាបានទទួលរងផលប៉ះពាល់ដូចនឹងបណ្តាប្រទេសដទៃទៀតដែរ ដោយវិស័យសំខាន់ៗ រួមមានវិស័យទេសចរណ៍ កាត់ដេរសម្លៀកបំពាក់និងវាយនភ័ណ្ឌ និងសំណង់បានរងការប៉ះទង្គិចខ្លាំងជាងគេ។ សេដ្ឋកិច្ចកម្ពុជាមានកំណើនអវិជ្ជមានក្នុងឆ្នាំ២០២០ បន្ទាប់ពីសម្រេចបានកំណើនខ្ពស់ ជាមធ្យមក្នុងរង្វង់ ៨% ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ។ ទោះបីជាមានផលប៉ះពាល់ពីការរីករាលដាលជំងឺកូវីដ-១៩ក៏ដោយ វិស័យធនាគារនៅកម្ពុជាបន្តរក្សាបានស្ថិរភាពនិងមានភាពធន់ ដោយសារការអភិវឌ្ឍប្រកបដោយចីរភាពនៃវិស័យធនាគារ។ ទ្រព្យសកម្មសរុបនៅក្នុងប្រព័ន្ធធនាគារបានកើនដល់ ២១៧% នៃផ.ស.ស. ជាមួយនឹងកំណើនប្រចាំឆ្នាំ ១៥,៧%។ លើសពីនេះ ឥណទានអតិថិជនបានកើនដល់ ១៤០% នៃផ.ស.ស. ជាមួយនឹងកំណើនប្រចាំឆ្នាំ ១៦,៩% ហើយប្រាក់បញ្ញើអតិថិជនមានកំណើនជាមធ្យម ១៥,៤% និងកើនដល់ ១២៣% នៃផ.ស.ស.។ ទោះយ៉ាងណា ទស្សនវិស័យនាពេលអនាគតនៅតែមានភាពមិនប្រាកដប្រជា។ ទោះបីជាមានសញ្ញាពីការងើបឡើងវិញនៃសេដ្ឋកិច្ច និងយុទ្ធនាការចាក់វ៉ាក់សាំងជាសកលក៏ដោយ ភាពមិនប្រាកដប្រជាជាច្រើនជុំវិញការវិវត្តនៃការរីករាលដាលជំងឺកូវីដ-១៩ ការងើបឡើងវិញមិនស្មើគ្នានៃសេដ្ឋកិច្ចប្រទេសនីមួយៗ និងផលប៉ះពាល់រយៈពេលវែងក្នុងវិស័យមួយចំនួនអាចនឹងដាក់កំហិតលើសក្តានុពលនៃកំណើនសេដ្ឋកិច្ចនាពេលអនាគត។

ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការរីករាលដាលជំងឺកូវីដ-១៩ មកលើសេដ្ឋកិច្ចនិងសង្គម ធនាគារជាតិនៃកម្ពុជាបានដាក់ចេញវិធានការជាច្រើន តាមរយៈវិធានការគាំទ្រនានា និងការអនុគ្រោះផ្នែកបទប្បញ្ញត្តិក្នុងប្រព័ន្ធធនាគារ ដើម្បីផ្តល់លទ្ធភាពដល់ប្រព័ន្ធធនាគារក្នុងការបន្តរក្សានិរន្តរភាពប្រតិបត្តិការរបស់ខ្លួន ក្នុងការបម្រើដល់តម្រូវការសេដ្ឋកិច្ច។ វិធានការដំបូងនិងសំខាន់បំផុត គឺធនាគារជាតិនៃកម្ពុជាបានបន្ធូរបន្ថយនយោបាយរូបិយវត្ថុ ដើម្បីផ្តល់សន្ទនីយភាពដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ លើសពីនេះ ចាប់តាំងពីខែមេសាឆ្នាំ២០២០មក គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យរៀបចំឥណទានឡើងវិញ ក្នុងគោលបំណងជួយសម្រាលបន្ទុករបស់ក្រុមគ្រួសារ និងអាជីវកម្ម។ វិធានការទាំងនេះបានជួយរក្សាគុណភាពឥណទាននិងពង្រឹងការគ្រប់គ្រងហានិភ័យសន្ទនីយភាពក្នុងប្រព័ន្ធធនាគារ ដែលបានធ្វើឱ្យអនុបាតឥណទានមិនដំណើរការមានកម្រិតទាប ហើយប្រាក់ចំណេញមានកម្រិតសមរម្យ។ ជាមួយនឹងភាពមិនប្រាកដប្រជានៃការងើបឡើងវិញនៃសេដ្ឋកិច្ច ជាពិសេសបន្ទាប់ពីព្រឹត្តិការណ៍ ២០-កុម្ភៈ ធនាគារជាតិនៃកម្ពុជានឹងបន្តរក្សាការប្រុងប្រយ័ត្ន ហើយត្រៀមខ្លួនរួចជាស្រេចដើម្បីដាក់ចេញវិធានការគាំទ្របន្ថែមទៀត ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ទន្ទឹមនឹងការរក្សាឱ្យបាននូវស្ថិរភាពហិរញ្ញវត្ថុ។ នៅពេលវិបត្តិជំងឺកូវីដ-១៩ ត្រូវបានបញ្ចប់ ការដកចេញគោលនយោបាយគាំទ្រនានានឹងត្រូវធ្វើឡើងដោយសន្សឹមៗ និងមានការផ្សព្វផ្សាយទូលំទូលាយ សំដៅសម្រេចឱ្យបាននូវតុល្យភាពរវាងកំណើនសេដ្ឋកិច្ច និងស្ថិរភាព។

របាយការណ៍ស្ថិរភាពហិរញ្ញវត្ថុឆ្នាំ២០២០ បង្ហាញពីការវិវត្តថ្មីៗនៃវិស័យហិរញ្ញវត្ថុ និងបញ្ហាប្រឈមនានា។ របាយការណ៍នេះ ពិភាក្សាផងដែរអំពីទស្សនវិស័យនិងហានិភ័យនាពេលអនាគតដែលវិស័យហិរញ្ញវត្ថុអាចនឹងជួបប្រទះក្នុងអំឡុងពេលដែលសេដ្ឋកិច្ចក្នុងស្រុក តំបន់ និងពិភពលោកកំពុងប្រឈមនឹងស្ថានភាពមិនប្រាកដប្រជា ដោយសារការរីករាលដាលជំងឺកូវីដ-១៩។ ខ្ញុំជឿជាក់ថា

របាយការណ៍នេះនឹងរួមចំណែកពង្រឹងការយល់ដឹងបន្ថែមដល់បុគ្គលបម្រើការនៅក្នុងវិស័យហិរញ្ញវត្ថុ, បញ្ញវន្ត, ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធនឹងស្ថិរភាពហិរញ្ញវត្ថុដទៃទៀតនៅកម្ពុជា។

ជាទីបញ្ចប់ ខ្ញុំសូមសម្តែងការកោតសរសើរដល់គណៈកម្មាធិការស្ថិរភាពហិរញ្ញវត្ថុនៃធនាគារជាតិនៃកម្ពុជាដែលបានខិតខំបំពេញការងាររបស់ខ្លួនបានយ៉ាងខ្ជាប់ខ្ជួន។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់ក្រសួង-ស្ថាប័នសាធារណៈ និងដៃគូអភិវឌ្ឍន៍ ចំពោះកិច្ចសហប្រតិបត្តិការនិងការគាំទ្រនានា។ ជាមួយស្ថានភាពបច្ចុប្បន្ន យន្តការសហការរវាងនិយ័តករក្នុងវិស័យហិរញ្ញវត្ថុ និងភាគីពាក់ព័ន្ធមានភាពចាំបាច់ណាស់ក្នុងការសម្រួលដល់ការតាមដានហានិភ័យនានាក្នុងប្រព័ន្ធហិរញ្ញវត្ថុ និងចាត់វិធានការ ឱ្យបានទាន់ពេលវេលាដើម្បីបង្ការហានិភ័យជាប្រព័ន្ធ។ ខ្ញុំជឿជាក់យ៉ាងមុតមាំទៅលើការបន្តកិច្ចសហប្រតិបត្តិការនិងការគាំទ្រនានា ដើម្បីពង្រឹងការឃ្លាំមើលស្ថិរភាពហិរញ្ញវត្ថុកម្ពុជាឱ្យកាន់តែប្រសើរឡើង។

ថ្ងៃសុក្រ ២រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១

ទេសាភិបាល

ជា ចាន់តូ

## ខ្លឹមសារសង្ខេប

**វិស័យធនាគារនិងហិរញ្ញវត្ថុបន្តមានភាពធន់ បើទោះបីជាសេដ្ឋកិច្ចសកលនៅក្នុងឆ្នាំ២០២០ មានកំណើនទាបជាងកាលពីអំឡុងពេលនៃវិបត្តិហិរញ្ញវត្ថុសកលឆ្នាំ២០០៨-២០០៩ ក៏ដោយ។** វិបត្តិជំងឺកូវីដ-១៩ ដែលបង្កើតឱ្យមានវិបត្តិតម្រូវការនិងការផ្គត់ផ្គង់ បានបង្កការប៉ះទង្គិចដល់សេដ្ឋកិច្ចសកលនៅក្នុងឆ្នាំ២០២០ ដែលបានធ្វើឱ្យសេដ្ឋកិច្ចសកលមានកំណើនអវិជ្ជមាន -៣,៣%។ ទោះយ៉ាងណា វិស័យនេះបន្តមានភាពធន់ក្នុងការទប់ទល់នឹងវិបត្តិ ដោយសារលក្ខខណ្ឌអំណោយផលនៃហិរញ្ញវត្ថុសកល ហើយដើមទុននិងសន្ទនីយភាពក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុមានកម្រិតខ្ពស់ជាងកាលពីវិបត្តិហិរញ្ញវត្ថុសកល ។

**ដោយសេដ្ឋកិច្ចកម្ពុជាមានលក្ខណៈបើកចំហនិងពឹងផ្អែកខ្លាំងលើវិស័យខាងក្រៅ កម្ពុជាមានកំណើនអវិជ្ជមាន -៣,១% នៅឆ្នាំ២០២០ ដែលជាកំណើនអវិជ្ជមានលើកដំបូងគិតចាប់តាំងពីឆ្នាំ១៩៩៤ មក។** វិស័យដែលរងផលប៉ះពាល់ខ្លាំងជាងគេរួមមាន ទេសចរណ៍ និងការនាំចេញសម្លៀកបំពាក់ និងស្បែកជើង។ វិស័យទេសចរណ៍បានរងផលប៉ះពាល់ខ្លាំង ដោយភ្ញៀវទេសចរអន្តរជាតិបានធ្លាក់ចុះរហូតដល់ -៨០,២% ខណៈដែលភ្ញៀវទេសចរក្នុងស្រុកបានថយចុះបន្តិចផងដែរ។ ទន្ទឹមនេះ បើទោះបីជាការនាំចេញសម្លៀកបំពាក់និងស្បែកជើងបានថយចុះ -៩,៧% និង -១១,៦% រៀងគ្នាក៏ដោយ ប៉ុន្តែការនាំចេញគ្រឿងបង្គុំអគ្គិសនី កង់ អង្ករ និងកៅស៊ូមានការកើនឡើងគួរឱ្យកត់សម្គាល់ ដែលបានឆ្លុះបញ្ចាំងពីការធ្វើពិពិធកម្មសេដ្ឋកិច្ចនាពេលកន្លងមក។ ការវិនិយោគផ្ទាល់បរទេសសរុបបានថយចុះបន្តិច -១% ប៉ុន្តែការវិនិយោគផ្ទាល់បរទេសទៅក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ មានកំណើនវិជ្ជមាន ១២,៨% ដោយសារតែការវិនិយោគឡើងវិញនូវប្រាក់ចំណូលដែលទទួលបាន ការបង្កើនដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងការបង្កើតគ្រឹះស្ថានធនាគារថ្មី។ ប្រាក់បង្វែររបស់ពលករពីក្រៅប្រទេសបានធ្លាក់ចុះយ៉ាងខ្លាំង -១៧% ដោយសារតែការថមថយសកម្មភាពសេដ្ឋកិច្ច និងការបិទខ្ទប់នៅក្នុងប្រទេសមួយចំនួនដែលពលករកំពុងធ្វើការ។ វិស័យសំណង់និងអចលនទ្រព្យក៏មានការថយចុះដែរ ប៉ុន្តែវិស័យកសិកម្មនៅតែមានកំណើនវិជ្ជមានដោយសារកំណើនកម្លាំងពលកម្មចេញពីវិស័យ ដែលទទួលរងផលប៉ះពាល់ពីវិបត្តិសុខភាព ទោះបីជាការប្រែប្រួលអាកាសធាតុបានប៉ះពាល់ដល់វិស័យនេះក៏ដោយ។

**ក្នុងអំឡុងវិបត្តិជំងឺកូវីដ-១៩ កម្មវិធីឧបត្ថម្ភសាច់ប្រាក់និងការបន្ធូរបន្ថយពន្ធរបស់រាជរដ្ឋាភិបាល បានកាត់បន្ថយផលប៉ះពាល់មកលើអាជីវកម្មនិងកម្មករនិយោជិត ខណៈដែលស្ថានភាពសារពើពន្ធ និងកម្រិតបំណុលបន្តស្ថិតក្នុងស្ថានភាពល្អ។** រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវកញ្ចប់ថវិកាដើម្បីគាំទ្រដល់ប្រជាពលរដ្ឋនិងសហគ្រាសដែលទទួលរងផលប៉ះពាល់ខ្លាំង។ ទោះយ៉ាងណា ការកើនឡើងនូវចំណាយរបស់រាជរដ្ឋាភិបាល គួបផ្សំនឹងការធ្លាក់ចុះនៃការប្រមូលចំណូលបានធ្វើឱ្យឱនភាពសារពើពន្ធកើនឡើង ប៉ុន្តែស្ថានភាពសារពើពន្ធនៅតែស្ថិតក្នុងភាពល្អប្រសើរនៅឡើយ ដែលឆ្លុះបញ្ចាំងតាមរយៈកម្រិតខ្ពស់នៃប្រាក់សន្សំរបស់រាជរដ្ឋាភិបាល។ ជាមួយគ្នានេះ បំណុលរាជរដ្ឋាភិបាលនៅតែមាននិរន្តរភាពក្នុងកម្រិត ៣២,៨% ធៀបនឹង ផ.ស.ស ដែលទាបជាងកម្រិតគោល ៤០%។

**នៅឆ្នាំ២០២០ អតិផរណាមានកម្រិតទាប ២,៩% ខណៈដែលប្រាក់រៀលបានធ្លាក់ថ្លៃបន្តិចធៀបនឹងប្រាក់ដុល្លារអាមេរិក។** កំណើនថ្លៃម្ហូបអាហារ ជាពិសេសក្នុងអំឡុងពេលនៃការផ្ទុះឡើងដំបូងនៃជំងឺ

កូវីដ-១៩ បានរួមចំណែកធ្វើឱ្យអត្រាអតិផរណាកើនឡើង ប៉ុន្តែមួយផ្នែកនៃការកើនឡើងនេះត្រូវបានផាត់ទាត់ដោយការធ្លាក់ចុះនៃថ្លៃក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ។ ជាលទ្ធផល អត្រាអតិផរណាបានកើនឡើងពី ១,៩% ក្នុងឆ្នាំ២០១៩ ដល់ ២,៩% នៅឆ្នាំ២០២០ ប៉ុន្តែនៅតែជាអត្រាមួយទាបនិងអាចគ្រប់គ្រងបាន។ ទន្ទឹមនេះ អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកបានកើនឡើងបន្តិចដោយសារការថយចុះនៃសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក ដែលបានធ្វើឱ្យតម្រូវការប្រាក់រៀលថយចុះរួមជាមួយនឹងការថយចុះនៃលំហូរចូលរូបិយប័ណ្ណបរទេស។ ដោយឡែក ទុនបម្រុងអន្តរជាតិបានកើនឡើងដល់ ២១,៣ ប៊ីលានដុល្លារអាមេរិក ស្មើនឹងជាង១០ខែនៃការនាំចូលទំនិញនិងសេវាសម្រាប់គ្រាបន្ទាប់។ កម្រិតខ្ពស់នៃទុនបម្រុងអន្តរជាតិ បានជួយពង្រឹងស្ថិរភាពអត្រាប្តូរប្រាក់និងទំនុកចិត្តសាធារណជនមកលើប្រាក់រៀលនិងសេដ្ឋកិច្ចកម្ពុជា។

**ប្រព័ន្ធធនាគារកម្ពុជាបន្តមានភាពធន់ ជាមួយភាពរឹងមាំនៃដើមទុននិងសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ទោះបីទទួលរងនូវការប៉ះទង្គិចក៏ដោយ។** ស្ថានភាពដើមទុននិងសន្ទនីយភាពរបស់ប្រព័ន្ធធនាគារបន្តមានភាពគ្រប់គ្រាន់ ដោយអនុបាតសាធនភាព និងអនុបាតក្របខ័ណ្ឌសន្ទនីយភាពមានកម្រិតខ្ពស់ជាងកម្រិតបទប្បញ្ញត្តិ។ អនុបាតសាធនភាពរបស់គ្រឹះស្ថានធនាគារ ជាមធ្យមមានកម្រិត ២៣,៧%, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (MDI) ១៩,៨% និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ (MFI) ៣៨,៩% ដែលអនុបាតទាំងនេះ ខ្ពស់ជាងកម្រិតបទប្បញ្ញត្តិ (១៥%)។ អនុបាតក្របខ័ណ្ឌសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារ និង MDI ជាមធ្យមមានកម្រិត ១៦២,៥% និង ២៤០,៤% រៀងគ្នា ខ្ពស់ជាងកម្រិតបទប្បញ្ញត្តិ (១០០%)។ ទន្ទឹមនេះ លទ្ធភាពស្វែងរកប្រាក់ចំណេញរបស់ប្រព័ន្ធធនាគារបន្តមានចីរភាព ទោះបីជាបានថយចុះបន្តិចធៀបនឹងឆ្នាំមុន ដោយអនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម (ROA) បានថយចុះពី ១,៩% នៅឆ្នាំ២០១៩ មកនៅ ១,៧% នៅឆ្នាំ២០២០ ហើយអនុបាតប្រាក់ចំណេញធៀបនឹងដើមទុន (ROE) បានថយចុះពី ៩,៨% មកនៅ ៨,៧%។ រីឯក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ROA របស់ MDI រក្សាបានក្នុងអត្រា ២,៩% តែ ROE បានថយចុះពី ១៧,៧% មកនៅ ១៤,៨% ខណៈដែល ROA និង ROE របស់ MFI ថយចុះពី ២,២% និង ៦,៣% មកនៅ ១,៩% និង ៤,៥% រៀងគ្នា។

**ភាពរឹងមាំនៃប្រព័ន្ធធនាគារ ក៏អាចឆ្លុះបញ្ចាំងតាមរយៈកម្រិតទាបនៃអនុបាតឥណទានមិនដំណើរការ (NPL)។** នៅឆ្នាំ២០២០ កំណើនឥណទានរបស់ប្រព័ន្ធធនាគារមានកម្រិត ១៦,៩% ដែលបានគាំទ្រដល់សកម្មភាពសេដ្ឋកិច្ច បើទោះជាមានការថមថយពី ២៧,៣% នៅឆ្នាំ២០១៩ ក៏ដោយ។ ជាមួយគ្នានេះ គុណភាពឥណទានបន្តមានភាពល្អប្រសើរ ដោយ NPL មានកម្រិតទាបទាំងក្នុងវិស័យធនាគារនិងមីក្រូហិរញ្ញវត្ថុ។ ជាក់ស្តែង NPL របស់ប្រព័ន្ធធនាគារបានកើនឡើងបន្តិចពី ១,៧% នៅឆ្នាំ២០១៩ ដល់ ២,១% នៅឆ្នាំ២០២០ ប៉ុន្តែនៅមានកម្រិតទាបនៅឡើយដែលរួមចំណែកដោយការរៀបចំឥណទានឡើងវិញ នៅក្នុងវិស័យទទួលរងផលប៉ះពាល់ខ្លាំងជាងគេ។

**ការអនុវត្តវិធានការមីក្រូប្រុងប្រយ័ត្នក្នុងរយៈពេលប៉ុន្មានទសវត្សរ៍កន្លងមក គួបផ្សំនឹងការដាក់ចេញវិធានការអន្តរាគមន៍នានាដោយធនាគារជាតិនៃកម្ពុជា បានពង្រឹងភាពធន់នៃប្រព័ន្ធធនាគារ។** ក្នុងអំឡុងពេលពីរទសវត្សរ៍កន្លងមកនេះ វិធានការមីក្រូប្រុងប្រយ័ត្ន ដូចជាការដំឡើងកម្រិតដើមទុនចុះបញ្ជីអប្បបរមា និងអនុបាតក្របខ័ណ្ឌសន្ទនីយភាព ព្រមទាំងការគ្រប់គ្រងហានិភ័យជាប្រព័ន្ធត្រូវបានពង្រឹងជាបន្តបន្ទាប់ បានរួមចំណែកធ្វើឱ្យស្ថានភាពដើមទុនមានភាពរឹងមាំ និងពង្រឹងការ

គ្រប់គ្រងហានិភ័យសន្ទនីយភាព។ ភាពរឹងមាំនៃប្រព័ន្ធធនាគារបានធ្វើឱ្យធនាគារជាតិនៃកម្ពុជាអាចបន្ធូរបន្ថយបទប្បញ្ញត្តិមួយចំនួន ក្នុងអំឡុងពេលនៃវិបត្តិជំងឺកូវីដ-១៩ នេះ ដែលជាលទ្ធផល គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានបន្តផ្តល់ឥណទានដល់សេដ្ឋកិច្ច។ ជាងនេះទៅទៀត ចាប់តាំងពីខែមេសា ឆ្នាំ២០២០មក គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យរៀបចំឥណទានឡើងវិញចំពោះវិស័យអាទិភាព។ ការធ្វើអន្តរាគមន៍ទាន់ពេលវេលារបស់ធនាគារជាតិនៃកម្ពុជាបានរួមចំណែកជួយសម្រាលបន្ទុកប្រជាពលរដ្ឋ ដែលកំពុងជួបប្រទះនូវការធ្លាក់ចុះប្រាក់ចំណូល។

**នៅឆ្នាំ២០២១ យុទ្ធនាការចាក់វ៉ាក់សាំងរបស់រាជរដ្ឋាភិបាលនឹងគាំទ្រដល់ការស្តារសេដ្ឋកិច្ចឡើងវិញ។** ជាមួយការរំពឹងទុកពីការងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោកក្នុងឆ្នាំ២០២១ សេដ្ឋកិច្ចប្រទេសកម្ពុជាត្រូវបានព្យាករថាមានកំណើន ៤% នៅឆ្នាំ២០២១។ ប៉ុន្តែ ការព្យាករនេះ មានភាពមិនប្រាកដប្រជាខ្ពស់ ដោយត្រូវផ្អែកលើការងើបឡើងវិញនៃសេដ្ឋកិច្ចរបស់បណ្តាប្រទេសជាដៃគូពាណិជ្ជកម្ម និងប្រសិទ្ធភាពនៃការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ក្នុងសហគមន៍។ យ៉ាងណាមិញ ការកើនឡើងនៃការចាក់វ៉ាក់សាំងជាសកល និងយុទ្ធនាការចាក់វ៉ាក់សាំងនៅកម្ពុជានាពេលថ្មីៗនេះ នឹងជួយកាត់បន្ថយហានិភ័យទាំងនេះ និងគាំទ្រដល់ការស្តារសេដ្ឋកិច្ចឡើងវិញ។

**នៅក្នុងស្ថានភាពមិនប្រាកដប្រជានេះ ធនាគារជាតិនៃកម្ពុជានឹងបន្តគាំទ្រដល់ផែនការស្តារសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល ខណៈពេលដែលការដកចេញគោលនយោបាយគាំទ្រនានានឹងធ្វើឡើងដោយសន្សឹមៗ និងប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់។** ធនាគារជាតិនៃកម្ពុជានឹងបន្តកិច្ចសហការជាមួយអាជ្ញាធរនិងភាគីពាក់ព័ន្ធ ដើម្បីធានាបាននូវស្ថិរភាពហិរញ្ញវត្ថុ សេដ្ឋកិច្ច និងសង្គម។ ការដកចេញគោលនយោបាយគាំទ្រនានានឹងត្រូវធ្វើឡើងជាសន្សឹមៗដោយភាពប្រុងប្រយ័ត្ន និងស្របតាមការវិវត្តនៃវិបត្តិជំងឺកូវីដ-១៩ និងការងើបឡើងវិញនៃសេដ្ឋកិច្ច។ ធនាគារជាតិនៃកម្ពុជានឹងត្រៀមខ្លួនរួចជាស្រេចដើម្បីដាក់ចេញវិធានការបន្ថែមទៀតប្រកបដោយភាពបុរេសកម្ម ស្របតាមស្ថានការណ៍ជាក់ស្តែង សំដៅធានាឱ្យបាននូវតុល្យភាពរវាងកំណើននិងស្ថិរភាពសេដ្ឋកិច្ច។

# ១. ស្ថានភាពនិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច

## ១.១ ស្ថានភាពនិងស្ថិរភាពវិស័យខាងក្រៅ

### ក- ស្ថានភាពវិស័យខាងក្រៅ

**ការធ្លាក់ចុះនៃកំណើនសេដ្ឋកិច្ចពិភពលោកក្នុងឆ្នាំ២០២០ មានទំហំខ្លាំងជាងវិបត្តិហិរញ្ញវត្ថុសកលក្នុងឆ្នាំ២០០៨ ដោយសារតែការរីករាលដាលជំងឺកូវីដ-១៩ ទោះយ៉ាងណា កំណើនសេដ្ឋកិច្ចក្នុងឆ្នាំ២០២១ រំពឹងថានឹងអាចងើបឡើងវិញ។** មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានកែប្រែការប៉ាន់ស្មានកំណើនសេដ្ឋកិច្ចពិភពលោកមក -៣,៣% ក្នុងឆ្នាំ២០២០ ពីការព្យាករលើកមុន[១]។ ការធ្លាក់ចុះសេដ្ឋកិច្ចក្នុងឆ្នាំ២០២០ មានសភាពធ្ងន់ធ្ងរ ប្រៀបធៀបទៅនឹង -១,៦៧% ក្នុងឆ្នាំ២០០៩ និង ២,៨% ក្នុងឆ្នាំ២០១៩ ខណៈដែលកំណើនសេដ្ឋកិច្ចពិភពលោកសម្រាប់ឆ្នាំ២០២១ អាចនឹងងើបឡើងក្នុងកម្រិតវិជ្ជមាន ៦%។ ការរីករាលដាលជំងឺកូវីដ-១៩ បានប៉ះពាល់ដល់សេដ្ឋកិច្ចពិភពលោកយ៉ាងខ្លាំងនៅដើមឆ្នាំ២០២០ ជាពិសេសក្នុងវិស័យទេសចរណ៍ សង្វាក់ផលិតកម្ម តម្លៃទ្រព្យសកម្ម និងគ្រប់រចនាសម្ព័ន្ធសេដ្ឋកិច្ចទាំងអស់។ លើសពីនេះ ប្រទេសជាច្រើនបានអនុវត្តវិធានការបិទខ្ទប់និងរឹតត្បិតការធ្វើដំណើរ ដែលបានគំរាមគំហែងដល់ប្រាក់ចំណូលគ្រួសារនិងអាជីវកម្ម អត្រាគ្មានការងារធ្វើនិងអត្រាផ្អាកការងារកើនឡើង ការផ្អាកខ្សែសង្វាក់ផលិតកម្មកាន់តែច្រើន និងការចំណាយធ្លាក់ចុះ។ ទន្ទឹមនេះ ភាពតានតឹងពាណិជ្ជកម្ម ការគាំពារនិយម និងការប្រែប្រួលអាកាសធាតុ នៅតែជាបញ្ហាប្រឈម។

**កំណើនសេដ្ឋកិច្ចពិភពលោកជាមធ្យមមានសន្ទុះខ្លាំងជាងការព្យាករកាលពីខែតុលា ឆ្នាំ២០២០ នៅគ្រប់តំបន់ ក្នុងឆមាសទី២ ឆ្នាំ២០២០ ជាពិសេស តំបន់អឺរ៉ុប សហរដ្ឋអាមេរិក ចិន ជប៉ុន ឥណ្ឌា និងកូរ៉េ ខណៈដែល អង់គ្លេស និងអាស៊ានកាន់តែមានភាពធ្ងន់ធ្ងរ។** យោងតាមរបាយការណ៍ការព្យាករសេដ្ឋកិច្ចពិភពលោក ដែលបានធ្វើបច្ចុប្បន្នកម្មក្នុងខែមេសា ឆ្នាំ២០២១ សេដ្ឋកិច្ចរបស់ សហរដ្ឋអាមេរិក ជប៉ុន ឥណ្ឌា និងចិន បានដំណើរការល្អជាងមុន ខណៈតំបន់អឺរ៉ុប និងអាស៊ាន-៥ មានស្ថានភាពកាន់តែដុនដាបធៀបទៅនឹងការព្យាករកាលពីខែតុលា ឆ្នាំ២០២០ (ក្រាហ្វ ១)។ ទោះយ៉ាងណា ល្បឿននៃការងើបឡើងវិញនៅតែមានភាពមិនទាន់ប្រាកដប្រជា និងអាស្រ័យលើការចាក់វ៉ាក់សាំងជាសកល កម្រិតនៃគោលនយោបាយគាំទ្រ ភាពជោគជ័យនៃវិធានការទប់ស្កាត់ និងការកំណត់បានច្បាស់ពីឫសគល់នៃបញ្ហា។ ទន្ទឹមនឹងនេះ អតិផរណាត្រូវបានគេរំពឹងថានឹងមានកម្រិតទាបជាងអត្រាគោលរបស់ធនាគារកណ្តាល ១,៥% សម្រាប់ប្រទេសអភិវឌ្ឍន៍ និងធំជាង ៤% សម្រាប់ប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍ ដែលទាបជាងអត្រាមធ្យមភាគជាប្រវត្តិសាស្ត្រតាមក្រុមប្រទេស។

---

[១] របាយការណ៍ការព្យាករសេដ្ឋកិច្ចពិភពលោករបស់ IMF ចេញផ្សាយខែតុលា ឆ្នាំ២០២០ និងខែមករា ឆ្នាំ២០២១ សេដ្ឋកិច្ចពិភពលោកត្រូវបានព្យាករមាន -៤,៤% និង -៣,៥% រៀងគ្នា។

## ក្រាហ្វ ១ ៖ ការព្យាករសេដ្ឋកិច្ចពិភពលោក




| | ២០១៩ | ២០២០ប | ២០២១ព | ខុសពី ខែមករា ឆ្នាំ ២០២១<br>២០២១ព | ខុសពី ខែតុលា ឆ្នាំ ២០២០<br>២០២១ព |
|---|---|---|---|---|---|
| ពិភពលោក | ២,៨ | -៣,៣ | ៦,០ | ០,៥ | ០,៨ |
| អាមេរិក | ២,២ | -៣,៥ | ៦,៤ | ១,៣ | ៣,៣ |
| ជប៉ុន | ០,៣ | -៤,៨ | ៣,៣ | ០,២ | ១,០ |
| ឥណ្ឌា | ៤,២ | -៨,០ | ១២,៥ | ១,០ | ៣,៧ |
| អឺរ៉ុប | ១,៣ | -៦,៦ | ៤,៤ | ០,២ | -០,៨ |
| ចិន | ៦,០ | ២,៣ | ៨,៤ | ០,៣ | ០,២ |
| អាស៊ាន-៥ | ៤,៩ | -៣,៤ | ៤,៩ | -០,៣ | -១,៣ |

ប្រភព ៖ ការព្យាករសេដ្ឋកិច្ចពិភពលោករបស់ IMF ចេញផ្សាយខែមេសា ឆ្នាំ២០២១

**ស្ថានភាពហិរញ្ញវត្ថុសកលបានបន្ធូរបន្ថយក្នុងការទប់ទល់នឹងភាពតានតឹងសន្ទនីយភាព និងផលប៉ះពាល់ដល់សេដ្ឋកិច្ចសកលដោយសារការរីករាលដាលជំងឺកូវីដ-១៩ ខណៈវិស័យធនាគារនៅតែមានភាពរឹងមាំ។** ធនាគារកណ្តាលភាគច្រើនបានអនុវត្តនយោបាយរូបិយវត្ថុរិត្តារកម្ម ដោយការចាក់បញ្ចូលសាច់ប្រាក់ និងការបន្ទាបអត្រាការប្រាក់គោល ដើម្បីគាំទ្រដល់សកម្មភាពសេដ្ឋកិច្ច។ ធនាគារកណ្តាលអាមេរិកបានទម្លាក់អត្រាការប្រាក់គោលជិតស្មើសូន្យ ខណៈធនាគារកណ្តាលអឺរ៉ុប (ECB) បានប្រកាសពីការបង្កើនកម្មវិធីទិញទ្រព្យសកម្ម។ ទន្ទឹមនេះ ធនាគារកណ្តាលភាគច្រើននៅក្នុងតំបន់ ដូចជា ចិន ឥណ្ឌា ឥណ្ឌូណេស៊ី កូរ៉េ ម៉ាឡេស៊ី ហ្វីលីពីន ថៃ និងវៀតណាម មិនបានរឹតត្បិតនយោបាយរូបិយវត្ថុទេ។ លើសពីនេះ វិស័យធនាគារនៅតែមានភាពធន់ ព្រោះធនាគារមានដើមទុនគ្រប់គ្រាន់ និងមានទ្រនាប់សន្ទនីយភាពខ្ពស់ រួមផ្សំនឹងគោលនយោបាយគាំទ្រជាបន្តបន្ទាប់ដើម្បីរក្សាលំហូរឥណទានដល់ក្រុមគ្រួសារនិងអាជីវកម្ម។ ទោះយ៉ាងណា ធនាគារអាចនឹង ប្រឈមបញ្ហាប្រាក់ចំណេញ ក្នុងបរិការណ៍អត្រាការប្រាក់ទាប និងការកើនឡើងឥណទានមិនដំណើរការ (NPL) បន្ទាប់ពីសកម្មភាពគោលនយោបាយគាំទ្រនានានឹងត្រូវបានបញ្ចប់។

### ខ- ស្ថិតិជញ្ជីងទូទាត់

**ក្នុងឆ្នាំ២០២០ ជញ្ជីងទូទាត់របស់ប្រទេសកម្ពុជាបន្តមានអតិរេកតែក្នុងកម្រិតទាបជាងឆ្នាំ២០១៩។** សមតុល្យរួមជញ្ជីងទូទាត់មានអតិរេក ២,៣% នៃផ.ស.ស ធៀបនឹង ៩,៨% នៃផ.ស.ស ក្នុងឆ្នាំ២០១៩ ជាចម្បងដោយសារតែការថយចុះតិចតួចនៃលំហូរចូលគណនីហិរញ្ញវត្ថុ ស្របពេលដែលឱនភាពគណនីចរន្តនិងដើមទុនបានរួមតូច (ក្រាហ្វ ២)។ ទន្ទឹមនេះ ឱនភាពគណនីចរន្តនិងដើមទុនមានសមាមាត្រ ១០,៣% នៃផ.ស.ស (១៣,៧% នៃផ.ស.ស ក្នុងឆ្នាំ២០១៩) បានថយចុះ ៣,៤% នៃផ.ស.ស។

**ឱនភាពគណនីចរន្តបានថយចុះមកនៅត្រឹម ១១,៣% នៃផ.ស.ស នៅឆ្នាំ២០២០ ពី ១៥% នៃផ.ស.ស ក្នុងឆ្នាំ២០១៩។** ការថយចុះនេះជាចម្បងដោយសារការថយចុះឱនភាពនៃពាណិជ្ជកម្មទំនិញ (១៣,៥% នៃផ.ស.ស) និងគណនីចំណូលបឋម (២% នៃផ.ស.ស)។ លើសពីនេះ សេវាកម្មសុទ្ធមានឱនភាព ០,៤% នៃផ.ស.ស បន្ទាប់ពីមានអតិរេក ១០,៤% នៃផ.ស.ស នៅឆ្នាំមុន ចំណែកឯអតិរេកចំណូលបន្ទាប់បន្សំនិងអតិរេកគណនីដើមទុនមានអត្រាទាបត្រឹម ១,១% នៃផ.ស.ស និង ០,៤% នៃផ.ស.ស រៀងគ្នា។

**ក្រាហ្វ ២ ៖ ជញ្ជីងទូទាត់របស់ប្រទេសកម្ពុជា**

(ជាភាគរយ នៃផ.ស.ស, ឆ្នាំ២០១១ - ឆ្នាំ២០២០)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

## គ- ពាណិជ្ជកម្ម

**ឱនភាពពាណិជ្ជកម្មទំនិញមានភាពប្រសើរក្នុងអំឡុងពេលការរីករាលដាលជំងឺកូវីដ-១៩ ដោយសារការថយចុះនៃការនាំចូលសម្រាប់តម្រូវការក្នុងស្រុក។** នៅឆ្នាំ២០២០ ឱនភាពទំនិញបានថយចុះមកត្រឹម ១៣,២% នៃផ.ស.ស ធៀបនឹង ២៦,៧% នៃផ.ស.ស កាលពីឆ្នាំមុន។ ការនាំចូលទំនិញបានថយចុះ -៥,៤% ដែលឆ្លុះបញ្ចាំងពីការធ្លាក់ចុះតម្រូវការក្នុងស្រុកសម្រាប់ទំនិញនាំចូល រួមមាន ការនាំចូលយានយន្ត (-៣៣%) សម្ភារនិងបរិក្ខារសំណង់ (-១២,២%) ប្រេងឥន្ធនៈ (-១៤,៩%) និងវត្ថុធាតុដើមសម្រាប់វិស័យកាត់ដេរ (-៥,៨%)។ លើសពីនេះ ការនាំចូលម្ហូបអាហារនិងភេសជ្ជៈបានកើនឡើងតិចតួច (ក្រាហ្វ ៣)។ គួរកត់សម្គាល់ថា ការនាំចេញបានកើនឡើង ១៦,៥%[២] ធៀបនឹង ១៥,៦% នៅក្នុងឆ្នាំ២០១៩ ដោយសារការកើនឡើងនៃការនាំចេញមាស[៣] និងការនាំចេញទំនិញផ្សេងទៀត រួមមាន វាយនភណ្ឌ (១,៨%) គ្រឿងបង្គុំអេឡិចត្រូនិក (១៥០%) កង់ (២៧,៤%) អង្ករ (១២%) និងកៅស៊ូ (២៤,១%)។ ដោយឡែក ការនាំចេញសម្លៀកបំពាក់ និងស្បែកជើង បានថយចុះគួរឱ្យកត់សម្គាល់ ៩,៧% និង ១១,៦% រៀងគ្នា ដោយសារកត្តាការផ្គត់ផ្គង់មានឧបសគ្គពីការបិទខ្ទប់និងការរឹតត្បិតការធ្វើដំណើរ និងកត្តាការធ្លាក់ចុះតម្រូវការរបស់បណ្ដាប្រទេសជាច្រើន។ ការនាំចេញទៅសហគមន៍អឺរ៉ុប អង់គ្លេស និងជប៉ុន បានថយចុះ ១៥,៨%, ១៥,៤% និង ៧,៧% រៀងគ្នា។ គួររំលេចផងដែរថា ការនាំចេញទៅសហរដ្ឋអាមេរិក (មានសមាមាត្រ ៣០,៥% នៃការនាំចេញសរុប) បានកើនឡើង ១៨,២% ធៀបនឹង

[២] ការនាំចេញមិនរាប់បញ្ចូលការនាំចេញមាស បានធ្លាក់ចុះ -១,១%។

[៣] ក្នុងឆ្នាំ២០២០ ការនាំចេញមាសមានប្រមាណ ១៧,៥% នៃការនាំចេញសរុប។

៤៦,៣% កាលពីឆ្នាំមុន ហើយការនាំចេញទៅអាស៊ាន (២១,៦% នៃការនាំចេញសរុប) កើន ២,៧ដង គឺខ្ពស់ជាងកំណើន ៣,៥% នៅឆ្នាំមុន។

**ក្រាហ្វ ៣ ៖ ការនាំចេញ ការនាំចូល និងសមតុល្យពាណិជ្ជកម្មទំនិញ**

(ជាភាគរយ នៃផ.ស.ស, ឆ្នាំ២០១១ - ឆ្នាំ២០២០)




ប្រភព ៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

### ឃ- គណនីសេវា

**វិស័យសេវាត្រូវបានរងការប៉ះពាល់យ៉ាងខ្លាំងដោយសារការរីករាលដាលជំងឺកូវីដ-១៩ ដែលធ្វើឱ្យការនាំចេញសេវាសុទ្ធមានឱនភាពជាលើកដំបូង។** នៅឆ្នាំ២០២០ ការនាំចេញសេវាសុទ្ធមានឱនភាព ១២៣ លានដុល្លារអាមេរិក ធៀបនឹងអតិរេក ២.៨១២ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៩ ដោយសារការថយចុះនៃចំនួនភ្ញៀវអន្តរជាតិ។ ការនាំចេញសេវាបានធ្លាក់ចុះ -៦៨% ធៀបនឹងកំណើន ១១,៦% កាលពីឆ្នាំមុន ជាចម្បងដោយសារការថយចុះការនាំចេញសេវាទេសចរណ៍ -៧៨,៦%។ ចំនួនភ្ញៀវមកដល់ កម្ពុជាមានត្រឹម ១,៣ លាននាក់ ដែលបានធ្លាក់ចុះ -៨០,២% ធៀបនឹងកំណើន ៦,៦% នៅឆ្នាំ ២០១៩។ អត្រាកំណើននៃការមកដល់របស់ភ្ញៀវអន្តរជាតិបានចាប់ផ្តើមធ្លាក់ចុះនៅត្រីមាសទី២ ឆ្នាំ ២០២០ ដោយសារការរីករាលដាលជំងឺកូវីដ-១៩ ដែលធ្វើឱ្យមានការរឹតត្បិតការធ្វើដំណើររបស់ប្រទេសជាច្រើននៅជុំវិញពិភពលោក (ដូចបង្ហាញក្នុងក្រាហ្វ ៤)។

**ក្រាហ្វ ៤ ៖ ចំនួនភ្ញៀវទេសចរអន្តរជាតិ (កំណើនភ្ញៀវទេសចរអន្តរជាតិ និង គោលដៅនៃការធ្វើដំណើរ)**
(គិតជាភាគរយ, ឆ្នាំ២០១៤ - ឆ្នាំ២០២០)




**ក្រាហ្វ ៥ ៖ ចំនួនភ្ញៀវទេសចរអន្តរជាតិមកប្រទេសកម្ពុជា**
(ឆ្នាំ២០១៥ - ឆ្នាំ២០២០)




ប្រភព៖ ក្រសួងទេសចរណ៍ និងអគ្គនាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ

## ង- ប្រាក់បង្ញើរបស់ពលករក្រៅប្រទេស

**ប្រាក់បង្ញើរបស់ពលករក្រៅប្រទេសបានធ្លាក់ចុះយ៉ាងខ្លាំង ដោយសារតែការថមថយសកម្មភាពសេដ្ឋកិច្ចនិងការរឹតត្បិតការធ្វើដំណើរនៅបណ្តាប្រទេសដែលពលករចេញទៅបម្រើការងារ។** ប្រាក់បង្ញើបានធ្លាក់ចុះ -១៧% ពី ១,៥ ប៊ីលានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៩ មក ១,២ ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ២០២០។ ប្រាក់បង្ញើរបស់ពលករពីប្រទេសថៃ (មានសមាមាត្រ ៧៣% នៃប្រាក់បង្ញើសរុប) បានធ្លាក់ចុះ -១១% បន្ទាប់មកប្រទេសកូរ៉េ (មានសមាមាត្រ ១៦%) បានធ្លាក់ចុះ -៣០% ប្រទេសជប៉ុន (មានសមាមាត្រ ៦%) បានធ្លាក់ចុះ -៤% និងប្រទេសម៉ាឡេស៊ី (មានសមាមាត្រ ១,៤%) បានធ្លាក់ចុះ -៥១%។ ការរីករាលដាលជំងឺកូវីដ-១៩ បានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សកម្មភាពសេដ្ឋកិច្ច ជាពិសេសទៅលើអាជីវកម្ម ដែលជាហេតុធ្វើឱ្យមានការកាត់បន្ថយតម្រូវការកម្លាំងពលកម្ម។ ពលករចំណាកស្រុកកម្ពុជាជាច្រើនបានវិលត្រឡប់មកផ្ទះវិញ ហើយមានពលករថ្មីចំនួនតិចតួចប៉ុណ្ណោះដែលត្រូវបានអនុញ្ញាតឱ្យចំណាកស្រុកទៅធ្វើការក្រៅប្រទេស។ ក្នុងឆ្នាំ២០២០នេះ ចំនួនពលករចំណាកស្រុកកម្ពុជាមានចំនួន ១,២ លាននាក់ ថយចុះ -៨% ពីចំនួន ១,៣ លាននាក់ ក្នុងឆ្នាំ២០១៩[៤]។

[៤] ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

**ក្រាហ្វ ៦ ៖ ប្រាក់បន្ថែរបស់ពលករតាមប្រទេស**
(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១៣-២០២០)




**ក្រាហ្វ ៧ ៖ សមាមាត្រនៃប្រាក់បន្ថែរបស់ពលករតាមប្រទេស**
(គិតជាភាគរយ, ឆ្នាំ២០២០)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### ច- គណនីហិរញ្ញវត្ថុ

**លំហូរវិនិយោគផ្ទាល់បរទេស (FDI) បានថយចុះបន្តិចនៅឆ្នាំ២០២០ ដែលបណ្តាលមកពីការថយចុះលំហូរវិនិយោគលើវិស័យមិនមែនធនាគារ។** ដោយសារភាពមិនប្រាកដប្រជាចំពោះការវិវត្តនៃជំងឺកូវីដ-១៩ នៅឆ្នាំ២០២០នេះ លំហូរវិនិយោគផ្ទាល់បរទេសសរុបមាន ៣,៥ ប៊ីលានដុល្លារអាមេរិក បានថយចុះ -១% ហើយភាគច្រើននៃការវិនិយោគគឺក្នុងវិស័យហិរញ្ញវត្ថុ សំណង់និងអចលនទ្រព្យ និងវិស័យកម្មន្តសាល។ វិស័យហិរញ្ញវត្ថុដែលរួមចំណែកប្រមាណមួយភាគបីនៃលំហូរវិនិយោគបរទេសសរុប បានបន្តមានកំណើន ១២,៨% ក្នុងឆ្នាំ២០២០ ធៀបនឹង ១៥,៨% នៅក្នុងឆ្នាំ២០១៩ ដោយសារការកើនឡើងនៃប្រាក់ចំណេញវិនិយោគឡើងវិញ ការបន្ថែមដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធនាគារបើកថ្មី និងការពង្រីកខ្លួនពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទៅជាធនាគារពាណិជ្ជ (ក្រាហ្វ ៩)។ ទន្ទឹមនេះ លំហូរវិនិយោគបរទេសចំពោះវិស័យមិនមែនធនាគារបានថយចុះ -៩,៥% ដែលក្នុងនោះលំហូរវិនិយោគបរទេសក្នុងវិស័យសំណង់និងអចលនទ្រព្យ (មានសមាមាត្រ ១៧% នៃលំហូរវិនិយោគបរទេសសរុប) បានថយចុះ -១០,៦% និង វិស័យកម្មន្តសាល (មានសមាមាត្រ ១៦,២%) បានថយចុះ -៧,៥% (ក្រាហ្វ ៨)។

**ក្រាហ្វ ៨ ៖ លំហូរវិនិយោគផ្ទាល់បរទេសតាមវិស័យ**

(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១៤ - ឆ្នាំ២០២០)




**ក្រាហ្វ ៩ ៖ លំហូរវិនិយោគផ្ទាល់បរទេសចំពោះវិស័យហិរញ្ញវត្ថុ**

(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១៤ - ឆ្នាំ២០២០)




ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ១០ ៖ លំហូរវិនិយោគផ្ទាល់បរទេសតាមប្រទេស**

(ជាភាគរយ, ឆ្នាំ២០២០)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**ប្រទេសចិនបាននាំមុខគេផ្នែកលំហូរវិនិយោគផ្ទាល់ពីបរទេសមកកម្ពុជា។** ក្នុងឆ្នាំ២០២០ លំហូរវិនិយោគផ្ទាល់បរទេសពីប្រទេសចិនមានសមាមាត្រ ៥១% នៃវិនិយោគផ្ទាល់បរទេសសរុប បន្ទាប់មកគឺប្រទេសសិង្ហបុរី (៨,២%) កូរ៉េ (៧,៩%) ជប៉ុន (៥,៨%) អង់គ្លេស (៤,៩%) ម៉ាឡេស៊ី (៤,២%) និងថៃ (៣,៣%) (ក្រាហ្វ ១០)។ លំហូរវិនិយោគផ្ទាល់ពីប្រទេសចិនភាគច្រើនផ្តោតលើវិស័យកាត់ដេរសម្លៀកបំពាក់ ស្បែកជើង វារីអគ្គិសនី អចលនទ្រព្យ ហិរញ្ញវត្ថុ និងការស្នាក់នៅ (សណ្ឋាគារ ភោជនីយដ្ឋាន និងលំនៅឋាន)។

**នៅចុងឆ្នាំ២០២០ បំណុលក្រៅប្រទេសដុល[៩]បានកើនឡើង ១៤,៥% (ឆ្នាំលើឆ្នាំ) ដល់ ១៦ ប៊ីលានដុល្លារអាមេរិក ដោយសារការកើនឡើងនៃបំណុលរបស់រាជរដ្ឋាភិបាល។** បំណុលខាងក្រៅរបស់រាជរដ្ឋាភិបាលមានប្រមាណ ៩៩% នៃបំណុលរាជរដ្ឋាភិបាលសរុប បានកើនឡើង ១៦% (ឆ្នាំលើឆ្នាំ) ដល់ ៨,៨ ប៊ីលានដុល្លារអាមេរិក និងសុទ្ធតែជាបំណុលរយៈពេលវែង។ កំណើនបំណុលក្រៅប្រទេសរបស់គ្រឹះស្ថានទទួលប្រាក់បញ្ញើបានថយចុះពី ១៣,៣% (ឆ្នាំលើឆ្នាំ) ធៀបនឹង ២៥,២% កាលពីឆ្នាំមុន មកត្រឹម ៨,៦ ប៊ីលានដុល្លារអាមេរិក (៣៣% នៃផ.ស.ស) ក្នុងនោះ ៥៦% (៤,៩ ប៊ីលានដុល្លារអាមេរិក) ជាបំណុលរយៈពេលវែង ។

[៩] បំណុលក្រៅប្រទេសដុលរាប់បញ្ចូលបំណុលសាធារណៈក្រៅប្រទេស (រដ្ឋាភិបាល និងធនាគារកណ្តាល) និងបំណុលរបស់គ្រឹះស្ថានទទួលប្រាក់បញ្ញើ។

**ក្រាហ្វ ១១ ៖ សមាសធាតុនៃបំណុលក្រៅប្រទេសដុល**

(ជាភាគរយនៃផ.ស.ស., ឆ្នាំ២០១០ - ឆ្នាំ២០២០)




ប្រភព៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា

## ឆ- អត្រាប្តូរប្រាក់ និងស្ថិរភាពវិស័យខាងក្រៅ

**សម្ពាធទីផ្សារប្តូរប្រាក់ នៅកម្ពុជាស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន ខណៈអត្រាប្តូរប្រាក់នាមនាមបានកើនឡើងបន្តិច**[៦]។ នៅឆ្នាំ២០២០ សម្ពាធទីផ្សារប្តូរប្រាក់ប្រែប្រួលក្នុងគម្លាតស្តង់ដា ទោះបីជាបានកើនឡើងក្នុងខែមីនា ឆ្នាំ២០២០ (ក្រាហ្វ ១២) ខណៈដែលតម្លៃប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកបានធ្លាក់ថ្លៃបន្តិច ប៉ុន្តែនៅតែមានស្ថិរភាព។ បើធៀបទៅនឹងឆ្នាំ២០១៩ អត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាម (NEER) បានកើនឡើងបន្តិចនៅឆមាសទី២ ឆ្នាំ២០២០ ខណៈអត្រាប្តូរប្រាក់ប្រសិទ្ធភាពពិត (REER) មានកម្រិតទាបជាងអត្រា NEER ដោយសារអត្រាអតិផរណាទាបនៃដៃគូពាណិជ្ជកម្មសំខាន់ៗ លើកលែងតែប្រទេសវៀតណាម (ក្រាហ្វ ១៣)។

**ក្រាហ្វ ១២ ៖ សម្ពាធទីផ្សារប្តូរប្រាក់ (EMP)**

(ខែមករា ឆ្នាំ២០១៨ - ខែធ្នូ ឆ្នាំ២០២០)




**ក្រាហ្វ ១៣ ៖ អត្រាប្តូរប្រាក់ទ្វេភាគី និងអត្រាប្តូរប្រាក់ប្រសិទ្ធភាព**

(សន្ទស្សន៍ ឆ្នាំ២០១៥ = ១០០, ខែមករា ឆ្នាំ២០១៨ - ខែធ្នូ ឆ្នាំ២០២០)




ប្រភព ៖ ការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

[៦] វិធីសាស្ត្រនៃការគណនាសម្ពាធទីផ្សារប្តូរប្រាក់មានបង្ហាញនៅទំព័រទី៩ នៃរបាយការណ៍ស្តីពីស្ថានភាពស្ថិរភាពហិរញ្ញវត្ថុឆ្នាំ២០១៨

**ទុនបម្រុងអន្តរជាតិបានបន្តគរពូននិងបង្កើនទំនុកចិត្តលើរូបិយវត្ថុ និងសេដ្ឋកិច្ចក្នុងស្រុក។** ទុនបម្រុងអន្តរជាតិមាន ២១,៣ ប៊ីលានដុល្លារអាមេរិក គិតត្រឹមចុងឆ្នាំ២០២០ កើនឡើង ១៩% និងអាចធានាការនាំចូលទំនិញនិងសេវាគ្រាបន្ទាប់បានជាង ១០ខែ ដែលខ្ពស់ជាងកម្រិតអប្បបរមា ៣ខែ ដែលប្រទេសកំពុងអភិវឌ្ឍន៍គួរមាន។ អនុបាតទុនបម្រុងអន្តរជាតិធៀបនឹងរូបិយវត្ថុទូទៅមានកម្រិត ៦៣,៣% ដែលលើសពីអត្រាគោលត្រឹម ២០%។ បន្ថែមលើនេះ អនុបាតទុនបម្រុងអន្តរជាតិធៀបនឹងផ.ស.ស. មានកម្រិត ៧៦,២% ហើយអនុបាតទុនបម្រុងអន្តរជាតិធៀបនឹងប្រាក់បញ្ញើជារូបិយប័ណ្ណមានកម្រិត ៧៥,៥%។ ទោះយ៉ាងណា នៅក្នុងបរិការណ៍នៃសេដ្ឋកិច្ចដែលមានដុល្លារូបនីយកម្មខ្ពស់ និងរបបអត្រាប្តូរប្រាក់មានស្ថិរភាព កម្ពុជាត្រូវគរពូនទុនបម្រុងអន្តរជាតិបន្ថែមទៀត ដើម្បីជាទ្រនាប់ការពារហានិភ័យសំដៅរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ក្រាហ្វ ១៩ និង ១៥)។

**ក្រាហ្វ ១៤ ៖ ទុនបម្រុងអន្តរជាតិ**
(ឆ្នាំ២០១០ - ២០២០)




**ក្រាហ្វ ១៥ ៖ សូចនាករភាពគ្រប់គ្រាន់នៃទុនបម្រុងអន្តរជាតិ**
(គិតជាភាគរយ)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

## ១.២ ស្ថានភាព និងស្ថិរភាពសេដ្ឋកិច្ចកម្ពុជា

**ក- កំណើនសេដ្ឋកិច្ច**

**នៅឆ្នាំ២០២០ កំណើនសេដ្ឋកិច្ចកម្ពុជាបានធ្លាក់ចុះ -៣,១% ដោយសារការប៉ះទង្គិចធ្ងន់ធ្ងរពីឥទ្ធិពលនៃការរីករាលដាលជំងឺកូវីដ-១៩។** វិស័យចម្បងៗដែលគាំទ្រកំណើនសេដ្ឋកិច្ចនិងពឹងផ្អែកខ្លាំងពីតម្រូវការខាងក្រៅ រួមមាន វិស័យទេសចរណ៍ កម្មន្តសាល និងវិស័យសំណង់បានទទួលរងផលប៉ះពាល់ខ្លាំង ខណៈដែលវិស័យកសិកម្មរក្សាបានកំណើនវិជ្ជមាន។

**វិស័យទេសចរណ៍បានទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរជាងគេ ដែលរួមចំណែកប្រមាណ -១,៥% នៅក្នុងកំណើនសេដ្ឋកិច្ច។** ចំនួនភ្ញៀវអន្តរជាតិមកកាន់កម្ពុជាបានធ្លាក់ចុះយ៉ាងគំហុកក្នុងអត្រា -៨០,២% (ធៀបនឹងកំណើនឆ្នាំមុន ៦,៦%) មកនៅត្រឹម ១,៣លាននាក់ ដោយសារការរឹតត្បិតការធ្វើដំណើរ និងការព្រួយបារម្ភពីការឆ្លងជំងឺ។ ក្នុងពេលដែលការធ្វើដំណើរអន្តរជាតិបានរងផលប៉ះពាល់អវិជ្ជមានពីជំងឺកូវីដ-១៩ វិស័យទេសចរណ៍បានពឹងផ្អែកស្ទើរតែទាំងស្រុងទៅលើសកម្មភាពទេសចរណ៍ក្នុងស្រុក។ យ៉ាងណាមិញ ភ្ញៀវទេសចរក្នុងស្រុក (សមាមាត្រប្រមាណ ៧៧,៦% នៃភ្ញៀវទេសចរសរុប) បានរួមចំណែកជួយកាត់បន្ថយផលប៉ះពាល់តិចតួចប៉ុណ្ណោះមកលើវិស័យសណ្ឋាគារ ភោជនីយដ្ឋាន និងអាជីវកម្មពាក់ព័ន្ធនឹងវិស័យទេសចរណ៍ផ្សេងៗទៀត។

**វិស័យកម្មន្តសាលបានធ្លាក់ចុះ ដែលឆ្លុះបញ្ចាំងដោយការធ្លាក់ចុះនៃតម្រូវការខាងក្រៅ និងបានរួមចំណែក -០,៦% នៅក្នុងកំណើនសេដ្ឋកិច្ច។** ការបន្តអូសបន្លាយនៃជំងឺកូវីដ-១៩ បានធ្វើឱ្យការនាំចេញផលិតផលកម្មន្តសាល ជាពិសេស សម្លៀកបំពាក់និងស្បែកជើងបានថយចុះ -៩,៩% ខណៈដែលការនាំចេញផលិតផលក្រៅពីកាត់ដេរ រួមមានគ្រឿងបង្គុំអេឡិចត្រូនិក គ្រឿងបន្លាស់យានយន្តកង់ និងផលិតផលកសិកម្មផ្សេងទៀត មានកំណើនវិជ្ជមាន។ ផលិតផលសម្រេចសរុបក្នុងវិស័យនេះបានធ្លាក់ចុះ -៣៥,៣%[៤] ដោយក្នុងនោះ ផលិតផលឧស្សាហកម្មសម្រាប់នាំចេញ និងផលិតផលឧស្សាហកម្មបម្រើទីផ្សារក្នុងស្រុកបានធ្លាក់ចុះ -៤៣% និង -១២% រៀងគ្នា។

**វិស័យសំណង់និងអចលនទ្រព្យក៏បានទទួលរងការប៉ះទង្គិចពីការរីករាលដាលជំងឺកូវីដ-១៩ផងដែរ បន្ទាប់ពីការធ្លាក់ចុះនៃវិស័យទេសចរណ៍និងកម្មន្តសាល។** វិស័យសំណង់មានកំណើនអវិជ្ជមាន (រួមចំណែក -០,២% នៅក្នុងកំណើនសេដ្ឋកិច្ច) ដែលឆ្លុះបញ្ចាំងតាមរយៈការថមថយកំណើនចំនួនគម្រោង និងការធ្លាក់ចុះនៃការនាំចូលសម្ភារនិងបរិក្ខារសំណង់ (សូមមើលផ្នែកខ សម្រាប់ព័ត៌មានបន្ថែម)។

**ស្ថិតក្នុងបរិការណ៍នៃការរីករាលដាលជំងឺកូវីដ-១៩ វិស័យកសិកម្មបន្តមានកំណើនយឺត និងបានរួមចំណែក ០,០៦% ទៅកាន់កំណើនសេដ្ឋកិច្ច។** ទោះបីជាបានទទួលរងផលប៉ះពាល់ដោយផ្នែកពីគ្រោះរាំងស្ងួតនិងទឹកជំនន់ក៏ដោយ វិស័យកសិកម្មនៅបន្តមានកំណើនវិជ្ជមាន ដោយសារកំណើនកម្លាំងពលកម្មដែលបានងាកចេញពីវិស័យសេវាកម្មនិងឧស្សាហកម្ម។ លំហូរទុនវិនិយោគទាំងឯកជននិងសាធារណៈ និងវិនិយោគផ្ទាល់បរទេស ទៅក្នុងវិស័យកសិកម្មបានកើនឡើង ដោយសារវិនិយោគិនជាច្រើនមានការចាប់អារម្មណ៍កាន់តែច្រើនក្នុងការអភិវឌ្ឍនិងធ្វើពិពិធកម្មវិស័យកសិកម្ម។

[៤] ទិន្នន័យនេះរួមបញ្ចូលតែសហគ្រាសធំៗ ផ្អែកតាមទិន្នន័យទទួលបានពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

**ក្រាហ្វ ១៦ ៖ ការរួមចំណែកក្នុងកំណើនសេដ្ឋកិច្ចតាមវិស័យចម្បងៗ**

(ឆ្នាំ២០១៤ - ឆ្នាំ២០២១ ព្យាករណ៍)




ប្រភព ៖ វិទ្យាស្ថានជាតិស្ថិតិ

## ខ- វិស័យសំណង់និងអចលនទ្រព្យ

**បន្ទាប់ពីបានកើនឡើងយ៉ាងឆាប់រហ័សក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ វិស័យសំណង់និងអចលនទ្រព្យមានកំណើនអវិជ្ជមាន ដោយសារគម្រោងអភិវឌ្ឍន៍មួយចំនួនបានផ្អាកការសាងសង់។** យោងតាមក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅឆ្នាំ២០២០ ចំនួនគម្រោងសំណង់ដែលទទួលបានការអនុម័តមានកំណើនត្រឹម ១% ធៀបនឹង ៤៥,៥% កាលពីឆ្នាំ២០១៩ ដោយគម្រោងដែលទទួលបានការអនុម័តមានចំនួន ៤.៨៤១ គម្រោង (ក្រាហ្វ ១៧)។ ដូចបានបង្ហាញក្នុងក្រាហ្វ ១៨ នៅឆ្នាំ២០២០ ទុនវិនិយោគក្នុងវិស័យសំណង់បានធ្លាក់ចុះ -៣២,១% ពី ១១,៤ ប៊ីលានដុល្លារអាមេរិក នៅឆ្នាំ២០១៩ មកត្រឹម ៧,៨ ប៊ីលានដុល្លារអាមេរិក។ ទន្ទឹមនេះ ផ្ទៃក្រឡាគម្រោងសំណង់បានធ្លាក់ចុះ -២៦,៩% មកត្រឹមប្រមាណ ១៧ លានម៉ែត្រការ៉េ ដែលក្នុងនោះ គម្រោងសំណង់លំនៅឋានមានសមាមាត្រ ៤៦,១% នៃផ្ទៃក្រឡាគម្រោងសំណង់សរុប ពាណិជ្ជកម្ម ៣១,៥% និងឧស្សាហកម្ម ១៤,៦%។ លើសពីនេះ លំហូរវិនិយោគផ្ទាល់បរទេសទៅកាន់វិស័យសំណង់និងអចលនទ្រព្យ (សមាមាត្រ ១៧% នៃទុនវិនិយោគផ្ទាល់បរទេសសរុប) បានថយចុះ -១០,៦% ។ គួរកត់សម្គាល់ថា ទំហំឥណទានរបស់ធនាគារទៅកាន់វិស័យសំណង់និងអចលនទ្រព្យ (សមាមាត្រប្រមាណ ១៨% នៃឥណទានធនាគារសរុប) បានថមថយកំណើនមកត្រឹមប្រមាណ ២៣% នៅឆ្នាំ២០២០ ដែលបានកាត់បន្ថយក្តីបារម្ភចំពោះហានិភ័យនៃការកើនឡើងខ្លាំងនៅក្នុងទីផ្សារអចលនទ្រព្យ។

**ការនាំចូលសម្ភារនិងបរិក្ខារសំណង់ក៏បានថយចុះគួរឱ្យកត់សម្គាល់ផងដែរ ខណៈពេលដែលការផ្គត់ផ្គង់ស៊ីម៉ងត៍ក្នុងស្រុកបានបន្តកើនឡើង។** នៅឆ្នាំ២០២០ ការនាំចូលសម្ភារនិងបរិក្ខារសំណង់បានធ្លាក់ចុះ -១២,២% (មកត្រឹមប្រមាណ ២ ប៊ីលានដុល្លារអាមេរិក) ក្នុងនោះ ការនាំចូលស៊ីម៉ងត៍និងដែកបានធ្លាក់ចុះ -៤៨,៣% និង -៤៣,៣% រៀងគ្នា ស្របពេលដែលការនាំចូលបរិក្ខារសំណង់មានកំណើនយឺត ៧,៥%។ ដោយឡែក រោងចក្រផលិតស៊ីម៉ងត៍ក្នុងស្រុកចំនួន ៥ បានផលិតស៊ីម៉ងត៍ប្រមាណ ៧,៩ លានតោន[៩] កើនឡើង ៧% ធៀបនឹងឆ្នាំ២០១៩។ កំណើននេះឆ្លុះបញ្ចាំងអំពីតួនាទីសំខាន់នៃផលិតកម្មក្នុងស្រុក ក្នុងការកាត់បន្ថយការពឹងផ្អែកលើការនាំចូលស៊ីម៉ងត៍។

[៩] យោងតាមអត្ថបទសារព័ត៌មានភ្នំពេញប៉ុស្តិ៍ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២០

**លើសពីនេះ សូចនាករទីផ្សារនៅក្នុងវិស័យអចលនទ្រព្យបានបង្ហាញពីនិន្នាការផ្សេងៗគ្នាក្នុងអំឡុងឆ្នាំ២០២០។** នៅឆ្នាំនេះ តម្លៃដីនៅទ្រឹង ដែលប្រហាក់ប្រហែលទៅនឹងទីក្រុងនានាក្នុងតំបន់។ នៅរាជធានីភ្នំពេញ សកម្មភាពទិញ-លក់ដីនៅមានកម្រិតតិចតួច ដោយអ្នកទិញនៅរង់ចាំមើលស្ថានភាពសេដ្ឋកិច្ចក្នុងប្រទេស។ យោងតាមក្រុមហ៊ុនអចលនទ្រព្យ CBRE ការទិញ-លក់ដីឡូត៍តូចៗស្ថិតនៅតាមជាយក្រុងមានសកម្មភាពមមាញឹក ដោយសារការដាក់សម្ពាធមកលើសេដ្ឋកិច្ចពីជំងឺកូវីដ-១៩ ដែលបានបង្ខំឱ្យវិនិយោគិនថ្នាក់កណ្តាលសម្រេចចិត្តធ្វើប្រតិបត្តិការទាំងនោះ។ ការផ្គត់ផ្គង់ខុនដូបានកើនឡើង ១៧,៦% ដោយបានបន្ថែមចំនួន ៣.៧៧៨ យូនីត លើការផ្គត់ផ្គង់សរុប។ យ៉ាងណាមិញ ការកើនឡើងនេះមានកំណើនតិចជាងការព្យាករសម្រាប់ឆ្នាំ២០២១ ដែលរំពឹងថាវិស័យនេះ អាចផ្គត់ផ្គង់បន្ថែមចំនួន ១១.០០០ យូនីត។ ចំពោះប្រភេទការិយាល័យម្ចាស់តែមួយ ការជួលជាមធ្យមបានថយចុះ -១,៨% ក្នុងត្រីមាសទី៤ ឆ្នាំ២០២០ ដែលធ្វើឱ្យ ការជួលសរុបក្នុងឆ្នាំ២០២០ ថយចុះប្រមាណ -៧,៨%។ ប្រសិទ្ធភាពនៃការទាក់ទាញអ្នកជួលរបស់ប្រភេទការិយាល័យម្ចាស់ផ្សេងគ្នា ពីប្រភេទការិយាល័យម្ចាស់តែមួយ នៅមានភាពមិនច្បាស់លាស់នៅឡើយ ដែលអាចនឹងផ្តល់សម្ពាធបន្ថែមទៀតដល់តម្លៃនិងការជួលក្នុងឆ្នាំ២០២១។ ការផ្ទុះឡើងនៃព្រឹត្តិការណ៍សហគមន៍ ២៨ វិច្ឆិកា បានប៉ះពាល់ដល់វិស័យលក់រាយនិងផ្សារទំនើប ដែលបានបណ្តាលឱ្យមានការបិទជាបណ្តោះអាសន្ននូវកន្លែងលក់រាយ និងផ្សារទំនើបមួយចំនួន។ យ៉ាងណាមិញ ការលក់ក្នុងអំឡុងពេលបុណ្យណូអែល និងថ្ងៃចូលឆ្នាំសកលបានទាក់ទាញមនុស្សជាច្រើនទៅកាន់ទីផ្សារលក់រាយ។ ដោយឡែក ការតាមដានសកម្មភាពធ្វើដំណើរ (Mobility Tracker) របស់ Google បានបង្ហាញពីការធ្លាក់ចុះជាមធ្យមប្រមាណ -១៨% ក្នុងរយៈពេលមួយឆ្នាំ បើធៀបនឹងកម្រិតមូលដ្ឋានមុនពេលមានជំងឺរាតត្បាតកូវីដ-១៩ នៅខែកុម្ភៈ ឆ្នាំ២០២០។

**ក្រាហ្វ ១៧៖ ចំនួនគម្រោងសំណង់តាមវិស័យ**
(ឆ្នាំ២០១៦ - ឆ្នាំ២០២០)




**ក្រាហ្វ ១៨៖ តម្លៃគម្រោងសំណង់**
(លានដុល្លារអាមេរិក, ឆ្នាំ២០១៦ - ឆ្នាំ២០២០)




ប្រភព ៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**ក្រាហ្វ ១៩៖ សមាមាត្រនៃផ្ទៃក្រឡាគម្រោងសំណង់តាមវិស័យ**
(គិតជាភាគរយ ឆ្នាំ២០២០)




ប្រភព ៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់

**ក្រាហ្វ ២០៖ កំណើននៃការនាំចូលសម្ភារនិងបរិក្ខារសំណង់**
(ឆ្នាំ២០១៦ - ឆ្នាំ២០២០)




ប្រភព ៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

### គ- វិស័យរូបិយវត្ថុ

**នៅឆ្នាំ២០២០ កំណើនរូបិយវត្ថុទូទៅ (M2) បានថយចុះ ស្របទៅតាមសកម្មភាពសេដ្ឋកិច្ច ហើយដុល្លារូបនីយកម្មបន្តស្ថិតក្នុងកម្រិតខ្ពស់។** រូបិយវត្ថុទូទៅបានកើនឡើង ១៥,៣% ទាបជាងឆ្នាំមុន (១៨,២%) និងកំណើនមធ្យមក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ (២១%) ដោយការថមថយល្បឿនកំណើននេះបណ្តាលមកពីការធ្លាក់ចុះនៃសកម្មភាពសេដ្ឋកិច្ច។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ តម្រូវការប្រាក់រៀលបានកើនឡើងជាលំដាប់ ដោយសារកិច្ចខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជានិងរាជរដ្ឋាភិបាល ក្នុងការជំរុញការប្រើប្រាស់ប្រាក់រៀល។ យ៉ាងណាមិញ ដុល្លារូបនីយកម្ម[៩]នៅតែមានកម្រិតខ្ពស់ប្រមាណ ៨៣,៧% (ធៀបនឹង ៨៤,១% នៅឆ្នាំ២០១៩)។ ទោះយ៉ាងណា ប្រាក់បញ្ញើជារូបិយប័ណ្ណធៀបនឹងប្រាក់បញ្ញើសរុបក្នុងប្រព័ន្ធធនាគារបានថយចុះបន្តិចពី ៩២% នៅឆ្នាំ២០១៩ មក ៩១,៧% នៅឆ្នាំ២០២០ ហើយឥណទានជារូបិយប័ណ្ណបានថយចុះពី ៩០% មក ៨៦,៩% (ក្រាហ្វ ២១) ។

**ក្រាហ្វ ២១ ៖ ប្រាក់បញ្ញើនិងកម្ចីជារូបិយប័ណ្ណ**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

[៩] កម្រិតដុល្លារូបនីយកម្មត្រូវបានវាស់វែងតាមរយៈអនុបាតប្រាក់បញ្ញើជារូបិយប័ណ្ណធៀបនឹងរូបិយវត្ថុទូទៅ (FCD/M2)

**ធនាគារជាតិនៃកម្ពុជាបានចូលរួមយ៉ាងសកម្មក្នុងការលើកកម្ពស់ប្រាក់រៀល ដើម្បីបង្កើនជម្រើសគោលនយោបាយរូបិយវត្ថុ។** ធនាគារជាតិនៃកម្ពុជាបានខិតខំប្រឹងប្រែងក្នុងការជំរុញការប្រើប្រាស់រូបិយវត្ថុតាមរយៈវិធានការផ្សេងៗ រួមមានការលើកទឹកចិត្តក្នុងការដាក់ស្លាកតម្លៃទំនិញ ការផ្តល់ឥណទានជារៀល និងការបោះផ្សាយមូលបត្របំណុលសាជីវកម្មជាប្រាក់រៀលជាដើម។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាបានធ្វើទំនើបកម្មប្រព័ន្ធទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក ដែលបានសម្រួលការទូទាត់ជាប្រាក់រៀលឱ្យកាន់តែមានភាពងាយស្រួលនិងចំណាយតិចជាងមុន ខណៈដែលការទូទាត់ប្រតិបត្តិការឆ្លងប្រទេសជាប្រាក់រៀលក៏ត្រូវបានលើកកម្ពស់ផងដែរ។

**អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកបន្តមានស្ថិរភាពក្នុងរង្វង់ ៤.០៩០ រៀលក្នុងមួយដុល្លារអាមេរិក ខណៈដែលតម្លៃរូបិយប័ណ្ណផ្សេងទៀតក្នុងតំបន់មានការប្រែប្រួលខ្លាំង។** នៅឆ្នាំ២០២០ ដើម្បីរក្សាស្ថិរភាពអត្រាប្តូរប្រាក់ ធនាគារជាតិនៃកម្ពុជាបានធ្វើអន្តរាគមន៍ក្នុងទីផ្សារប្តូរប្រាក់តាមរយៈការលក់ប្រាក់ដុល្លារអាមេរិកនិងប្រាក់រៀលប្រមាណ ៨០,២ លានដុល្លារអាមេរិក និង ៦៩,៥ ប៊ីលានរៀល (១៧ លានដុល្លារអាមេរិក) រៀងគ្នា ទៅកាន់គ្រឹះស្ថានធនាគារនិងអាជីវករប្តូរប្រាក់។ ការធ្វើអន្តរាគមន៍ទាំងនេះបានរក្សាស្ថិរភាពតម្លៃប្រាក់រៀលធៀបនឹងដុល្លារអាមេរិក (ដោយបានថយថ្លៃត្រឹមតែ ០,៨% ធៀបនឹងឆ្នាំ២០១៩) ដែលបានចូលរួមចំណែកក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចផងដែរ។

**ធនាគារជាតិនៃកម្ពុជាបានបន្ធូរបន្ថយស្ថានភាពហិរញ្ញវត្ថុ តាមរយៈការទម្លាក់អត្រាប្រាក់បម្រុងកាតព្វកិច្ច ដើម្បីផ្តល់លទ្ធភាពដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងការបន្តផ្តល់ឥណទានដល់សេដ្ឋកិច្ច។** ដើម្បីផ្តល់សន្ទនីយភាពបន្ថែមដល់ប្រព័ន្ធធនាគារ ចាប់ពីខែមេសា ឆ្នាំ២០២០មក ធនាគារជាតិនៃកម្ពុជាបានទម្លាក់អត្រាការប្រាក់បម្រុងកាតព្វកិច្ចមកត្រឹម ៧% ពីកម្រិត ៨% ចំពោះប្រាក់រៀល និង ១២,៥% ចំពោះរូបិយប័ណ្ណបរទេស។ ជាមួយនឹងការកាត់បន្ថយនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទទួលបានសន្ទនីយភាពបន្ថែមជាង ១,៨ ប៊ីលានដុល្លារអាមេរិក ដែលបានផ្តល់អំណោយផលក្នុងការគ្រប់គ្រងហានិភ័យសន្ទនីយភាពបានយ៉ាងប្រសើរ, ផ្តល់លទ្ធភាពបង្កើនឥណទាន និងផ្តល់លទ្ធភាពក្នុងការរៀបចំឥណទានឡើងវិញសម្រាប់អង្គភាពគ្រួសារ និងអាជីវកម្មដែលរងផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចពីវិបត្តិជំងឺកូវីដ-១៩។

**លើសពីនេះ អត្រាការប្រាក់ដេញថ្លៃអប្បបរមានៃប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ក៏ត្រូវបានកាត់បន្ថយផងដែរ។** ដើម្បីកាត់បន្ថយថ្លៃដើមនៃមូលនិធិជារៀល ធនាគារជាតិនៃកម្ពុជាបានកាត់បន្ថយអត្រាការប្រាក់ដេញថ្លៃលើប្រតិបត្តិការ LPCO ចំនួន ០,៥% សម្រាប់គ្រប់ឥណប្រតិទានទាំងអស់។ ទន្ទឹមនេះ អត្រាការប្រាក់ NCD ជាប្រាក់រៀលនិងដុល្លារអាមេរិកក៏ត្រូវបានកាត់បន្ថយផងដែរ ដើម្បីលើកទឹកចិត្តដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឱ្យបន្តផ្តល់ឥណទានឱ្យបានច្រើន ជាជាងការរក្សាទុកសន្ទនីយភាព ដោយការទិញមូលបត្រអាចជួញដូរបាន (NCD)។

### ឃ- ស្ថានភាពអតិផរណា

**អតិផរណាបន្តមានកម្រិតទាប ដោយសារការធ្លាក់ចុះនៃថ្លៃក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ បើទោះជាថ្លៃក្រុមម្ហូបអាហារបានកើនឡើង។** នៅឆ្នាំ២០២០ អតិផរណាជាមធ្យមមានកម្រិតទាបក្នុងរង្វង់ ២,៩% ប៉ុន្តែខ្ពស់ជាងឆ្នាំ២០១៩ (១,៩%) ខណៈដែលនៅខែតុលានិងវិច្ឆិកា អតិផរណាបានកើនដល់ ៣,៧% ជាចម្បងដោយសារកំណើនថ្លៃក្រុមម្ហូបអាហារ។ អតិផរណាបានថយចុះក្នុង

ខែធ្នូ មកត្រឹម ២,៩% ដោយសារកំណើនយឺតនៃការកើនឡើងថ្លៃក្រុមម្ហូបអាហារនិងទំនិញស្នូល ខណៈពេលដែលថ្លៃក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈបន្តមានស្ថិរភាព។ គួររំលេចថា ប្រេងឆៅនៅលើពិភពលោកមានតម្លៃ ៤២[១០] ដុល្លារអាមេរិកក្នុង១បារ៉ែល នៅឆ្នាំ២០២០ ដែលមានកម្រិតទាបជាងឆ្នាំ២០១៩ (៦៤ ដុល្លារអាមេរិក ក្នុង១បារ៉ែល)។

**ក្រាហ្វ ២២ ៖ ការរួមចំណែកក្នុងអតិផរណា**

ជាភាគរយ, ឆ្នាំលើឆ្នាំ, ខែមករា ឆ្នាំ២០១៨ - ខែធ្នូ ឆ្នាំ២០២០




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

## ង- វិស័យសារពើពន្ធ

**ការធ្លាក់ចុះខ្លាំងនៃប្រាក់ចំណូលគួបផ្សំជាមួយនឹងការកើនឡើងនៃប្រាក់ចំណាយរបស់រាជរដ្ឋាភិបាល ដើម្បីគាំទ្រដល់សកម្មភាពសេដ្ឋកិច្ច ក្នុងបរិបទនៃការរីករាលដាលជំងឺកូវីដ-១៩ បានធ្វើឱ្យសមតុល្យសារពើពន្ធរួមរបស់រាជរដ្ឋាភិបាល មានឱនភាព (ក្រាហ្វ ២៣)។** នៅឆ្នាំ២០២០នេះ ស្ថានភាពសារពើពន្ធរបស់រាជរដ្ឋាភិបាលបានបង្ហាញពីការខ្ចីសុទ្ធ ប្រមាណ ២,៩% នៃផ.ស.ស ប៉ុន្តែឱនភាពនេះជាកម្រិតមួយទាបបើធៀបនឹងបណ្តាប្រទេសអាស៊ាន (ក្រាហ្វ ២៤)។ ស្ថានភាពសារពើពន្ធរបស់ប្រទេសកម្ពុជាអាចធន់នឹងវិបត្តិដោយសារលំហថវិកានៅមាន ដែលឆ្លុះបញ្ចាំងតាមរយៈកម្រិតខ្ពស់នៃប្រាក់សន្សំរបស់រាជរដ្ឋាភិបាល។

**ក្រាហ្វ ២៣ ៖ គណនីសារពើពន្ធ**

(ជាភាគរយនៃផ.ស.ស. ឆ្នាំ២០១១ - ឆ្នាំ២០២០)




ប្រភព ៖ អគ្គនាយកដ្ឋានរតនាគារជាតិ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**ក្រាហ្វ ២៤ ៖ ស្ថានភាពសារពើពន្ធនៃប្រទេសអាស៊ាន**

(ជាភាគរយនៃផ.ស.ស. ឆ្នាំ២០១២ - ឆ្នាំ២០២០)




ប្រភព ៖ Statista (https://www.statista.com/statistics/804386/asean-countries-budget-balance-in-relation-to-gdp/)

[១០] យោងតាមការព្យាកររយៈពេលខ្លីនៃរដ្ឋបាលសារព័ត៌មានថាមពលសហរដ្ឋអាមេរិក (EIA)

**នៅឆ្នាំ២០២០នេះ ការប្រមូលចំណូលរបស់រាជរដ្ឋាភិបាលបានធ្លាក់ចុះ គួរឱ្យកត់សម្គាល់ជាលើកដំបូងក្នុងរយៈពេល១ទសវត្សរ៍ចុងក្រោយ ដែលបណ្តាលមកពីការថមថយនៃសកម្មភាពសេដ្ឋកិច្ច និងគោលនយោបាយបន្ធូរបន្ថយពន្ធ ក្នុងអំឡុងពេលការរីករាលដាលជំងឺកូវីដ-១៩។** ប្រាក់ចំណូលរបស់រាជរដ្ឋាភិបាលមានចំនួន ២២ ទ្រីលានរៀល (៥,៤ ប៊ីលានដុល្លារអាមេរិក) បានធ្លាក់ចុះ -១៩% ធៀបនឹងកំណើន ២៣% នៅឆ្នាំ២០១៩។ ការធ្លាក់ចុះនេះ បណ្តាលមកពីការថយចុះនៃការប្រមូលពន្ធ (-១៣%) ក្នុងនោះពន្ធលើទំនិញនិងសេវាកម្មបានថយចុះ -២១% និងពន្ធលើពាណិជ្ជកម្មក្រៅប្រទេស -២៤,១% ដោយសារគោលនយោបាយបន្ធូរបន្ថយពន្ធ និងការថមថយនៃសកម្មភាពសេដ្ឋកិច្ច។

**ក្រាហ្វ ២៥ ៖ ការរួមចំណែកក្នុងកំណើនប្រាក់ចំណូល**

(ជាភាគរយ, ឆ្នាំ២០១១ - ឆ្នាំ២០២០)




ប្រភព ៖ អគ្គនាយកដ្ឋានរតនាគារជាតិ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**កម្មវិធីគាំពារសង្គមរួមទាំងការឧបត្ថម្ភសាច់ប្រាក់ពលកម្ម និងការឧបត្ថម្ភសាច់ប្រាក់ជូនក្រុមគ្រួសារក្រីក្រ បានបង្កើនចំណាយរបស់រាជរដ្ឋាភិបាល និងបានជួយការពារគ្រួសារងាយរងគ្រោះ។** នៅឆ្នាំនេះ ប្រាក់ចំណាយរបស់រាជរដ្ឋាភិបាល មានចំនួន ២៥ ទ្រីលានរៀល (៦,១ ប៊ីលានដុល្លារអាមេរិក) បានកើនឡើង ០,៧% បើប្រៀបធៀបទៅនឹងកំណើន ១៥,២% ក្នុងឆ្នាំ២០១៩។ ការកើនឡើងបន្តិចនេះ បណ្តាលមកពីការកើនឡើងនៃចំណាយលើសុខុមាលភាពសង្គម (កើនទ្វេដង) និងប្រាក់បៀវត្សរ៍ (៣,៣%) ប៉ុន្តែត្រូវបានផាត់ទាត់ជាមួយនឹងការធ្លាក់ចុះនៃការចំណាយលើការប្រើប្រាស់ទំនិញនិងសេវា (-២៧,៥%) និងទ្រព្យអចល័ត (-៤,២%)។ ការចំណាយលើប្រាក់ឧបត្ថម្ភសង្គមពាក់ព័ន្ធនឹងសុខភាព និងជំនួយជាសាច់ប្រាក់ បានកើនឡើងទ្វេដងដើម្បីឆ្លើយតបនឹងកិច្ចគាំពាររបស់រាជរដ្ឋាភិបាលជូនប្រជាជនដែលរងការប៉ះពាល់ដោយការរីករាលដាលជំងឺកូវីដ-១៩។ គួរកត់សម្គាល់ថា រាជរដ្ឋាភិបាលធ្លាប់បានប្រកាសមូលនិធិបម្រុងបន្ទាន់ ចំនួន ៨០០ លានដុល្លារអាមេរិក (សេណារីយ៉ូ ៦ ខែ) និង ២ ប៊ីលានដុល្លារអាមេរិក (សេណារីយ៉ូមួយឆ្នាំ) ក្នុងការដោះស្រាយវិបត្តិសុខភាពនេះ។ ទោះយ៉ាងណាចំណាយដើមទុនបានធ្លាក់ចុះ -៤% បើប្រៀបធៀបនឹងឆ្នាំមុន។

**ក្រាហ្វ ២៦ ៖ ការរួមចំណែកក្នុងកំណើនប្រាក់ចំណាយ**

(ជាភាគរយ, ឆ្នាំ២០១១ - ឆ្នាំ២០២០)




ប្រភព ៖ អគ្គនាយកដ្ឋានរតនាគារជាតិ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**ក្រាហ្វ ២៧ ៖ សមាមាត្របំណុលសាធារណៈ ក្រៅប្រទេស បែងចែកតាមប្រទេសចម្បងៗ**

(ជាភាគរយ, គិតត្រឹមឆ្នាំ២០២០)




ប្រភព ៖ អគ្គនាយកដ្ឋានរតនាគារជាតិ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**បើទោះជាបំណុលរាជរដ្ឋាភិបាលបន្តមាននិរន្តរភាព ប៉ុន្តែត្រូវទាមទារឱ្យមានតាមដានជិតដល់។** គិតត្រឹមចុងឆ្នាំ២០២០ បំណុលរបស់រាជរដ្ឋាភិបាល មានចំនួន ៨,៨ ប៊ីលានដុល្លារអាមេរិក (៣២,៨% នៃផ.ស.ស) បានកើនឡើង ១៦%។ ប្រទេសចិននៅតែជាអ្នកផ្តល់ប្រាក់កម្ចីធំជាងគេដែលមានសមាមាត្រ ៤៥,២% នៃបំណុលរាជរដ្ឋាភិបាលសរុប បន្ទាប់មក គឺកម្ចីពហុភាគី (៣១,២%) ប្រទេសជប៉ុន (៥,៧%) និងប្រទេសកូរ៉េ (៤,៩%)។ គួរកត់សម្គាល់ថាសមាមាត្របំណុលពីប្រទេសចិនបានធ្លាក់ចុះពីកម្រិតមធ្យម ៤៧% ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ មកនៅត្រឹម ៤៥% ក្នុងឆ្នាំនេះ ខណៈដែលសមាមាត្រនៃប្រាក់កម្ចីពហុភាគី បានកើនឡើងពី ២៨% ទៅ ៣១% (ក្រាហ្វ ២៧)។ យោងតាមការវិភាគចីរភាពបំណុលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបង្ហាញថាបំណុលរាជរដ្ឋាភិបាលរំពឹងថានឹងកើនឡើងដល់ ១៤ ប៊ីលានដុល្លារអាមេរិក ក្នុងឆ្នាំ២០២៤ ក្នុងនោះរាជរដ្ឋាភិបាលគ្រោងខ្ចី ប្រមាណ ២ ប៊ីលានដុល្លារអាមេរិក ប្រចាំឆ្នាំ ដែលចំនួននេះ លើសពីកម្រិតគោល ១,៤ ប៊ីលានអេសដេអ៊ែរ (១,៩ ប៊ីលានដុល្លារអាមេរិក)។ បើទោះជាបំណុលរាជរដ្ឋាភិបាលមានការកើនឡើងយ៉ាងឆាប់រហ័ស ប៉ុន្តែនៅបន្តមាននិរន្តរភាពរហូតដល់ឆ្នាំ២០២៤ ដោយសារស្ថិតក្រោមកម្រិតគោល ៤០% នៃផ.ស.ស។

**ប្រអប់ ១ ៖ វិធានការគាំទ្ររបស់រាជរដ្ឋាភិបាលដើម្បីជួយលើកស្ទួយអាជីវកម្មក្នុងស្រុក និងសុខុមាលភាពសង្គម ក្នុងបរិបទនៃការរីករាលដាលជំងឺកូវីដ-១៩ ។**

នៅដើមឆ្នាំ២០២០ រាជរដ្ឋាភិបាលបានប្រកាសមូលនិធិបម្រុងគ្រាអាសន្នពី ៨០០ លានដុល្លារអាមេរិក (សេណារីយ៉ូ ៦ ខែ) និង ២ ប៊ីលានដុល្លារអាមេរិក (សេណារីយ៉ូមួយឆ្នាំ) ដើម្បីកាត់បន្ថយផលប៉ះពាល់នៃជំងឺកូវីដ-១៩។ មូលនិធិនេះ អាចជួយឱ្យអាជីវកម្មបន្តដំណើរការ និងស្តារសកម្មភាពសេដ្ឋកិច្ចឡើងវិញ។ នៅក្នុងឆ្នាំ២០២០នេះ វិធានការអន្តរាគមន៍ រួមបញ្ចូលវិធានការលើកស្ទួយសុខុមាលភាពសង្គម និងសេដ្ឋកិច្ច មានចំនួន៧ជុំ។ គម្រោងគាំពារសង្គម តាមរយៈការឧបត្ថម្ភជាសាច់ប្រាក់ដល់ជនក្រីក្រនិងងាយរងគ្រោះ ត្រូវបានអនុវត្តចាប់តាំងពីខែមិថុនា ឆ្នាំ២០២០។ គិតត្រឹមខែកុម្ភៈ ឆ្នាំ២០២១ រាជរដ្ឋាភិបាលបានចំណាយថវិកា ចំនួន ៩២២,៣ ប៊ីលានរៀល (២៣០,៥ លានដុល្លារអាមេរិក) និងបានជួយប្រជាជនក្រីក្រនិងងាយរងគ្រោះ ប្រមាណ ២,៧ លាននាក់ (៦៨៨.៥៣៩ គ្រួសារ)។ បន្ថែមពីវិធានការខាងលើនេះ ការលើកលែងពន្ធនិងវិធានការមួយចំនួនផ្សេងទៀត ត្រូវបានអនុវត្តរួចរាល់ ដូចខាងក្រោម៖

- បញ្ចូលអាករលើតម្លៃបន្ថែមនៃអាហារមូលដ្ឋាន ក្រោមបន្ទុកបង់ពន្ធរបស់រាជរដ្ឋាភិបាល រយៈពេលពីរឆ្នាំ (ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០ ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១)
- ផ្តល់ការលើកលែងពន្ធរយៈពេលប្រាំមួយខែ ទៅមួយឆ្នាំ សម្រាប់រោងចក្រដែលរងផលប៉ះពាល់ធ្ងន់ធ្ងរ ដោយសារការរីករាលដាលជំងឺកូវីដ-១៩ និងការព្យួរ " អ្វីៗទាំងអស់លើកលែងតែអាវុធ (EBA)"
- លើកលែងការបង់កម្រៃថ្លៃអាជ្ញាប័ណ្ណទាំងអស់នៅក្នុងវិស័យទេសចរណ៍ សម្រាប់ឆ្នាំ២០២១
- ផ្តល់ការលើកលែងពន្ធនិងកាត់បន្ថយការធ្វើសវនកម្មលើសណ្ឋាគារ និងផ្ទះសំណាក់ដែលមានទីតាំងនៅខេត្តសៀមរាប សម្រាប់ឆ្នាំ២០២០
- លើកលែងពន្ធប្រថាប់ត្រាសម្រាប់ផ្ទះដែលមានតម្លៃទាបជាង ៧០.០០០ ដុល្លារអាមេរិក
- លើកលែងការបង់ពន្ធអប្បបរមាប្រចាំខែ សម្រាប់ក្រុមហ៊ុនអាកាសចរណ៍កម្ពុជា
- ពន្យារពេលការបង់ប្រាក់ជំពាក់ កម្រៃអាកាសចរស៊ីវិល និងអនុញ្ញាតឱ្យក្រុមហ៊ុនអាកាសចរស៊ីវិលរៀបចំបង់ប្រាក់ជំពាក់ជាដំណាក់កាលក្រោយរយៈពេលពន្យារ
- លើកលែងការបង់ពន្ធប្រចាំខែសម្រាប់សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងភ្នាក់ងារទេសចរណ៍
- ផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មករ-និយោជិតកាត់ដេរចំនួន ៧០ ដុល្លារអាមេរិក ក្នុងមួយខែ (រាជរដ្ឋាភិបាល ៤០ ដុល្លារអាមេរិក និងនិយោជក ៣០ ដុល្លារអាមេរិក) ដោយមិនតម្រូវឱ្យនិយោជិតចូលរួមវគ្គបណ្តុះបណ្តាល។
- ផ្តល់ប្រាក់ឧបត្ថម្ភ ៤០ ដុល្លារអាមេរិក ក្នុងមួយខែ ជូនកម្មករ-និយោជិតដែលបំពេញការងារក្នុងវិស័យទេសចរណ៍ ដូចជាសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងភ្នាក់ងារទេសចរណ៍
- ផ្តល់ប្រាក់កម្ចីដែលមានអត្រាការប្រាក់ទាប ចំនួន ៥០ លានដុល្លារអាមេរិក ដើម្បីជួយសហគ្រាសធុនតូចនិងមធ្យម ក្នុងវិស័យកសិកម្ម និងផលិតកម្ម
- ផ្តល់គម្រោងហិរញ្ញប្បទានពិសេស ចំនួន ៥០ លានដុល្លារអាមេរិក ដល់ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម ដើម្បីគាំទ្រដល់ក្រុមហ៊ុនកែច្នៃកសិផល

- បង្កើតគម្រោងធានាឥណទាន ដើម្បីបន្ធូរបន្ថយសម្ពាធទុនបង្វិល
- ពង្រីកវិសាលភាពនិងទំហំថវិកាសម្រាប់កម្មវិធីការឧបត្ថម្ភជាសាច់ប្រាក់ដើម្បីឱ្យមានការងារសម្រាប់ទ្រទ្រង់ជីវភាពកម្មករ-និយោជិតដែលបាត់បង់ការងារនៅតាមរោងចក្រ-សហគ្រាស និងកម្មករ-និយោជិតដែលត្រឡប់មកពីធ្វើការនៅបរទេសវិញ
- ទម្លាក់ពន្ធកាត់ទុកលើកម្ចីរបស់ម្ចាស់កម្ចីទាំងប្រភពក្នុងស្រុកនិងបរទេស
- បង្កើតកម្មវិធីបណ្តុះបណ្តាល និងលើកកម្ពស់ជំនាញឡើងវិញ សម្រាប់កម្មករ-និយោជិតដែលត្រូវបានបញ្ឈប់ពីការងារ សម្រាប់វិស័យទេសចរណ៍ និងកាត់ដេរ និង
- កាត់បន្ថយអត្រាពន្ធនាំចូលលើផលិតផលអាកុលនិងផលិតផលដែលពាក់ព័ន្ធព្រមទាំងវត្ថុធាតុដើមសម្រាប់ផលិតកម្មអាហារនិងភេសជ្ជៈ។

# ២. ស្ថានភាពនិងការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុ

## ២.១ ទិដ្ឋភាពទូទៅ ស្ថានភាព និងការវាយតម្លៃប្រព័ន្ធធនាគារ

### ក- ទិដ្ឋភាពទូទៅនៃប្រព័ន្ធធនាគារ

**ប្រព័ន្ធធនាគារកម្ពុជា[១១]បន្តរក្សាបានភាពធន់ ទោះបីស្ថិតក្នុងការរីករាលដាលជំងឺកូវីដ-១៩ ក៏ដោយ។** ការអភិវឌ្ឍវិស័យធនាគារក្នុងអំឡុងពេលប៉ុន្មានទសវត្សរ៍ចុងក្រោយ គួបផ្សំនឹងការដាក់ចេញ និងអនុវត្តតាមបទប្បញ្ញត្តិប្រុងប្រយ័ត្ន អាចឱ្យធនាគារជាតិនៃកម្ពុជាដាក់ចេញវិធានការបុរេសកម្ម ដើម្បីបន្ធូរបន្ថយបទប្បញ្ញត្តិ ផ្តល់សន្ទនីយភាពបន្ថែម និងអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ រៀបចំឥណទានឡើងវិញជូនអតិថិជន ក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩។ លើសពីនេះ ដោយសារមានកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ព្រមទាំងការដាក់ចេញជាបន្តបន្ទាប់នៃវិធានការអន្តរាគមន៍និងគាំទ្រសេដ្ឋកិច្ច ប្រព័ន្ធធនាគារបន្តរក្សា បានជំនឿទុកចិត្តរបស់សាធារណជននិងវិនិយោគិន។

**ក្រាហ្វ ២៨ ៖ ប្រព័ន្ធធនាគារកម្ពុជានៅឆ្នាំ២០២០**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**ទ្រព្យសកម្មក្នុងប្រព័ន្ធធនាគារបានកើនឡើង ១៣,៩% ដោយវិស័យធនាគារបន្តមាន សមាមាត្រទ្រព្យសកម្មធំជាងគេ។** នៅឆ្នាំ២០២០ ទ្រព្យសកម្មវិស័យធនាគារមានចំនួន ២០៤,២ ទ្រីលានរៀល (៥០,៥ ប៊ីលានដុល្លារអាមេរិក) កើនឡើង ១៧,៦% ធៀបនឹងឆ្នាំមុន ១៧៥ ទ្រីលាន រៀល (៤៣ ប៊ីលានដុល្លារអាមេរិក)។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួនបានក្លាយជាធនាគារ ដែល បាននាំឱ្យមានការកើនឡើងនៃសមាមាត្រទ្រព្យសកម្មនិងឥណទានរបស់វិស័យធនាគារនៅក្នុង ប្រព័ន្ធពី ៨៣% និង ៧៧,៧% ដល់ ៨៥,៦% និង ៨២% រៀងគ្នា។ ដោយឡែក សមាមាត្រទ្រព្យសកម្ម របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (MDI) ក្នុងប្រព័ន្ធធនាគារ បានថយចុះ -២,៣% មក ៣០,១ ទ្រីលានរៀល (៧,៤ ប៊ីលានដុល្លារអាមេរិក) ស្របពេលដែលសមាមាត្ររបស់គ្រឹះស្ថាន

[១១] គិតត្រឹមខែធ្នូ ឆ្នាំ២០២០ ប្រព័ន្ធធនាគារ រួមមាន៖ ធនាគារពាណិជ្ជ ៥២, ធនាគារឯកទេស ១៣, ការិយាល័យតំណាង ៦, គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ ៨១ (មីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៦ និងមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ៧៥), គ្រឹះស្ថានទូទាត់សងប្រាក់ ២៤, ក្រុមហ៊ុន ភតិសន្យា ១៥ និងគ្រឹះស្ថានឥណទានជនបទ ២៤៥។

មីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ (MFI) ថយចុះ -១២,៩% មក ៤,២ ទ្រីលានរៀល (១ ប៊ីលានដុល្លារអាមេរិក)។ ការថយចុះសមាមាត្រទាំងនេះ បណ្តាលមកពី៖ i/-MDI មួយបានរួមបញ្ចូលគ្នាជាមួយធនាគារពាណិជ្ជ ii/-MDI មួយបានក្លាយជាធនាគារពាណិជ្ជ និង iii/- MFI មួយក្លាយជា MDI។ វិស័យមីក្រូហិរញ្ញវត្ថុមានចំនួនគ្រឹះស្ថានច្រើនជាងវិស័យធនាគារ ប៉ុន្តែមានប្រតិបត្តិការនិងទំហំតូចនៅឡើយ។ (ក្រាហ្វ ២៩ និង ៣០)

**ក្រាហ្វ ២៩ ៖ សមាមាត្រទ្រព្យសកម្ម**

គិតជាភាគរយ ត្រីមាសទី១ ឆ្នាំ២០១៧ - ត្រីមាសទី៤ ឆ្នាំ២០២០




**ក្រាហ្វ ៣០ ៖ សមាមាត្រឥណទាន**

គិតជាភាគរយ ត្រីមាសទី១ ឆ្នាំ២០១៧ - ត្រីមាសទី៤ ឆ្នាំ២០២០




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

## ខ- ការវិភាគឥណទានតាមវិស័យ

**ឥណទាននៅក្នុងវិស័យធនាគារបន្តផ្តល់ទៅកាន់វិស័យសេដ្ឋកិច្ចសំខាន់ៗដូចជា សំណង់ អចលនទ្រព្យ កម្ចីទិញផ្ទះ និងការជួញដូរដុំនិងរាយ ខណៈដែលឥណទានរបស់វិស័យមីក្រូហិរញ្ញវត្ថុ បានផ្តល់ទៅកាន់ក្រុមគ្រួសារ ពាណិជ្ជកម្ម និងកសិកម្ម។** ចំណែកឥណទានរបស់វិស័យធនាគារទៅវិស័យជួញដូរាយ និងដុំ មាន ២៦,២% នៃឥណទានសរុប (ក្នុងនោះ ១៦,១% ជាឥណទានក្នុងវិស័យជួញដូរាយ)។ ឥណទានទៅកាន់វិស័យសំណង់ និងអចលនទ្រព្យ បានបន្តកើនឡើងដល់ ១០,២% និង ៨,៧% នៃឥណទានសរុប រៀងគ្នា។ ទន្ទឹមនេះ ចំណែកឥណទានសម្រាប់កម្ចីទិញផ្ទះបន្តកើនឡើងប្រមាណ ២% ធៀបនឹងឆ្នាំមុនដល់ ១៣,៧% នៃឥណទានសរុប ដែលមកពីការប្រែប្រួល MDI ចំនួន ១ ទៅជាគ្រឹះស្ថានធនាគារពាណិជ្ជ។ ឥណទានទៅកាន់វិស័យកម្មន្តសាល និងសណ្ឋាគារនិងភោជនីយដ្ឋាន បានធ្លាក់ចុះបន្តិចពីសមាមាត្រដូចគ្នា៤,៦% នៅឆ្នាំមុន មក ៤,២% និង ៤,១% រៀងគ្នា។ ចំពោះវិស័យមីក្រូហិរញ្ញវត្ថុ ឥណទានទៅកាន់ក្រុមគ្រួសារមានចំណែកធំជាងគេ ៣១,៦% នៃឥណទានសរុប បន្ទាប់មកពាណិជ្ជកម្ម ២១% កសិកម្ម ១៩,៣% និងសេវាកម្ម ១៥,៧%។ វិស័យមីក្រូហិរញ្ញវត្ថុនៅតែបន្តដើរតួនាទីយ៉ាងសកម្មក្នុងការគាំទ្រវិស័យកសិកម្ម និងសហគ្រាសធុនតូច និងមធ្យម។ (ក្រាហ្វ ៣១ និង ៣២)

**ក្រាហ្វ ៣១ ៖ ឥណទានធនាគារតាមវិស័យសេដ្ឋកិច្ច**
ឆ្នាំ២០១៧ - ឆ្នាំ២០២០

**ក្រាហ្វ ៣២ ៖ ឥណទានមីក្រូហិរញ្ញវត្ថុតាមវិស័យសេដ្ឋកិច្ច**
ឆ្នាំ២០១៧ - ឆ្នាំ២០២០







ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**ស្ថានភាពហិរញ្ញវត្ថុកម្ពុជាបានបន្ធូរបន្ថយ ដើម្បីរក្សាសន្ទនីយភាពសំដៅគាំទ្រសកម្មភាពសេដ្ឋកិច្ច។** គិតត្រឹមចុងឆ្នាំ២០២០ កំណើនឥណទានក្នុងប្រព័ន្ធធនាគារមានកម្រិត ១៦,៩% ទាបជាង ២៧,៣% នៅឆ្នាំមុន។ ទោះបីជាកំណើនឥណទានបានថមថយ ឥណទានក្នុងប្រព័ន្ធធនាគារហាក់មានភាពល្អប្រសើរក្នុងឆមាសទី២ ឆ្នាំ២០២០ ដោយសារការរីករាលដាលជំងឺកូវីដ-១៩ អាចគ្រប់គ្រងបាន និងតម្រូវការទុនបង្វិលពីម្ចាស់អាជីវកម្មបានកើនឡើង។ ឥណទានរបស់គ្រឹះស្ថានធនាគារនៅបន្តមានកំណើនតិចតួច ខណៈដែលឥណទានរបស់MDI និង MFIមាននិន្នាការថយចុះ។ (ក្រាហ្វ ៣៣)

**ក្រាហ្វ ៣៣ ៖ កំណើនឥណទានក្នុងប្រព័ន្ធធនាគារ**
គិតជាភាគរយ ត្រីមាសទី១ ឆ្នាំ២០១៦ - ត្រីមាសទី៤ ឆ្នាំ២០២០




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

### គ- កំណើនឥណទានតាមវិស័យរបស់វិស័យធនាគារ

**ឥណទាននៅក្នុងវិស័យធនាគារមានកំណើន ១៨% នៅឆ្នាំ២០២០ ធៀបនឹង ២៣,៥% ឆ្នាំ ២០១៩។** វិស័យដែលរួមចំណែកក្នុងកំណើនឥណទានធំជាងគេគឺ ឥណទានទៅកាន់វិស័យពាណិជ្ជកម្ម (ការជួញដូររាយ និងដុំ ៥%) កម្ចីទិញផ្ទះ (៤%) ការឱ្យខ្ចីជាបុគ្គល (៣%) កសិកម្ម (២%) សំណង់ (២%) និងអចលនទ្រព្យ (១,៨%)។ ឥណទានទៅកាន់វិស័យកម្មន្តសាល និងសណ្ឋាគារនិងភោជនីយដ្ឋាន បានរួមចំណែកតិចតួចនៅក្នុងកំណើនឥណទាន (០,៦% និង ០,៥% រៀងគ្នា)។ ឥណទានសម្រាប់វិស័យមិនមែនហិរញ្ញវត្ថុបន្តមានកំណើន ១៩,៧% ក្នុងឆ្នាំ២០២០ ប្រហាក់ប្រហែលនឹងឆ្នាំមុន (១៩,៤%) ហើយឥណទានសម្រាប់តម្រូវការផ្ទាល់ខ្លួនក៏បន្តមានកំណើន ៣៨,៥% ធៀបនឹង ៣៧,៣% ក្នុងឆ្នាំ ២០១៩។ (ក្រាហ្វ ៣៤)

**ក្រាហ្វ ៣៤ ៖ ការរួមចំណែកនៃឥណទានតាមវិស័យទៅកាន់កំណើនឥណទានធនាគារសរុប**

គិតជាភាគរយ ត្រីមាសទី១ ឆ្នាំ២០១៦ - ត្រីមាសទី៤ ឆ្នាំ២០២០




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**ទោះបីជាមានភាពរអាក់រអួលក្នុងសកម្មភាពអាជីវកម្ម និងតម្រូវការតិចតួចស្ទើរគ្រប់វិស័យសេដ្ឋកិច្ចទាំងអស់ ហិរញ្ញប្បទានទៅកាន់វិស័យជួញដូរដុំ និងរាយនៅបន្តរួមចំណែក ២៦,៣% នៃឥណទានសរុបរបស់វិស័យធនាគារ ដោយសារអាជីវកម្មចាប់ផ្ដើមមានភាពប្រសើរក្នុងឆមាសទី២ ឆ្នាំ២០២០។ យ៉ាងណាមិញ ភាពល្អប្រសើរនេះក៏នៅមានភាពមិនស្មើសាច់នៅឡើយ។** កំណើនឥណទានទៅកាន់វិស័យជួញដូរដុំបានថមថយមកត្រឹម ៨,៥% ក្នុងឆ្នាំ២០២០ ធៀបនឹងឆ្នាំមុន ២០,៧% ខណៈដែលឥណទានទៅកាន់វិស័យជួញដូររាយបន្តមានកំណើន ២៣,២% ខ្ពស់ជាងឆ្នាំមុន (១៩,៣%)។ កំណើនខ្ពស់នៃឥណទានក្នុងវិស័យជួញដូររាយត្រូវបានរួមចំណែកដោយការកើនឡើងនៃតម្រូវការឥណទានសម្រាប់សហគ្រាសធុនតូច និងមធ្យម និងជាពិសេសអាជីវកម្មតាមប្រព័ន្ធអនឡាញ។

**ក្រាហ្វ ៣៥ ៖ ចំណែកឥណទានធនាគារតាមវិស័យ**
(គិតជាភាគរយ, ឆ្នាំ២០១៨, ២០១៩ និង ២០២០)




**ក្រាហ្វ ៣៦ ៖ កំណើនឥណទានក្នុងវិស័យចម្បងៗ**
(គិតជាភាគរយ, ត្រីមាសទី១ ២០១៦ - ត្រីមាសទី៤ ឆ្នាំ២០២០)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**ឥណទានទៅកាន់សណ្ឋាគារនិងភោជនីយដ្ឋាន មានកំណើនទាបក្នុងឆ្នាំ២០២០ (១០,៥%) ធៀបនឹងកំណើន ១៩,៣% ឆ្នាំមុន ដោយសារចំណូលរបស់អាជីវកម្មក្នុងវិស័យនេះបានធ្លាក់ចុះខ្លាំង ស្របពេលដែលភ្ញៀវទេសចរថយចុះ និងការកាត់បន្ថយចំណាយមិនចាំបាច់ផ្សេងៗ។** វិស័យទេសចរណ៍ និងសេវាកម្ម បានទទួលរងផលប៉ះពាល់ខ្លាំងជាងគេពីការរីករាលដាលជំងឺកូវីដ-១៩។ ទេសចរណ៍ក្នុងស្រុកហាក់មានភាពល្អប្រសើរ ប៉ុន្តែក៏មិនអាចគ្រប់គ្រាន់ក្នុងការផាត់ទាត់នឹងការបាត់បង់ចំណូលពីភ្ញៀវទេសចរបរទេសដែរ។

**ឥណទានទៅកាន់វិស័យកម្មន្តសាលមានកំណើនវិជ្ជមានក្នុងឆ្នាំ២០២០។ ភាពប្រសើរឡើងក្នុងវិស័យនេះបានឆ្លុះបញ្ចាំងតាមរយៈការកើនឡើងការនាំចេញផលិតផលបង្គុំអេឡិចត្រូនិក និងវេជ្ជសាស្ត្រ ជាពិសេសក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩។** បន្ទាប់ពីមានកំណើនអវិជ្ជមានក្នុងត្រីមាសទី២ និងទី៣ ឥណទានទៅកាន់វិស័យកម្មន្តសាលមានកំណើន ១២,៧% គិតត្រឹមចុងឆ្នាំ ២០២០ ដែលឆ្លុះបញ្ចាំងពីការកើនឡើងនៃតម្រូវការផលិតផលក្រៅពីទំនិញសម្រាប់ការធ្វើដំណើរ។

**ទន្ទឹមនេះ ឥណទានទៅកាន់វិស័យកសិកម្មមានកំណើនខ្ពស់ ដោយសារការកើនឡើងនៃការទទួលបានកម្លាំងពលកម្មមួយចំនួនដែលបាត់បង់ការងារពីវិស័យសេវាកម្ម និងឧស្សាហកម្ម។** សមាមាត្រឥណទានទៅកាន់វិស័យកសិកម្មមានកម្រិត ៨% នៃឥណទានសរុបរបស់វិស័យធនាគារ។ កំណើនឥណទានក្នុងវិស័យនេះមានកម្រិត ២៥,៦% ក្នុងឆ្នាំ២០២០ ធៀបនឹង ៣,៦% ឆ្នាំមុន ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនៃតម្រូវការផលិតផលកសិកម្មក្នុងស្រុក។

**ទោះបីជាមានវិបត្តិសុខភាព ឥណទានសម្រាប់ទិញផ្ទះបន្តមានកំណើន ៤០% ក្នុងឆ្នាំ២០២០ (៤១,៣% ក្នុងឆ្នាំ២០១៩) ដោយសារតម្រូវការក្នុងស្រុកខ្ពស់ទៅលើទីផ្សារអចលនទ្រព្យ (ជាពិសេសបុរី)។** យ៉ាងណាមិញ ឥណទានសម្រាប់ទិញផ្ទះអាចនឹងស្ថិតក្រោមរូបភាពផ្សេងទៀតក្រៅពីឥណទានពីវិស័យធនាគារ ដោយសារតែក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យក៏បានផ្តល់ការបង់រំលស់សម្រាប់អតិថិជនរបស់

ខ្លួនផងដែរ ដែលមិនបានស្ថិតនៅក្រោមបទប្បញ្ញត្តិត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា។ ទន្ទឹមនេះ ការរីករាលដាលជំងឺកូវីដ-១៩ អាចធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពសងត្រលប់របស់អតិថិជន ដោយសារការបាត់បង់ចំណូល និងអាចមានការកើនឡើងហានិភ័យនៃបំណុលលើសលប់របស់ក្រុមគ្រួសារ។

**កំណើនឥណទានទៅកាន់វិស័យសំណង់ និងអចលនទ្រព្យមាននិន្នាការថមថយ ខណៈសកម្មភាពសំណង់មួយចំនួនត្រូវបានផ្អាក។** ទោះបីជាសកម្មភាពសំណង់មួយចំនួននៅទ្រឹងចាប់ពីពាក់កណ្ដាលឆ្នាំ២០២០មក កំណើនឥណទានទៅកាន់វិស័យសំណង់នៅមានកម្រិតខ្ពស់ ២៦,៣% ប៉ុន្តែទាបជាងកំណើនឆ្នាំ២០១៩ (២៩,១%) ។ ដោយឡែក កំណើនឥណទានក្នុងវិស័យអចលនទ្រព្យបានថមថយល្បឿនដោយមានកម្រិតត្រឹម ២០,១% ធៀបនឹង ៤០,៣% ឆ្នាំ២០១៩ ឆ្លុះបញ្ចាំងតាមរយៈការវិវត្តយឺតនៃគម្រោងអចលនទ្រព្យជាច្រើន និងការថយចុះនៃការលក់។

**ក្រាហ្វ ៣៧ ៖ ចំណែកឥណទានធនាគារទាក់ទងវិស័យអចលនទ្រព្យ**
(គិតជាភាគរយ, ឆ្នាំ២០១៨, ២០១៩ និង ២០២០)




**ក្រាហ្វ ៣៨ ៖ កំណើនឥណទានក្នុងវិស័យទាក់ទងនឹងអចលនទ្រព្យ**
(គិតជាភាគរយ, ត្រីមាសទី១ ២០១៦ - ត្រីមាសទី៤ ឆ្នាំ២០២០)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**ឥណទានសម្រាប់តម្រូវការផ្ទាល់ខ្លួនបន្តមានកំណើន ៣៨,៤% ក្នុងឆ្នាំ២០២០ ខ្ពស់ជាងកំណើនឆ្នាំ២០១៩ បន្តិច (៣៧,៣%) ទោះបីជាមានការរឹតត្បិតការធ្វើដំណើរក្នុងឆមាសទី១ ឆ្នាំ២០២០ និងការថយចុះនៃចំណាយរបស់ក្រុមគ្រួសារក៏ដោយ។** ឥណទានសម្រាប់ទិញផ្ទះ នៅតែរួមចំណែកធំក្នុងកំណើនឥណទានសម្រាប់តម្រូវការផ្ទាល់ខ្លួន (២២,៤%) ខណៈដែលការឱ្យខ្ចីជាបុគ្គលរួមចំណែក ១៦% និងឥណទានសម្រាប់ប័ណ្ណឥណទាននៅមានកម្រិតទាប។ ទន្ទឹមនេះ កំណើននៃការឱ្យខ្ចីជាបុគ្គលបានកើនឡើងពី ៣៣% ក្នុងឆ្នាំ២០១៩ ទៅ ៣៧% ក្នុងឆ្នាំ២០២០។

**ឥណទានសាជីវកម្ម មានចំណែក ៧៦% នៃឥណទានសរុបរបស់វិស័យធនាគារ និងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក។** កំណើនឥណទានសាជីវកម្មមានកម្រិត ១៩,៧% គិតត្រឹមចុងឆ្នាំ២០២០ (១៩,៤% ឆ្នាំ២០១៩) ដោយរួមចំណែកជាចម្បងដោយឥណទានទៅកាន់វិស័យជួញដូររាយ (៤,៨%) សំណង់ (៣,៤%) កសិកម្ម (២,៥%) អចលនទ្រព្យ (២,៥%) និងជួញដូរដុំ (១,៦%)។ ដោយឡែក ការរួមចំណែកពីឥណទានទៅកាន់សណ្ឋាគារនិង

ភោជនីយដ្ឋានបានថយចុះ (មក ០,៦២%) ធៀបនឹងឆ្នាំ២០១៩ ខណៈដែលការរួមចំណែករបស់ឥណទានទៅកាន់វិស័យកសិកម្ម និងកម្មន្តសាល នៅមានកម្រិតទាប។

**ក្រាហ្វ ៣៩ ៖ ចំណែកនៃកំណើនឥណទានក្រុមគ្រួសារ**
(គិតជាភាគរយ, ត្រីមាសទី១ ២០១៦ - ត្រីមាសទី៤ ឆ្នាំ២០១៩)




**ក្រាហ្វ ៤០ ៖ ចំណែកនៃកំណើនឥណទានសាជីវកម្ម**
(គិតជាភាគរយ, ត្រីមាសទី១ ២០១៧ - ត្រីមាសទី៤ ឆ្នាំ២០១៩)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

## ឃ- វិស័យមីក្រូហិរញ្ញវត្ថុ

**វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាបានចូលរួមអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងដើរតួនាទីយ៉ាងសំខាន់ក្នុងបរិយាបន្នហិរញ្ញវត្ថុ តាមរយៈការផ្តល់ហិរញ្ញប្បទាន និងសេវាហិរញ្ញវត្ថុផ្សេងៗទៅដល់ប្រជាពលរដ្ឋដែលពុំទាន់មានលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុ។** ផលិតផល និងសេវា របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានដូចជា ការឱ្យខ្ចីជាក្រុម ជាបុគ្គល និងអាជីវកម្ម ជាពិសេសសហគ្រាសធុនតូច និងមធ្យម។ នៅឆ្នាំ២០២០ វិស័យមីក្រូហិរញ្ញវត្ថុបានផ្តល់សេវាហិរញ្ញវត្ថុទៅដល់ប្រជាជន និងសហគ្រាសធុនតូច និងមធ្យមប្រមាណ ២ លាននាក់/សហគ្រាស តាមរយៈ MDIចំនួន ៦ និង MFI ៧៥ និងបានបង្កើតការងារដល់យុវជន និងនិស្សិតប្រមាណ ៣០ ម៉ឺននាក់។

**ឥណទានដែលផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមាននិន្នាការថមថយក្នុងឆ្នាំ២០២០ ដោយមានកំណើន ១៤,៤% ធៀបនឹង ៣៣% ឆ្នាំ២០១៩។** កំណើនឥណទានក្នុងគ្រឹះស្ថាននេះ បានរួមចំណែកជាចម្បងពីឥណទានទៅកាន់ក្រុមគ្រួសារ (៥,៣%) ពាណិជ្ជកម្ម (៣,៨%) សេវាកម្ម (២,៣%) ការដឹកជញ្ជូន (០,៨៥%) កសិកម្ម (០,០៥%) និងផ្សេងៗ។

**ទន្ទឹមនេះ ឥណទានដែលផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើក៏បង្ហាញពីនិន្នាការដូចគ្នាផងដែរ ដោយមានកំណើនត្រឹម ១,៧២% ធៀបនឹង ៣២,៥% ក្នុងឆ្នាំ២០១៩។** កំណើនឥណទានក្នុងគ្រឹះស្ថាននេះ បានរួមចំណែកជាចម្បងពីឥណទានទៅកាន់វិស័យសំណង់ (៣,៨%) ពាណិជ្ជកម្ម (៣,៣%) សេវាកម្ម (១,៤%) កសិកម្ម (១%) និងផ្សេងៗ។ អតិថិជនដែលបានខ្ចីពីវិស័យមីក្រូហិរញ្ញវត្ថុភាគច្រើននៅក្នុងវិស័យទេសចរណ៍ សណ្ឋាគារនិងផ្ទះសំណាក់ សំណង់ និង

ការដឹកជញ្ជូន ហើយភាគច្រើនពួកគាត់បានរងផលប៉ះពាល់ខ្លាំងជាងគេពីការធ្លាក់ចុះសេដ្ឋកិច្ច និងជំនន់ទឹកភ្លៀងនាចុងឆ្នាំក៏បានផ្តល់សម្ពាធកាន់តែខ្លាំង។

**ការបាត់បង់ការងារ និងចំណូលរបស់ពលករចំណាកស្រុក បានប៉ះពាល់ខ្លាំងដល់ប្រាក់បង្វែររបស់ពួកគាត់ដែលត្រូវបានចាត់ទុកថាជាចំណូលសំខាន់សម្រាប់ប្រជាជននៅតាមជនបទ[១២]។** ពលករជាច្រើននាក់បានបាត់បង់ការងារ ឬចំណូលទាំងស្រុងដោយសារការរីករាលដាលជំងឺកូវីដ-១៩។ ការសម្ភាសប្រជាពលរដ្ឋដែលមានសមាជិកគ្រួសារជាពលករចំណាកស្រុក បានបង្ហាញថា ចំណូលពីពួកគាត់បានថយចុះ ៤៧% ចាប់តាំងពីការមានវិបត្តិសុខភាពមក។ ហេតុដូចនេះ ពួកគាត់បានជួបប្រទះបញ្ហាក្នុងការសងត្រលប់នៃកម្ចី ហើយក៏លំបាកក្នុងការខ្ចីឥណទានថ្មីផងដែរ។ ក្នុងឆ្នាំ២០២០ ការរួមចំណែករបស់ឥណទានទៅកាន់ក្រុមគ្រួសារ បានថយចុះខ្លាំងក្នុងកំណើនឥណទានវិស័យមីក្រូហិរញ្ញវត្ថុ ដោយបានថយចុះពី ៨% ក្នុងឆ្នាំ២០១៩ ទៅត្រឹម ៥% ក្នុងឆ្នាំ២០២០ សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងពី ១២,៦% ក្នុងឆ្នាំ២០១៩ ទៅការរួមចំណែកអវិជ្ជមានសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ។

**ក្រាហ្វ ៤១ ៖ ការរួមចំណែកកំណើនឥណទាន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើតាមវិស័យ**
(គិតជាភាគរយ, ត្រីមាសទី១ ឆ្នាំ២០១៦-ត្រីមាសទី៤ ឆ្នាំ២០២០)




**ក្រាហ្វ ៤២ ៖ ការរួមចំណែកកំណើនឥណទាន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើតាមវិស័យ**
(គិតជាភាគរយ, ត្រីមាសទី១ ឆ្នាំ២០១៦-ត្រីមាសទី៤ ឆ្នាំ២០២០)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

[១២] របាយការណ៍បច្ចុប្បន្នកម្មសេដ្ឋកិច្ចកម្ពុជារបស់ធនាគារពិភពលោក ខែវិច្ឆិកា ឆ្នាំ២០២០

## ង- គុណភាពឥណទាន

គុណភាពឥណទានក្នុងប្រព័ន្ធធនាគារបន្តមានសុខភាពល្អ ក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩ ឆ្លុះបញ្ចាំងតាមរយៈកម្រិតទាបនៃអនុបាតឥណទានមិនដំណើរការ និងគាំទ្រដោយការដាក់ចេញវិធានការបុរេសកម្មរបស់ធនាគារជាតិនៃកម្ពុជា។ អនុបាតឥណទានមិនដំណើរការរបស់ប្រព័ន្ធធនាគារមានកម្រិត ២,១% កើនឡើងធៀបនឹងឆ្នាំ២០១៩ (១,៧%)។ អនុបាតឥណទានមិនដំណើរការសម្រាប់វិស័យធនាគារ និងវិស័យមីក្រូហិរញ្ញវត្ថុ បានកើនឡើងជាបន្តបន្ទាប់ក្នុងឆ្នាំ២០២០ ពី ២% និង ០,៨% នៅឆ្នាំ២០១៩ ដល់ ២,១% និង ១,៨% រៀងគ្នា។ កម្រិតទាបនៃអនុបាតឥណទានមិនដំណើរការ ត្រូវបានរួមចំណែកដោយការរៀបចំឥណទានឡើងវិញ ដែលបានអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរក្សាចំណាត់ថ្នាក់ឥណទានឱ្យនៅដដែលសម្រាប់ឥណទានដែលត្រូវបានរៀបចំឡើងវិញ។ (ក្រាហ្វ ៤៣)

**ក្រាហ្វ ៤៣ ៖ ឥណទានមិនដំណើរការ**

គិតជាភាគរយ ត្រីមាសទី១ ឆ្នាំ២០១៧ - ត្រីមាសទី៤ ឆ្នាំ២០២០




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

## ច- គុណភាពឥណទានតាមវិស័យ

អនុបាតឥណទានមិនដំណើរការក្នុងវិស័យកសិកម្មមានកម្រិត ៥,៦% នៅឆ្នាំ២០២០ ធៀបនឹង ៧,៤% នៅឆ្នាំ២០១៩ ខណៈអនុបាតឥណទានមិនដំណើរការក្នុងវិស័យកម្មន្តសាលមានកម្រិតខ្ពស់ ៤,២%។ អនុបាតឥណទានមិនដំណើរការមានកម្រិត ២,១% សម្រាប់ឥណទានទៅវិស័យសំណង់ និង ២,៤% សម្រាប់ឥណទានទៅវិស័យសណ្ឋាគារនិងភោជនីយដ្ឋាន។ ទោះបីកំណើនឥណទានទៅវិស័យអចលនទ្រព្យនិងកម្ចីទិញផ្ទះផ្ទាល់ខ្លួនមានកម្រិតខ្ពស់ អនុបាតឥណទានមិនដំណើរការទៅវិស័យទាំងនេះមានកម្រិតទាប ១% និង ១,១% រៀងគ្នា ធៀបនឹងឆ្នាំ២០១៩ (០,៩% និង ០,៤% រៀងគ្នា)។ ដោយឡែក អនុបាតឥណទានមិនដំណើរការទៅវិស័យផ្សេងៗទៀត ដូចជា ការជួញដូរដុំនិងរាយ បន្តមានកម្រិតទាបជាង ២%។

**ក្រាហ្វ ៤៤ ៖ អនុបាតឥណទានមិនដំណើរការតាមវិស័យធុរកិច្ចចម្បងៗរបស់គ្រឹះស្ថានធនាគារ**

(គិតជាភាគរយ, ត្រីមាសទី៤ ឆ្នាំ២០១៤ - ត្រីមាសទី៤ ឆ្នាំ២០២០)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៤៥ ៖ អនុបាតឥណទានមិនដំណើរការក្នុងវិស័យអចលនទ្រព្យនិងការប្រើប្រាស់ផ្ទាល់ខ្លួន**

(គិតជាភាគរយ, ត្រីមាសទី១ ឆ្នាំ២០១៧ - ត្រីមាសទី៤ ឆ្នាំ២០២០)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ប្រអប់ ២៖ ឥណទានរៀបចំឡើងវិញសម្រាប់អតិថិជនដែលរងផលប៉ះពាល់ពីការរីករាលដាលជំងឺកូវីដ-១៩

**ទោះបីឥណទានរៀបចំឡើងវិញបានថមថយនៅចុងឆ្នាំ២០២០ក្តី ក៏ភាពមិនច្បាស់លាស់នៅតែបន្តដោយសារការអូសបន្លាយនៃការរីករាលដាលជំងឺកូវីដ-១៩។** ធនាគារជាតិនៃកម្ពុជាបានចេញសារាចរណែនាំស្តីពី ឥណទានរៀបចំឡើងវិញក្នុងអំឡុងពេលរងផលប៉ះពាល់ពីការរីករាលដាលជំងឺកូវីដ-១៩ នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ ដើម្បីអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរៀបចំឥណទានឡើងវិញសម្រាប់អតិថិជនដែលបានជួបប្រទះការធ្លាក់ចុះចំណូលដោយផ្តល់អាទិភាពដល់វិស័យចម្បងៗចំនួនបួនគឺ វិស័យកាត់ដេរ, ដឹកជញ្ជូននិងឡូជីស្ទិក, ទេសចរណ៍ និងសំណង់។ បន្ទាប់ពីការដាក់ចេញសារាចរណែនាំនេះ ចំនួនឥណទានរៀបចំឡើងវិញបានកើនឡើង ជាពិសេសក្នុងខែមេសានិងឧសភា។ ទោះយ៉ាងណា កំណើននេះបានថមថយចាប់ពីខែមិថុនា ឆ្នាំ២០២០មក ហើយបានឈានដល់កំណើនអវិជ្ជមាន (ខែលើខែ) ចាប់ពីត្រីមាសទី៣មក។ គិតត្រឹមចុងឆ្នាំ ឥណទានរៀបចំឡើងវិញមានចំនួន ៤ ប៊ីលានដុល្លារអាមេរិក ស្មើនឹង ១០,៧% នៃឥណទានសរុប ក្នុងនោះឥណទានរៀបចំឡើងវិញក្នុងវិស័យធនាគារមានចំនួន ២,៩ ប៊ីលានដុល្លារអាមេរិក, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៨១៣,៩ លានដុល្លារអាមេរិក, និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ២៧៥,៧ លានដុល្លារអាមេរិក។ បើគិតជាចំនួនគណនី ប្រព័ន្ធធនាគារទាំងមូលមានឥណទានរៀបចំឡើងវិញ ២៩២.៨៤១ គណនី ក្នុងនោះ ៩៣.៧១០ គណនីជារបស់គ្រឹះស្ថានធនាគារ, ១៥១.៣១៦ គណនី ជារបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ, និង ៤៧.៨១៥ គណនី ជារបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ។ (ក្រាហ្វ ៤៦ និង ៤៧)

**ក្រាហ្វ ៤៦ ៖ ចំនួនគណនីឥណទានរៀបចំឡើងវិញ**
ខែមេសា - ខែធ្នូ ឆ្នាំ២០២០




**ក្រាហ្វ ៤៧ ៖ ចំនួនឥណទានរៀបចំឡើងវិញ**
គិតជាលានដុល្លារអាមេរិក ខែមេសា - ខែធ្នូ ឆ្នាំ២០២០




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ឥណទានរៀបចំឡើងវិញ បានជួយដល់អតិថិជនរងផលប៉ះពាល់ជាច្រើនក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩។** ក្នុងចំណោមវិស័យអាទិភាពទាំងបួន អតិថិជនក្នុងវិស័យកាត់ដេរទទួលបានការរៀបចំឥណទានច្រើនជាងគេ ដោយមានចំនួន ៥៨.១៩៩ គណនី បន្ទាប់មកវិស័យទេសចរណ៍ (២៤.៦៨៥ គណនី), វិស័យសំណង់ (២០.៦០៩ គណនី) និងដឹកជញ្ជូននិងឡូជីស្ទិក (១៣.៧៣១ គណនី)។ គ្រឹះស្ថានធនាគារបានរៀបចំឥណទានឡើងវិញចំនួន ៧.៦៩០ គណនី សម្រាប់វិស័យសំណង់, ៤.២៣២ គណនី សម្រាប់វិស័យទេសចរណ៍, ២,៩៩៧ គណនី សម្រាប់វិស័យដឹកជញ្ជូននិងឡូជីស្ទិក និង ២.៣៨០ គណនី សម្រាប់វិស័យកាត់ដេរ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើបានរៀបចំឥណទានឡើងវិញចំនួន ៣៨.៥២០ គណនី សម្រាប់វិស័យកាត់ដេរ, ១៤,៣៤៣ គណនី សម្រាប់វិស័យទេសចរណ៍, ១០.៥៣១ គណនី សម្រាប់វិស័យសំណង់ និង ៦.៥០៦ គណនី សម្រាប់វិស័យដឹកជញ្ជូននិងឡូជីស្ទិក។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើបានរៀបចំឥណទានឡើងវិញចំនួន ១៧.២៩៩ គណនី សម្រាប់វិស័យកាត់ដេរ, ៦.១១០ គណនី សម្រាប់វិស័យទេសចរណ៍, ៤.២២៨ គណនី សម្រាប់វិស័យដឹកជញ្ជូននិងឡូជីស្ទិក និង ២.៣៨៨ គណនី សម្រាប់វិស័យសំណង់។

**ក្រាហ្វ ៤៨ ៖ គណនីឥណទានរៀបចំឡើងវិញក្នុងប្រព័ន្ធធនាគារតាមវិស័យអាទិភាព**




**ក្រាហ្វ ៤៩ ៖ គណនីឥណទានរៀបចំឡើងវិញរបស់គ្រឹះស្ថានធនាគារតាមវិស័យអាទិភាព**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៥០ ៖ គណនីឥណទានរៀបចំឡើងវិញរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើតាមវិស័យអាទិភាព**




**ក្រាហ្វ ៥១ ៖ គណនីឥណទានរៀបចំឡើងវិញរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើតាមវិស័យអាទិភាព**




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

### ឆ- ស្ថានភាពសន្ទនីយភាព និងប្រភពមូលនិធិ

**គ្រឹះស្ថានធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ រក្សាបាននូវអនុបាតក្របខ័ណ្ឌសន្ទនីយភាពខ្ពស់ជាងកម្រិតកំណត់ដោយបទប្បញ្ញត្តិ (១០០%)។** ជាមធ្យម អនុបាតក្របខ័ណ្ឌសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារពាណិជ្ជមានកម្រិត ១៦២,៥% កើនឡើងធៀបនឹងឆ្នាំ២០១៩ (១៥៥,៨%)។ ជាមួយគ្នានេះ អនុបាតរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើបានកើនឡើងគួរឱ្យកត់សម្គាល់ពី ១៧៨,១% ដល់ ២៤០,៤%។ កំណើនសន្ទនីយភាពត្រូវបានរួមចំណែកគាំទ្រដោយការដាក់ចេញវិធានការផ្តល់សន្ទនីយភាពរបស់ធនាគារជាតិនៃកម្ពុជា, ការផ្តល់ឥណទានប្រកបដោយភាពប្រុងប្រយ័ត្នរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងការកើនឡើងនៃប្រាក់បញ្ញើ និងការសន្សំ (១១,៨%[១៣]) ក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩។ ទ្រព្យសកម្មសន្ទនីយត្រូវបានរក្សានៅកម្រិតប្រមាណ ២០% នៃទ្រព្យសកម្មសរុប ខណៈដែលសមាមាត្រទ្រព្យអកម្មបរទេសបានកើនឡើងពី ១៦,១% ដល់ ១៧,១% នៃទ្រព្យអកម្មសរុប។ (ក្រាហ្វ ៥២ និង ៥៣)

[១៣] កំណើនឆ្នាំលើឆ្នាំដោយបានកែតម្រូវទិន្នន័យរបស់ធនាគារហត្ថា

**ក្រាហ្វ ៥២ ៖ អនុបាតគ្របខណ្ឌសន្ទនីយភាព**
គិតជាភាគរយ ត្រីមាសទី១ ឆ្នាំ២០១៧ - ត្រីមាសទី៤ ឆ្នាំ២០២០




**ក្រាហ្វ ៥៣ ៖ ស្ថានភាពសន្ទនីយភាព**
គិតជាភាគរយ ត្រីមាសទី១ ឆ្នាំ២០១៧ - ត្រីមាសទី៤ ឆ្នាំ២០២០




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**ប្រាក់បញ្ញើនៅតែជាប្រភពទុនចម្បងរបស់គ្រឹះស្ថានធនាគារ។** នៅឆ្នាំ២០២០ សមាមាត្រប្រាក់បញ្ញើក្នុងប្រភពមូលនិធិសរុប បានថយចុះបន្តិចមក ៦៧% ធៀបនឹងឆ្នាំមុន (៦៩%) ខណៈដែលសមាមាត្រដើមទុនបានកើនឡើងដល់ ២១% (ឆ្នាំមុន ១៩%)។ ដោយឡែក មូលនិធិកម្ចីរបស់គ្រឹះស្ថានធនាគារមានចំណែកប្រមាណ ១៣% នៃប្រភពមូលនិធិសរុប ក្នុងនោះមាន ៦៤% ជាមូលនិធិកម្ចីរយៈពេលវែង ដែលមានកម្រិតខ្ពស់ជាងឆ្នាំ២០១៩ (៦០,១%)។ (ក្រាហ្វ ៥៤ និង ៥៥)

**ក្រាហ្វ ៥៤ ៖ ប្រភពមូលនិធិក្នុងវិស័យធនាគារ**
គិតជាភាគរយ ឆ្នាំ២០១៣ - ឆ្នាំ២០២០




**ក្រាហ្វ ៥៥ ៖ មូលនិធិកម្ចីក្នុងវិស័យធនាគារ**
ត្រីមាសទី១ ឆ្នាំ២០១៧ - ត្រីមាសទី៤ ឆ្នាំ២០២០




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**វិស័យមីក្រូហិរញ្ញវត្ថុពឹងផ្អែកជាចម្បងលើមូលនិធិកម្ចី ដែលមានសមាមាត្រខ្ពស់ជាងមូលនិធិកម្ចីក្នុងវិស័យធនាគារ ហើយមូលនិធិកម្ចីភាគច្រើនមានរយៈពេលវែងជាងមួយឆ្នាំ។** មូលនិធិកម្ចីនិងដើមទុន ជាប្រភពទុនដ៏ចម្បងក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ដោយមានសមាមាត្រសរុបប្រមាណ ៥៤% នៃមូលនិធិសរុប ក្នុងនោះ ៣៣% ជាមូលនិធិកម្ចី។ ប្រាក់បញ្ញើដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រសកម្មភាពប្រតិបត្តិការរបស់ MDI ដោយបានគ្របដណ្តប់ប្រមាណ ៤៦% នៃមូលនិធិសរុប។ ទោះបីវិស័យមីក្រូហិរញ្ញវត្ថុភាគច្រើនប្រើប្រាស់មូលនិធិកម្ចីរយៈពេលវែង (៨១,៧% នៃមូលនិធិកម្ចីសរុប) សមាមាត្រនៃមូលនិធិកម្ចីប្រភេទនេះបានថយចុះបើធៀបនឹងឆ្នាំមុន (៨៥,១%)។ គិតត្រឹមឆ្នាំ២០២០ មូលនិធិកម្ចីសរុបនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុមានចំនួន ១១,៦ ទ្រីលានរៀល (២,៩ ប៊ីលានដុល្លារអាមេរិក) ថយចុះ -៧,៧% ធៀបនឹងឆ្នាំ២០១៩ ដែលមានចំនួន ១២,៦ ទ្រីលានរៀល (៣,១ ប៊ីលានដុល្លារអាមេរិក)។ មូលនិធិកម្ចីក្នុងស្រុកបានថយចុះ -២៣% មកត្រឹម ៣,៣ ទ្រីលានរៀល (៨១២,៣ លានដុល្លារអាមេរិក) និងរួមចំណែកប្រមាណ ២៨,៣% ក្នុងមូលនិធិកម្ចីសរុប។ ទន្ទឹមនេះ មូលនិធិកម្ចីពីសហភាពអឺរ៉ុប[១៤]បានធ្លាក់ចុះ -៣៣,៣% មកត្រឹម ២,៨ ទ្រីលានរៀល (៦៨៤,៤ លានដុល្លារអាមេរិក) និងរួមចំណែកប្រមាណ ២៣,៨% ក្នុងមូលនិធិកម្ចីសរុប។

**ក្រាហ្វ ៥៦ ៖ ប្រភពមូលនិធិក្នុងវិស័យមីក្រូហិរញ្ញវត្ថុ**
គិតជាភាគរយ ឆ្នាំ២០១៣ - ឆ្នាំ២០២០




**ក្រាហ្វ ៥៧ ៖ មូលនិធិកម្ចីក្នុងវិស័យមីក្រូហិរញ្ញវត្ថុ**
ត្រីមាសទី១ ឆ្នាំ២០១៧ - ត្រីមាសទី៤ ឆ្នាំ២០២០




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

[១៤] ក្នុងចំណោមប្រភពមូលនិធិកម្ចីពីសហភាពអឺរ៉ុប មូលនិធិកម្ចីពីប្រទេសលុចសំបួរមានចំណែកធំជាងគេ ប្រមាណ ៥៣% នៃមូលនិធិកម្ចីពីសហភាពអឺរ៉ុប និងមានចំនួន ១,៥ ទ្រីលានរៀល (៣៦២,៨ លានដុល្លារអាមេរិក)។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៨ ក្នុងចំណោម ៨១ ខ្ចីមូលនិធិភាគច្រើនពីសហភាពអឺរ៉ុប។

**ក្រាហ្វ ៥៨ ៖ ប្រទេសចម្បងទាំង១០ ដែលជាប្រភពហិរញ្ញប្បទានរបស់វិស័យមីក្រូហិរញ្ញវត្ថុ**
គិតជាលានរៀល ឆ្នាំ២០១៨ - ឆ្នាំ២០២០




**ក្រាហ្វ ៥៩ ៖ សមាមាត្រប្រភពមូលនិធិកម្ចី**
ឆ្នាំ២០២០




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ប្រអប់ ៣៖ វិធានការឆ្លើយតបដែលបានដាក់ចេញក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩**

ធនាគារជាតិនៃកម្ពុជាបានអនុវត្តវិធានការមួយចំនួន ដើម្បីកាត់បន្ថយផលប៉ះពាល់មកលើប្រព័ន្ធធនាគារ ដូចខាងក្រោម៖

i/-រក្សាការអនុវត្តប្រកាសស្តីពី ទ្រនាប់ដើមទុនខនស៊ើវេសិន នៅកម្រិត ១,២៥% ចាប់ពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០

ii/-កាត់បន្ថយអត្រាការប្រាក់លើប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា ០,៥% សម្រាប់រាល់តណប្រតិទានទាំងអស់ ចាប់ពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០

iii/-កាត់បន្ថយអត្រាការប្រាក់មូលបត្រអាចជួញដូរបានទាំងជាប្រាក់រៀលនិងជាប្រាក់ដុល្លារអាមេរិកមកកម្រិតសមស្រប

iv/-កាត់បន្ថយអត្រាប្រាក់បម្រុងកាតព្វកិច្ចពី ៨% ជាប្រាក់រៀល និង ១២,៥% ជារូបិយប័ណ្ណបរទេស មក ៧% ទាំងប្រាក់រៀល និងរូបិយប័ណ្ណ រយៈពេល ៦ខែ ចាប់ពីខែមេសា ឆ្នាំ២០២០ តទៅ

v/-ចេញសេចក្តីណែនាំដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អំពីការរៀបចំឥណទានឡើងវិញជូនអតិថិជនដែលជួបប្រទះបញ្ហាហិរញ្ញវត្ថុ (តែឥណទាននៅដំណើរការ) ក្នុងវិស័យចម្បងៗ និងវិស័យដទៃទៀត នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០

vi/-ទទួលស្គាល់ប្រាក់ចំណេញប្រចាំត្រីមាសដែលត្រូវបានធ្វើសវនកម្មរួច ដើម្បីដាក់បញ្ចូលក្នុងការគណនាដើមទុនសរុប ចាប់ពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០ និង

vii/-ផ្អាកការបែងចែកភាគលាភដល់ម្ចាស់ភាគហ៊ុនសម្រាប់ប្រាក់ចំណេញដែលបានធ្វើសវនកម្មរួច ក្នុងឆ្នាំ២០២០។

### ជ- លទ្ធភាពស្វែងរកប្រាក់ចំណេញ

**លទ្ធភាពស្វែងរកប្រាក់ចំណេញក្នុងប្រព័ន្ធធនាគារ រក្សាបានចីរភាព តែមានកម្រិតទាបជាងឆ្នាំមុន ដោយសារការធ្វើសំវិធានធនខ្ពស់ជាងមុន គួបផ្សំនឹងកំណើនយឺតនៃឥណទាន។** អនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម (ROA) និងអនុបាតប្រាក់ចំណេញធៀបនឹងដើមទុន (ROE) សម្រាប់គ្រឹះស្ថានធនាគារ បានថយចុះពី ១,៩% និង ៩,៨% នៅឆ្នាំ២០១៩ មក ១,៧% និង ៨,៧% រៀងគ្នា នៅឆ្នាំ២០២០ ខណៈដែលអនុបាតប្រសិទ្ធភាពនៃការគ្រប់គ្រងចំណាយបានកើនឡើងបន្តិចពី ៤៩,៦% ដល់ ៤៥,៩%។ ចំណាយលើសំវិធានធនរបស់គ្រឹះស្ថានធនាគារបានកើនឡើង ៧៩% ធៀបនឹងឆ្នាំមុន។ ដោយឡែក លទ្ធភាពស្វែងរកប្រាក់ចំណេញរបស់ MDI បន្តមានចីរភាព ឆ្លុះបញ្ចាំងតាមរយៈស្ថិរភាពនៃ ROA នៅកម្រិត ២,៩% ខណៈ ROE ថយចុះពី ១៧,៧% ដល់ ១៤,៨% ដែលជាចម្បងបណ្តាលមកពីការបង្កើនដើមទុន។ ប្រសិទ្ធភាពប្រតិបត្តិការមានភាពល្អប្រសើរ ដោយអនុបាតប្រសិទ្ធភាពនៃការគ្រប់គ្រងចំណាយបានថយចុះពី ៥៥,៨% មក ៥១%។ សម្រាប់ MFI ROA និង ROE បានថយចុះពី ២,២% និង ៦,៣% មក ១,៩% និង ៤,៥% រៀងគ្នា។ ដោយប្រតិបត្តិការរបស់ MFI មានលក្ខណៈប្រពៃណី ប្រសិទ្ធភាពប្រតិបត្តិការរបស់ពួកគេនៅមានកម្រិតនៅឡើយ ឆ្លុះបញ្ចាំងតាមរយៈកម្រិតខ្ពស់នៃអនុបាត ៧០,៤%។ (ក្រាហ្វ ៦០, ៦១ និង ៦២)

ជាមួយនឹងការអូសបន្លាយនៃការរីករាលដាលជំងឺកូវីដ-១៩ ធនាគារជាតិនៃកម្ពុជាបានចេញសេចក្តីជូនដំណឹងដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីផ្អាកការបែងចែកភាគលាភសម្រាប់ឆ្នាំ២០២០ និងត្រូវរក្សាប្រាក់ចំណេញទុកសម្រាប់គ្រាបន្ទាប់ សំដៅរក្សាលទ្ធភាពស្វែងរកប្រាក់ចំណេញរបស់គ្រឹះស្ថាននីមួយៗ ព្រមទាំងការពារពីព្រឹត្តិការណ៍មិនច្បាស់លាស់មួយចំនួនដែលអាចកើតឡើង។

**ក្រាហ្វ ៦០ ៖ អនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម**

គិតជាភាគរយ, ត្រីមាសទី១ ឆ្នាំ២០១៧ - ត្រីមាសទី៤ ឆ្នាំ២០២០




**ក្រាហ្វ ៦១ ៖ អនុបាតប្រាក់ចំណេញធៀបនឹងដើមទុន**

គិតជាភាគរយ, ត្រីមាសទី១ ឆ្នាំ២០១៧ - ត្រីមាសទី៤ ឆ្នាំ២០២០




**ក្រាហ្វ ៦២ ៖ អនុបាតប្រសិទ្ធភាពនៃការគ្រប់គ្រងចំណាយ**

គិតជាភាគរយ, ត្រីមាសទី១ ឆ្នាំ២០១៧ - ត្រីមាសទី៤ ឆ្នាំ២០២០




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**MDI បង្កើនប្រាក់ចំណូលតាមរយៈប្រភពមិនមែនការប្រាក់ ជាមួយនឹងប្រសិទ្ធភាពប្រតិបត្តិការប្រសើរជាងមុន ខណៈដែលសមាមាត្រចំណូលពីការប្រាក់របស់ MFI បានកើនឡើង ជាមួយនឹងចំណាយសំវិធានធនធំជាងមុន។** អនុបាតប្រសិទ្ធភាពនៃការគ្រប់គ្រងចំណាយបានថយចុះជាសន្សឹមៗ ដោយសារការថយចុះនៃចំណាយប្រតិបត្តិការ។ ម៉្យាងទៀត ចំណូលពីសកម្មភាពហិរញ្ញប្បទានបន្តមានកម្រិតខ្ពស់ ប្រមាណ ៩១,៩% នៃប្រាក់ចំណូលសរុប ដែលធ្លាក់ចុះពី ៩៨,៥% នៅឆ្នាំមុន។ ចំណែកឯ MFI វិញ អនុបាតប្រសិទ្ធភាពនៃការគ្រប់គ្រងចំណាយបន្តមានកម្រិតខ្ពស់ជាង ឆ្លុះបញ្ចាំងតាមរយៈសមាមាត្រដ៏ធំនៃចំណាយប្រតិបត្តិការ ដែលអាចបណ្ដាលមកពីម៉ូឌែលធុរកិច្ចខុសគ្នា និងការពឹងផ្អែកលើមូលនិធិកម្ចីនិងដើមទុនជាប្រភពទុនចម្បង ជាជាងការពឹងផ្អែកលើប្រាក់បញ្ញើ។ សមាមាត្រចំណូលពីការប្រាក់បានកើនឡើងពី ៧៩,៨% នៃប្រាក់ចំណូលសរុប ដល់ ៨៣,៩% ស្របពេលដែលសមាមាត្រចំណាយសំវិធានធនកើនឡើងទ្វេដងពី ៨% ដល់ ១៥,៥% នៃចំណាយសរុប។ (ក្រាហ្វ ៦៣ និង ៦៤)

**ក្រាហ្វ ៦៣ ៖ ធាតុនៃប្រាក់ចំណេញរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ**
គិតជាភាគរយ, ឆ្នាំ២០១៣ - ឆ្នាំ២០២០




**ក្រាហ្វ ៦៤ ៖ ធាតុនៃប្រាក់ចំណេញរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ**
គិតជាភាគរយ, ឆ្នាំ២០១៣ - ឆ្នាំ២០២០




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

## ឈ- ស្ថានភាពដើមទុន

**ក្រាហ្វ ៦៥៖ អនុបាតសាធនភាព**



ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ប្រព័ន្ធធនាគារបន្តបង្ហាញភាពធន់លើផ្នែកដើមទុន។** គ្រឹះស្ថានធនាគារ ជារួម រក្សាបានអនុបាតសាធនភាពក្នុងកម្រិតខ្ពស់ និងស្ថិរភាព ប្រមាណ ២៣,៧% ដែលទាបជាងឆ្នាំមុនបន្តិច (២៤%)។ ជាមួយគ្នានេះ MDI និង MFI ក៏បានពង្រឹងដើមទុនផងដែរ ដោយបានកើនឡើងពី ១៦,២% និង ៣៤,៩% ដល់ ១៩,៨% និង ៣៨,៩% រៀងគ្នា ដែលជាទ្រនាប់ដើមទុនបន្ថែមសម្រាប់ទប់ទល់នឹងការខាតបង់ដែលអាចកើតឡើងក្នុងអំឡុងពេលមានភាពមិនច្បាស់លាស់នៃការរីករាលដាលនៃជំងឺកូវីដ-១៩។ ភាពរឹងមាំនៃអនុបាតសាធនភាពអាចមកពីការថយចុះនៃទ្រព្យសកម្មថ្លឹងតាមកម្រិតហានិភ័យ -៤,៨% និង -១៣,៤% សម្រាប់ MDI និង MFI រៀងគ្នា។ (ក្រាហ្វ ៦៥)

ទោះយ៉ាងណា ការប្រៀបធៀបអនុបាតសាធនភាពទៅតាមប្រភេទនៃគ្រឹះស្ថានហិរញ្ញវត្ថុទាំងបី (ធនាគារ MDI និង MFI) មិនគួរត្រូវបានធ្វើឡើងនោះឡើយ ដោយសារភាពខុសគ្នានៃបទប្បញ្ញត្តិនិងម៉ូឌែលធុរកិច្ចរបស់គ្រឹះស្ថាននីមួយៗ។ គួររំលេចថា ទ្រនាប់ដើមទុនខនស៊ើវេសិនត្រូវបានរក្សានៅកម្រិត ១,២៥% (៥០% នៃទ្រនាប់ដើមទុនខនស៊ើវេសិនពេញលេញ) ដែលជាកិច្ចខិតខំប្រឹងប្រែងមួយរបស់ធនាគារជាតិនៃកម្ពុជាក្នុងការកាត់បន្ថយផលប៉ះពាល់នៃជំងឺកូវីដ-១៩មកលើប្រព័ន្ធធនាគារ។

## ២.២ ការអភិវឌ្ឍនៅក្នុងវិស័យមូលបត្រនិងធានារ៉ាប់រង

### ក- ផ្សារភាគហ៊ុន

**នៅឆមាសទី១ ឆ្នាំ២០២០ ផ្សារភាគហ៊ុនកម្ពុជា បានទទួលរងផលប៉ះពាល់យ៉ាងខ្លាំងពីការរីករាលដាលជំងឺកូវីដ-១៩ ដែលបានធ្វើឱ្យប្រតិបត្តិការរបស់គ្រឹះស្ថាននិងក្រុមហ៊ុនចុះបញ្ជីមានការថយចុះ។ យ៉ាងណាមិញ ផ្សារភាគហ៊ុនមានភាពប្រសើរឡើង និងចាប់ផ្តើមមានស្ថិរភាពឡើងវិញបន្ទាប់ពីធនាគារ អេស៊ីលីដា បានចុះបញ្ជី។** នៅចុងឆ្នាំ២០២០ សន្ទស្សន៍ផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) មានចំនួន ៦៤៨ពិន្ទុ ថយចុះ -១៤,៩% ពី ៧៦១.៧ពិន្ទុ កាលពីឆ្នាំមុន។ ការធ្លាក់ចុះនេះបណ្តាលមកពីការធ្លាក់ចុះនៃតម្លៃភាគហ៊ុនរបស់កំពង់ផែស្វយ័តក្រុងព្រះសីហានុនិងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ដែលបានថយចុះ -២៦,៨% និង -៤៤,៣% រៀងគ្នា។ ទោះយ៉ាងណា មូលធននីយកម្មទីផ្សារបានកើនឡើងគួរឱ្យកត់សម្គាល់ដល់ ២៥០,៣% (ឆ្នាំលើឆ្នាំ) ពី ២,៨ទ្រីលានរៀល ដល់ ៩,៨ ទ្រីលានរៀល ជាមួយនឹងវត្តមានរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុន ផេសចិក (ខេមបូឌា) ដែលបានចូលក្នុងផ្សារភាគហ៊ុននៅខែឧសភា និងខែសីហា ឆ្នាំ២០២០ រៀងគ្នា។ ក្រុមហ៊ុនទាំងពីរបានរួមចំណែកជាង ៧៥% នៃមូលធននីយកម្មទីផ្សារសរុប (ក្រាហ្វ ៦៦ និង ៦៧)។

ផ្សារភាគហ៊ុនកម្ពុជាមិនសូវមានភាពសកម្ម ដែលឆ្លុះបញ្ចាំងតាមរយៈការថយចុះគួរឱ្យកត់សម្គាល់នៃការជួញដូរប្រចាំថ្ងៃ។ បរិមាណជួញដូរប្រចាំថ្ងៃជាមធ្យមបានថយចុះ -២៧,៧% ចំណែកឯតម្លៃជួញដូរជាមធ្យមបានថយចុះ -២៤,៦% ពី ៦២៨,២ លានរៀល មកត្រឹម ៤៧៣,៩ លានរៀល (ក្រាហ្វ ៦៨)។

**ក្រាហ្វ ៦៦ ៖ សន្ទស្សន៍ ផ.ម.ក**

(ឆ្នាំ២០២០)



**ក្រាហ្វ ៦៧ ៖ ទំហំមូលធននីយកម្មទីផ្សារ**
ឆ្នាំ២០១៧ - ឆ្នាំ២០២០




**ក្រាហ្វ ៦៨ ៖ ទំហំនិងតម្លៃជួញដូរជាមធ្យម**
ឆ្នាំ២០១៧ - ឆ្នាំ២០២០




ប្រភព ៖ ផ្សារមូលបត្រកម្ពុជា

## ខ- ផ្សារមូលបត្របំណុល

ផ្សារមូលបត្របំណុលបានបន្តអភិវឌ្ឍដោយបានទាក់ទាញក្រុមហ៊ុនបោះផ្សាយមូលបត្របំណុលកាន់តែច្រើន និងបានជួយលើកកម្ពស់រូបិយវត្ថុជាតិ។ ធនាគារ ភ្នំពេញពាណិជ្ជ បានបោះផ្សាយមូលបត្របំណុលសាជីវកម្មជារូបិយវត្ថុជាតិសរុប ៨០០.០០០ឯកតា ដោយបានបោះផ្សាយចំនួនពីរលើកនៅឆ្នាំ២០២០ ក្នុងនោះមូលបត្របំណុលចំនួន ៤០០.០០០ឯកតា ត្រូវបានចុះបញ្ជីនៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០២០ និងមូលបត្របំណុលចំនួន ៤០០.០០០ឯកតាផ្សេងទៀត ត្រូវបានចុះបញ្ជីនៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០២០ ដែលមានតម្លៃសរុប ៨០ប៊ីលានរៀល។ ធនាគារនេះបានផ្តល់ឱ្យវិនិយោគិននូវអត្រាការប្រាក់គូប៉ុង ៦,៥%និងបង់ការប្រាក់ត្រលប់មកវិញរៀងរាល់៦ខែម្តង។ លើសពីនេះ ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ភីអិលស៊ី ត្រូវបានចុះបញ្ជីនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០ និងបានបោះផ្សាយមូលបត្របំណុលសាជីវកម្មជារូបិយវត្ថុជាតិចំនួន ៨០០.០០០ឯកតា ដែលមានតម្លៃ ៨០ ប៊ីលានរៀល។ ក្រុមហ៊ុននេះបានផ្តល់ឱ្យវិនិយោគិននូវអត្រាការប្រាក់គូប៉ុង ៥,៥% និងបង់ការប្រាក់ត្រលប់មកវិញជារៀងរាល់ឆ្នាំ។ ជាចុងក្រោយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ភីអិលស៊ី ត្រូវបានចុះបញ្ជីនៅថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២០ និងបានបោះផ្សាយមូលបត្របំណុលសាជីវកម្មជារូបិយវត្ថុជាតិចំនួន ១.២៧២.០០០ ឯកតា ដែលមានតម្លៃ ១២៧,២ ប៊ីលានរៀល។ គ្រឹះស្ថាននេះបានផ្តល់ឱ្យវិនិយោគិននូវអត្រាការប្រាក់គូប៉ុង ៧,៥% និងបង់ការប្រាក់ត្រលប់មកវិញរៀងរាល់៦ខែម្តង។ នៅចុងឆ្នាំ២០២០ ធនាគារពាណិជ្ជចំនួន ៣ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ២ និងក្រុមហ៊ុននាំចេញ-នាំចូលចំនួន ១ បានចុះបញ្ជីនៅក្នុងផ្សារមូលបត្របំណុលកម្ពុជា។ ទោះបីជាមានការកើនឡើងនូវក្រុមហ៊ុនបោះផ្សាយមូលបត្របំណុលក៏ដោយ ក៏ផ្សារមូលបត្របំណុលនៅតែមិនទាន់មានភាពសកម្មក្នុងការជួញដូរនៅឡើយ ដោយវិនិយោគិនជាច្រើនមានបំណងរក្សាមូលបត្របំណុលរបស់ពួកគេរហូតដល់កាលកំណត់។

**តារាង ១ ៖ ការបោះផ្សាយមូលបត្របំណុលនៅក្នុងឆ្នាំ២០២០**

| ក្រុមហ៊ុនបោះផ្សាយមូលបត្របំណុល | ធនាគារ ភ្នំពេញពាណិជ្ជ | ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ភីអិលស៊ី | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ភីអិលស៊ី | ធនាគារ ភ្នំពេញពាណិជ្ជ |
|---|---|---|---|---|
| កាលបរិច្ឆេទបោះផ្សាយ | ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០ | ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២០ | ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០ | ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ |
| កាលបរិច្ឆេទជួញដូរដំបូង | ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២០ | ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០ | ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០ | ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២០ |
| ប្រភេទមូលបត្របំណុល | មូលបត្របំណុលផ្សារភ្ជាប់នឹងអត្រាប្តូរប្រាក់ | មូលបត្របំណុលមានគូប៉ុង | មូលបត្របំណុលមានគូប៉ុង | មូលបត្របំណុលផ្សារភ្ជាប់នឹងអត្រាប្តូរប្រាក់ |
| តម្លៃមូលបត្របំណុលដែលបានបោះផ្សាយ | ៤០ ប៊ីលានរៀល (១០ លានដុល្លារអាមេរិក) | ៨០ ប៊ីលានរៀល (២០ លានដុល្លារអាមេរិក) | ១២៧,២ ប៊ីលានរៀល (៣១,៨ លានដុល្លារអាមេរិក) | ៤០ ប៊ីលានរៀល (១០ លានដុល្លារអាមេរិក) |
| ប្រភេទរូបិយបណ្ណ | រៀល | រៀល | រៀល | រៀល |
| រយៈពេលឥណប្រតិទាន (ឆ្នាំ) | ៣ឆ្នាំ | ៥ឆ្នាំ | ៣ឆ្នាំ | ៣ឆ្នាំ |
| អត្រាគូប៉ុង (%) | ៦,៥០% | ៥,៥០% | ៧,៥០% | ៦,៥០% |
| ចំនួនបោះផ្សាយមូលបត្របំណុល (ឯកតា) | ៤០០.០០០ | ៨០០.០០០ | ១.២៧២.០០០ | ៤០០.០០០ |
| តម្លៃចារឹកនៃមូលបត្របំណុល | ១០០.០០០ រៀល ក្នុងមួយឯកតា | ១០០.០០០ រៀល ក្នុងមួយឯកតា | ១០០.០០០ រៀល ក្នុងមួយឯកតា | ១០០.០០០ រៀល ក្នុងមួយឯកតា |
| អ្នកធានាទិញមូលបត្រ | ក្រុមហ៊ុន យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី | ក្រុមហ៊ុន អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី | ក្រុមហ៊ុន អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី | ក្រុមហ៊ុន យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី |

ប្រភព៖ ផ្សារមូលបត្រកម្ពុជា

## គ) វិស័យធានារ៉ាប់រង

វិស័យធានារ៉ាប់រងបន្តមានការរីកចម្រើន ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនៃបុព្វលាភដុលសរុបរបស់ធានារ៉ាប់រងទូទៅ និងធានារ៉ាប់រងអាយុជីវិត។ ក្នុងឆ្នាំ២០២០ បុព្វលាភសរុប[១៥] បានកើនឡើង ៧,៨% ដល់ ២៦៤,៩លានដុល្លារអាមេរិក។ បុព្វលាភធានារ៉ាប់រងទូទៅបានកើនឡើង ១០,៥% ដែលត្រូវបានរួមចំណែកជាចម្បងដោយធានារ៉ាប់រងទ្រព្យសម្បត្តិ ឬអគ្គិភ័យ (៦,៤% នៃកំណើនសរុប) សុខភាព (២,២%) និងគ្រោះថ្នាក់ផ្សេងៗ (១,៩%)។ នៅក្នុងចំណោមប្រភេទធានារ៉ាប់រងទាំងនេះ ធានារ៉ាប់រងទ្រព្យសម្បត្តិឬអគ្គិភ័យ និង ធានារ៉ាប់រងសុខភាពមានចំណែកធំជាងគេដល់ ៣៥,៤% និង ១៨,៤% នៃបុព្វលាភធានារ៉ាប់រងទូទៅ រៀងគ្នា។ លើសពីនេះ បុព្វលាភធានារ៉ាប់រងអាយុជីវិតបានកើនឡើង ៥,៨% ដោយសារការកើនឡើងនៃការលក់កិច្ចសន្យាទាយជ្ជទាន (២,៦% នៃកំណើនសរុប) និងជាចំណែកធំជាងគេក្នុងចំណោមធានារ៉ាប់រងអាយុជីវិតទាំងអស់ ដែលស្មើនឹង ៨៤,៣% នៃបុព្វលាភធានារ៉ាប់រងអាយុជីវិត (ក្រាហ្វ ៦៩, ៧១, និង៧២)។

ការផ្តល់សំណងរបស់ក្រុមហ៊ុនធានារ៉ាប់រងទូទៅ និងធានារ៉ាប់រងអាយុជីវិតមានកំណើនយឺតក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩។ ក្នុងឆ្នាំ២០២០ ការផ្តល់សំណងរបស់ក្រុមហ៊ុន

[១៥] ធានារ៉ាប់រងទូទៅ និងធានារ៉ាប់រងអាយុជីវិត

ធានារ៉ាប់រងទូទៅមានប្រមាណ ២៩,២ លានដុល្លារអាមេរិក កើនឡើង ០,២% ធៀបនឹងឆ្នាំមុន (២៩,១លានដុល្លារអាមេរិក) ដោយបានថមថយពីកំណើន ៤៧,១%។ ទោះយ៉ាងណា អនុបាតការផ្តល់សំណងបានថយចុះមកត្រឹម ២៥,៦% នៃបុព្វលាភសរុប ក្នុងឆ្នាំ២០២០ (ពី ២៨,៣% ក្នុងឆ្នាំ២០១៩) ដែលជាចម្បងដោយសារការកើនឡើងលឿននៃបុព្វលាភធានារ៉ាប់រងទូទៅ។ លើសពីនេះ ការផ្តល់សំណងរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតបានកើនឡើង ៤៣,៤% ដល់ ៦,៩ លានដុល្លារអាមេរិក (អនុបាតការផ្តល់សំណងមានចំនួន ៤,៦%) ពី ៤,៨ លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៩ (អនុបាតការផ្តល់សំណងមានចំនួន ៣,៤%) ដែលកំណើននេះមានការថមថយគួរឱ្យកត់សម្គាល់ពីកំណើន ១០៨,៤%(ក្រាហ្វ ៧០)។

**ក្រាហ្វ ៦៩ ៖ បុព្វលាភដុល**

ឆ្នាំ២០១៦ - ឆ្នាំ២០២០




**ក្រាហ្វ ៧០ ៖ សំណងធានារ៉ាប់រងដុល**

ឆ្នាំ២០១៦ - ឆ្នាំ២០២០




**ក្រាហ្វ ៧១ ៖ សមាមាត្រនៃបុព្វលាភធានារ៉ាប់រងទូទៅ**

(ឆ្នាំ២០២០)




**ក្រាហ្វ ៧២ ៖ សមាមាត្រនៃបុព្វលាភធានារ៉ាប់រងអាយុជីវិត**

(ឆ្នាំ២០២០)




ប្រភព៖ សមាគមធានារ៉ាប់រងកម្ពុជា

# ៣. ទំនាក់ទំនងម៉ាក្រូហិរញ្ញវត្ថុ

## ៣.១ គម្លាតឥណទានធៀបនឹង ផ.ស.ស

**អនុបាតឥណទានធៀបនឹងផ.ស.ស កើនជាលំដាប់ ទោះបីជាកំណើនឥណទានថមថយល្បឿនក៏ដោយ។** អនុបាតឥណទានធៀបនឹងផ.ស.ស បានកើនឡើងពី ១២០,៦% ក្នុងឆ្នាំ២០១៩ ដល់ ១៤០% ក្នុងឆ្នាំ២០២០ ដែលជាចម្បងមកពីការធ្លាក់ចុះកម្រិត ផ.ស.ស ដោយសារការធ្លាក់ចុះនៃសេដ្ឋកិច្ចជាជាងការកើនឡើងនៃឥណទាន។ កម្រិតខ្ពស់នៃអនុបាតនេះ បានធ្វើឱ្យគម្លាតឥណទានធៀបនឹង ផ.ស.ស បានកើនដល់ ២៦,១% ក្នុងឆ្នាំ២០២០ ធៀបនឹង ១៩,១% ឆ្នាំមុន។ ប្រសិនបើការរីករាលដាលជំងឺកូវីដ-១៩ អូសបន្លាយរយៈពេលយូរ និងមានផលប៉ះពាល់ខ្លាំងដល់សេដ្ឋកិច្ច ការណ៍នេះទាមទារការតាមដានដោយយកចិត្តទុកដាក់លើផលប៉ះពាល់ និងកម្រិតឥណទាន ដែលអាចបណ្តាលឱ្យមានកំណើនឥណទានខ្ពស់ហួសហេតុធៀបនឹងសកម្មភាពសេដ្ឋកិច្ច។ យ៉ាងណាមិញ ដោយសារប្រទេសកម្ពុជាជាប្រទេសមានកំណើនសេដ្ឋកិច្ចលឿន ស្របពេលដែលទីផ្សារហិរញ្ញវត្ថុស្ថិតក្នុងដំណាក់កាលកំពុងអភិវឌ្ឍន៍នៅឡើយ  កម្ពុជានៅតែត្រូវការឥណទានពីប្រព័ន្ធធនាគារដើម្បីទ្រទ្រង់ដល់សកម្មភាពនានាក្នុងវិស័យសេដ្ឋកិច្ច។

**ក្រាហ្វ ៧៣ ៖ អនុបាតឥណទានធៀបនឹង ផ.ស.ស និងគម្លាតឥណទាន**

(គិតជាភាគរយ, ត្រីមាសទី១ ឆ្នាំ២០១០-ត្រីមាសទី៤ ឆ្នាំ២០១៩)




*សម្គាល់ ៖ ឥណទានសរុប = ធនាគារ + គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ, គម្លាតត្រូវបានគណនាដោយប្រើ one-sided HP filter ជាមួយ lambda ចំនួន ៤០០,០០០*

ប្រភព ៖  ធនាគារជាតិនៃកម្ពុជា

## ៣.២ ការវិភាគតារាងតុល្យការ

**គិតត្រឹមចុងឆ្នាំ២០២០ លទ្ធផលនៃការវិភាគតារាងតុល្យការ (BSA) បង្ហាញថាគ្រឹះស្ថានទទួលប្រាក់បញ្ញើផ្សេងទៀត (ODCs) គ្រឹះស្ថានមិនមែនហិរញ្ញវត្ថុ (NFCs) និងវិស័យខាងក្រៅ បានដើរតួនាទីសំខាន់នៅក្នុងសេដ្ឋកិច្ចកម្ពុជា ឆ្លុះបញ្ចាំងតាមរយៈភាពប្រទាក់ក្រឡាហិរញ្ញវត្ថុខ្លាំងនៃវិស័យទាំងនេះ។** ស្ថានភាពហិរញ្ញវត្ថុសុទ្ធរបស់ ODCs នៅមានភាពរឹងមាំ បើទោះជាបានធ្លាក់ចុះក៏ដោយ។ ODCs មានទ្រព្យសកម្មសុទ្ធ ១,៦ ប៊ីលានដុល្លារអាមេរិក បានធ្លាក់ចុះ -១៨,៩% ពី ២ ប៊ីលានដុល្លារអាមេរិកនៅឆ្នាំ២០១៩ ដែលបណ្តាលមកពីការកើននៃទ្រព្យអកម្មខ្ពស់ជាងកំណើនទ្រព្យសកម្ម។ នៅក្នុងផ្នែកទ្រព្យអកម្ម ODCs បានទទួលលំហូរមូលធនពីគ្រប់វិស័យ ចំនួន ៥២,៥ ប៊ីលានដុល្លារអាមេរិក បានកើនឡើង ១៧,២% (ឆ្នាំលើឆ្នាំ) ដោយសារកំណើនលំហូរចូលមូលធនពី អង្គភាពគ្រួសារ (២០,៦%) វិស័យខាងក្រៅ (១៣,៥%) និង NFCs (៧,២%)។ ដោយឡែក ក្នុងផ្នែកទ្រព្យសកម្ម ODCs បានផ្តល់មូលធនទៅកាន់គ្រប់វិស័យ ចំនួន ៥៤,២ ប៊ីលានដុល្លារអាមេរិក បានកើន ១៥,៦% ពីចំនួន ៤៦,៩ ប៊ីលានដុល្លារអាមេរិកនៅឆ្នាំមុន។ ការកើនឡើងនៃទ្រព្យសកម្មនេះ ជាចម្បងបណ្តាលមកពីការកើនឡើងនៃការផ្តល់ឥណទានទៅកាន់ NFCs (១៨,៦%) និងអង្គភាពគ្រួសារ (១៨,៥%)។

**ក្រាហ្វ ៧៤ ៖ ស្ថានភាពហិរញ្ញវត្ថុរួមតាមវិស័យឆ្នាំ២០២០**
(គិតជាប៊ីលានដុល្លារអាមេរិក)




<u>កំណត់សម្គាល់ ៖</u>
- *ទំហំរង្វង់ តំណាងឱ្យទំហំទឹកប្រាក់សរុបនៃទ្រព្យសកម្មនិងទ្រព្យអកម្មរបស់វិស័យនីមួយៗ*
- *ពណ៌នៃខ្សែដែលចេញពីវិស័យមួយ ទៅវិស័យផ្សេងទៀត តំណាងឱ្យបំណុលត្រូវទារពីវិស័យទាំងនោះ។*

**ភាពប្រទាក់ក្រឡានៃ NFCs និងវិស័យដទៃទៀត បានបង្ហាញថា វិស័យខាងក្រៅ និង ODCs គឺជាប្រភពមូលធនដ៏សំខាន់សម្រាប់ NFCs។** ទ្រព្យអកម្មសុទ្ធនៃ NFCs មានចំនួន ៤៧,៧ ប៊ីលានដុល្លារអាមេរិក បានថយចុះ -២,៥% ដោយសារតែការធ្លាក់ចុះនៃលំហូរមូលធនពីក្រៅប្រទេស។ គិតត្រឹមចុងឆ្នាំនេះ NFCs បានទទួលលំហូរមូលធនពីគ្រប់វិស័យ ចំនួន ៦៣,៤ ប៊ីលានដុល្លារអាមេរិក បានកើនឡើង ១,៩% (ឆ្នាំលើឆ្នាំ) ដោយសារការកើនឡើងនៃលំហូរមូលធនពី ODCs (១៨,៦%) ខណៈដែលលំហូរមូលធនរបស់វិស័យខាងក្រៅ ចូល NFCs បានថយចុះ -៧,៥%។ ដោយឡែក ទ្រព្យសកម្មរបស់ NFCs បានកើនឡើង ១៦,៣% ដល់ ១៥,៧ ប៊ីលានដុល្លារអាមេរិក។ គួរកត់សម្គាល់ថា សមាមាត្រ ៩៩% នៃលំហូរមូលធនចេញពី NFCs គឺទៅកាន់ ODCs និងវិស័យខាងក្រៅ ចំនួន ៨ ប៊ីលានដុល្លារអាមេរិក និង ៧,៧ ប៊ីលានដុល្លារអាមេរិក រៀងគ្នា។

**វិស័យខាងក្រៅបានបង្ហាញពីឥណទេយ្យត្រូវទារសុទ្ធមកកាន់កម្ពុជា ចំនួន ២២ ប៊ីលានដុល្លារអាមេរិក បានថយចុះ -១៩,១% ដែលជាចម្បងបណ្តាលមកពីផលប៉ះពាល់នៃការរីករាលដាលជំងឺកូវីដ-១៩។** គិតត្រឹមចុងឆ្នាំនេះ លំហូរចេញមូលធនពីវិស័យខាងក្រៅ មកកាន់គ្រប់វិស័យនៅក្នុងប្រទេស

កម្ពុជា មានចំនួន ៥៥,៤ ប៊ីលានដុល្លារអាមេរិក បានថយចុះ ១,១% ខណៈដែលលំហូរមូលធនពីគ្រប់វិស័យនៅក្នុងប្រទេសកម្ពុជា ទៅកាន់វិស័យខាងក្រៅ មានចំនួន ៣៣,៤ ប៊ីលានដុល្លារអាមេរិក បានកើនឡើង ១៦,២%។ NFCs ជាវិស័យចម្បងដែលទទួលបានមូលធនពីវិស័យខាងក្រៅ ដោយមានសមាមាត្រ ៦៧% នៃលំហូរមូលធនចេញសរុបពីវិស័យខាងក្រៅ ខណៈលំហូរចេញពី NFCs ទៅកាន់វិស័យខាងក្រៅ មានសមាមាត្រ ២៣%។ ទន្ទឹមនេះ ភាពប្រទាក់ក្រឡាហិរញ្ញវត្ថុរវាងរាជរដ្ឋាភិបាលកម្ពុជា និងវិស័យខាងក្រៅបានបង្ហាញថា រាជរដ្ឋាភិបាល មិនមានបំណុលត្រូវទារពីវិស័យខាងក្រៅនោះទេ គឺមានតែបំណុលត្រូវសង ចំនួន ៨,៨ ប៊ីលានដុល្លារអាមេរិក ដែលភាគច្រើនជាជំនួយ និងប្រាក់កម្ចីសម្បទាន។

**ក្រាហ្វ ៧៥ ៖ ស្ថានភាពហិរញ្ញវត្ថុអន្តរវិស័យ**

(ឆ្នាំ២០១៩ និងឆ្នាំ២០២០)




*<u>កំណត់សម្គាល់:</u>*

- *វិស័យសេដ្ឋកិច្ចដែលរំលេចដោយពណ៌ ក្រហម សំដៅលើឥណទាយិក (Net debtor) ខណៈដែលវិស័យសេដ្ឋកិច្ចដែលរំលេចដោយពណ៌ បៃតង សំដៅលើឥណទាយក (Net Creditor)*
- *ទំហំរង្វង់ តំណាងឱ្យទំហំស្ថានភាពសុទ្ធ (Net Position) របស់វិស័យនីមួយៗ*
- *សញ្ញាព្រួញដែលចេញពីវិស័យមួយ ទៅវិស័យផ្សេងទៀត តំណាងឱ្យបំណុលត្រូវទារពីវិស័យទាំងនោះ*

ប្រភព ៖ ការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

## ៤- ទស្សនវិស័យ និងហានិភ័យ

**ជាមួយនឹងស្ថានភាពជំងឺកូវីដ-១៩ និងការអូសបន្លាយនៃភាពតានតឹងពាណិជ្ជកម្មអន្តរជាតិ កំណើនសេដ្ឋកិច្ចកម្ពុជាបន្តប្រឈមនឹងភាពមិនប្រាកដប្រជា។** ដោយកម្ពុជាជាប្រទេសមានទំហំសេដ្ឋកិច្ចតូចនិងពឹងផ្អែកលើវិស័យខាងក្រៅ កំណើនសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០២១ នឹងអាស្រ័យផងដែរទៅលើការងើបឡើងវិញនៃសេដ្ឋកិច្ចរបស់បណ្ដាប្រទេសផ្សេងទៀត, ការវិវត្តនៃស្ថានភាពជំងឺកូវីដ-១៩ និងភាពតានតឹងផ្នែកពាណិជ្ជកម្មអន្តរជាតិ ជាពិសេសរវាងសហរដ្ឋអាមេរិកនិងប្រទេសចិនដែលជាដៃគូពាណិជ្ជកម្មសំខាន់របស់កម្ពុជា។ យ៉ាងណាមិញ ភាពតានតឹងនេះអាចនឹងជំរុញសហគ្រាសអន្តរជាតិមួយចំនួនឱ្យធ្វើពិពិធកម្មផលិតកម្មរបស់ខ្លួនទៅកាន់បណ្ដាប្រទេសផ្សេងទៀត និងតំបន់អាស៊ានរួមទាំងប្រទេសកម្ពុជា អាចជាទិសដៅសក្ដានុពលមួយសម្រាប់ការវិនិយោគទាំងនោះ។

**បើទោះបីជាសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកកំពុងប្រឈមនឹងហានិភ័យ ដោយសារការរីករាលដាលជាបន្តបន្ទាប់នៃជំងឺកូវីដ-១៩ នៅក្នុងសហគមន៍ យុទ្ធនាការចាក់វ៉ាក់សាំងនឹងជួយកាត់បន្ថយហានិភ័យនេះ។** បន្ទាប់ពីព្រឹត្តិការណ៍សហគមន៍ ៣ វិច្ឆិកា និង ២៨ វិច្ឆិកា ឆ្នាំ២០២០ ប្រទេសកម្ពុជាបានទទួលរងផលប៉ះពាល់ពីការផ្ទុះឡើងវិញនៃជំងឺកូវីដ-១៩ ក្នុង ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ឆ្នាំ២០២១។ ដូចនេះ ជំងឺកូវីដ-១៩ ជាពិសេសវីរុសបំប្លែងខ្លួនថ្មី នៅតែជាហានិភ័យចម្បងដែលអាចបង្អាក់សកម្មភាពសង្គមនិងសេដ្ឋកិច្ចកម្ពុជា។ ដើម្បីកាត់បន្ថយផលប៉ះពាល់នៃជំងឺកូវីដ-១៩ មកលើអាជីវកម្មនិងបុគ្គលិកនិយោជិត រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញវិធានការសារពើពន្ធចំនួន ៨ជុំរួចមកហើយ រួមមាន៖ ការលើកលែងពន្ធ, ការផ្ទេរសាច់ប្រាក់, ការឧបត្ថម្ភសាច់ប្រាក់ប្រាក់ឈ្នួល, គម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូចនិងមធ្យម, គម្រោងធានាឥណទាន។ល។ យ៉ាងណាមិញ ថវិការដ្ឋអាចនឹងទទួលរងសម្ពាធនាពេលខាងមុខប្រសិនបើជំងឺកូវីដ-១៩ នៅតែបន្តអូសបន្លាយ។ ទន្ទឹមនេះ ជាមួយការកើនឡើងនៃបំណុលឯកជនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដូចដែលបានបង្ហាញតាមរយៈអនុបាតឥណទានធៀបនឹងផ.ស.ស ការអូសបន្លាយនៃវិបត្តិជំងឺកូវីដ-១៩ អាចធ្វើឱ្យអង្គភាពគ្រួសារនិងសហគ្រាសមួយចំនួនធ្លាក់ចូលក្នុងស្ថានភាពបំណុលលើសលប់ និងអាចធ្វើឱ្យអនុបាតឥណទានមិនដំណើរការនិងការស្នើសុំរៀបចំឥណទានឡើងវិញកើនឡើង។ យ៉ាងណាមិញ ការចាប់ផ្ដើមចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ នាពេលកន្លងទៅ នឹងជួយកាត់បន្ថយហានិភ័យទាំងនេះ។

**សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថានឹងមានកំណើន ៤% នៅឆ្នាំ២០២១[១៦] ដោយសារការរំពឹងទុកពីការងើបឡើងវិញនៃស្ថានភាពក្រៅប្រទេសនិងការធ្វើពិពិធកម្មការនាំចេញ។** ស្ថានភាពសេដ្ឋកិច្ចនៃប្រទេសដែលជាទិសដៅនាំចេញសំខាន់ៗរបស់កម្ពុជា ដូចជាសហរដ្ឋអាមេរិក សហភាពអឺរ៉ុប និងជប៉ុនត្រូវបានរំពឹងថានឹងមានភាពប្រសើរឡើងវិញជាបណ្ដើរៗ ជាមួយយុទ្ធនាការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ និងការដាក់ចេញគោលនយោបាយគាំទ្របន្ថែមទៀតនៅក្នុងបណ្ដាប្រទេសទាំងនោះ។ ដូចនេះ ការនាំចេញសម្លៀកបំពាក់និងស្បែកជើងរបស់កម្ពុជាដែលបានធ្លាក់ចុះខ្លាំងនៅឆ្នាំ២០២០ ត្រូវបានរំពឹងថានឹងងើបឡើងវិញនៅឆ្នាំ២០២១។ ក្រៅពីនេះ កម្ពុជាក៏ទទួលបានប្រព័ន្ធអនុគ្រោះពន្ធលើការនាំចេញទំនិញគ្រប់ប្រភេទទៅកាន់ចក្រភពអង់គ្លេស ដែលនឹងផាត់ទាត់ការបាត់បង់ផ្នែកខ្លះនៃប្រព័ន្ធ

[១៦] ការព្យាករនេះមិនទាន់បានបញ្ចូលផលប៉ះពាល់នៃព្រឹត្តិការណ៍២០កុម្ភៈនៅឡើយ

អនុគ្រោះពន្ធ "អ្វីៗគ្រប់យ៉ាងលើកលែងតែគ្រឿងសព្វាវុធ (EBA)" ទៅកាន់សហភាពអឺរ៉ុប[១៧]។ ការនាំចេញគ្រឿងបង្គុំអេឡិចត្រូនិក កង់ និងផលិតផលមិនមែនកាត់ដេរផ្សេងទៀត ត្រូវបានរំពឹងថានឹងបន្តរក្សាកំណើន ផងដែរ។

**ការកើនឡើងនៃវិនិយោគផ្ទាល់បរទេស (FDI) ទៅកាន់វិស័យឧស្សាហកម្មក្រៅពីកាត់ដេរសម្លៀកបំពាក់ ក៏បានបង្ហាញពីកិច្ចខិតខំប្រឹងប្រែងនៃការធ្វើពិពិធកម្មសេដ្ឋកិច្ចកន្លងមក ជាមួយការរំពឹងថាកំណើនវិនិយោគក្នុងវិស័យទាំងនោះនឹងបន្តកើនឡើងដោយសន្សឹមៗ។** វិស័យពាក់ព័ន្ធនឹងទំនិញសម្រាប់ការធ្វើដំណើរ, ថាមពល, គ្រឿងបង្គុំអេឡិចត្រូនិក, គ្រឿងបន្លាស់យានយន្ត និងវិស័យផ្សេងៗទៀតជាច្រើន បាននិងកំពុងក្លាយជាវិស័យដែលមានភាពទាក់ទាញសម្រាប់វិនិយោគិនបរទេស។ ជាមួយការគាំទ្របន្ថែម ឧស្សាហកម្មទាំងនេះនឹងជំរុញដល់ការធ្វើពិពិធកម្មនៅក្នុងវិស័យកម្មន្តសាលក្នុងពេលមធ្យម។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជាបានទាញយកអត្ថប្រយោជន៍ពីការរីកចម្រើនផ្នែកបច្ចេកវិទ្យាតាមរយៈការប្រែក្លាយសេវាសាធារណៈមួយចំនួនជាលក្ខណៈឌីជីថល រួមមានសេវាកម្មពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្ម វិនិយោគ និងការចុះបញ្ជីអាជីវកម្មជាដើម ខណៈពេលដែលប្រព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech) ជាពិសេសប្រព័ន្ធទូទាត់ កាន់តែមានការរីកចម្រើនគួរឱ្យកត់សម្គាល់។ វឌ្ឍនភាពទាំងនេះនឹងអាចជួយកាត់បន្ថយថ្លៃដើម និងការពង្រឹងផលិតភាពនិងនវានុវត្តន៍ឱ្យកាន់តែប្រសើរឡើង ដែលសុទ្ធសឹងជាកត្តាសំខាន់ក្នុងការទាក់ទាញវិនិយោគផ្ទាល់បរទេសបន្ថែមទៀត។

**មុនពេលមានព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ វិស័យសំណង់ និងអចលនទ្រព្យត្រូវបានរំពឹងថានឹងងើបឡើងវិញដោយសន្សឹមៗ ទន្ទឹមនឹងការរំពឹងទុកពីការកើនឡើងនៃការវិនិយោគផ្ទាល់បរទេស។ ប៉ុន្តែ បច្ចុប្បន្នការរំពឹងទុកនេះ អាស្រ័យទៅលើប្រសិទ្ធភាពការគ្រប់គ្រងនៃការរីករាលដាលជំងឺកូវីដ-១៩ និងការងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ចក្នុងឆមាសទី២ ឆ្នាំ២០២១។** ប្រទេសចិនដែលជាប្រភពចម្បងនៃលំហូរវិនិយោគផ្ទាល់បរទេសមកកាន់វិស័យសំណង់ និងអចលនទ្រព្យនៅកម្ពុជា និងជាប្រទេសតែមួយគត់នៅក្នុងក្រុមប្រទេស G20 ដែលមានកំណើនសេដ្ឋកិច្ចវិជ្ជមាននៅឆ្នាំ២០២០ ត្រូវបានព្យាករថានឹងមានកំណើនសេដ្ឋកិច្ចខ្ពស់ជាង ៨% ក្នុងឆ្នាំ២០២១។ ជាមួយភាពប្រសើរឡើងនៃទស្សនវិស័យសេដ្ឋកិច្ចពិភពលោកនិងតំបន់ ជំនឿទុកចិត្តក្នុងទីផ្សារនៅឆ្នាំ២០២១ នឹងអាចងើបឡើងវិញ ហើយលំហូរវិនិយោគផ្ទាល់បរទេសទៅកាន់វិស័យសំណង់និងអចលនទ្រព្យនឹងអាចមានភាពប្រសើរឡើងវិញបន្តិចម្តងៗ បើទោះបីជាមិនអាចឈានដល់ស្ថានភាព ដូចកាលពីឆ្នាំ២០១៩ ក៏ដោយ។ ប៉ុន្តែ ព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ បានជះឥទ្ធិពលអវិជ្ជមានដល់ការរំពឹងទុកទាំងនេះ។ ដោយឡែក ដោយសារវិស័យធនាគារមានទំនាក់ទំនងខ្លាំងនឹងវិស័យសំណង់និងអចលនទ្រព្យ ធនាគារជាតិនៃកម្ពុជានឹងបន្តតាមដានយ៉ាងជិតដល់រាល់ការវិវត្តនិងផលប៉ះពាល់នានាក្នុងវិស័យទាំងនេះ។

**បើទោះបីជាស្ថិតក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ក៏ដោយ វិស័យកសិកម្មត្រូវបានរំពឹងថាមានកំណើនប្រសើរជាងឆ្នាំ២០២០ ដោយសារតែនយោបាយគាំទ្ររបស់រាជរដ្ឋាភិបាលកម្ពុជា និងការងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោកដែលអាចជំរុញដល់កំណើនតម្រូវការផលិតផលកសិកម្ម។** នៅឆ្នាំ២០២០ ផលិតកម្មនិងការនាំចេញអង្ករមិនបានទទួលរងផលប៉ះពាល់ពីវិបត្តិជំងឺ

[១៧] ការនាំចេញរបស់កម្ពុជាទៅកាន់ចក្រភពអង់គ្លេសមានទំហំប្រមាណ ២០% នៃការនាំចេញសរុបទៅកាន់សហភាពអឺរ៉ុប

កូវីដ-១៩ នោះទេ ដោយសារតម្រូវការនាំចេញនៅតែមានការកើនឡើង។ ហេតុដូចនេះ ផលិតកម្ម និងការនាំចេញអង្ករ ត្រូវបានរំពឹងថានឹងបន្តកើនឡើងក្នុងឆ្នាំ២០២១ ព្រមទាំងប្រសើរជាងឆ្នាំកន្លងទៅ ជាមួយនឹងការរំពឹងទុកពីភាពអំណោយផលនៃលក្ខខណ្ឌអាកាសធាតុ និងការងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោក។ ទន្ទឹមនេះ ការវិនិយោគក្នុងស្រុកនិងពីបរទេសលើការកែច្នៃផលិតផលកសិកម្មមានការកើនឡើងគួរឱ្យកត់សម្គាល់ ជាមួយការគាំទ្រកាន់តែច្រើនឡើងជាលំដាប់ពីបណ្ដាដៃគូអភិវឌ្ឍន៍និងគោលនយោបាយគាំទ្ររបស់រាជរដ្ឋាភិបាលដើម្បីពង្រឹងការអភិវឌ្ឍវិស័យកសិកម្ម។ ជាលទ្ធផល ផលិតផលដំណាំផ្សេងទៀត បសុសត្វ និងជលផលត្រូវបានព្យាករថានឹងបន្តកើនឡើងក្នុងឆ្នាំ២០២១។ យ៉ាងណាមិញ ការប្រែប្រួលអាកាសធាតុនៅតែជាបញ្ហាប្រឈមដ៏សំខាន់សម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម ដូចជាគ្រោះរាំងស្ងួតនិងទឹកជំនន់កាលពីឆ្នាំមុនដែលបានជះឥទ្ធិពលយ៉ាងខ្លាំងដល់បណ្ដាខេត្តជាច្រើន។

**វិស័យទេសចរណ៍នឹងត្រូវការពេលវេលាយូរជាងវិស័យផ្សេងទៀតដើម្បីស្ដារឡើងវិញ ស្របពេលដែលផែនទីចង្អុលផ្លូវ** (Roadmap) **ដើម្បីស្ដារវិស័យនេះត្រូវបានរៀបចំនិងអនុវត្ត។** វិស័យទេសចរណ៍និងបដិសណ្ឋារកិច្ច នឹងអាចត្រូវការពេលយូរដើម្បីស្ដារឡើងវិញ ពីព្រោះវិស័យនេះពឹងផ្អែកខ្លាំងលើភ្ញៀវទេសចរអន្តរជាតិ ហើយភ្ញៀវទាំងនោះ នៅមានភាពស្ទាក់ស្ទើរក្នុងការធ្វើដំណើរ ដោយសារតែភាពភ័យខ្លាចជំងឺកូវីដ-១៩, ការរឹតត្បិតការធ្វើដំណើរ និងការបាត់បង់ប្រាក់ចំណូលនិងសន្សំ។ ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមនេះ ផែនទីចង្អុលផ្លូវ ស្ដីពី "ផែនការស្ដារនិងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺ កូវីដ-១៩ ឆ្នាំ២០២១-២០២៥" ត្រូវបានរៀបចំនិងតាក់តែងឡើងដោយរាជរដ្ឋាភិបាលកម្ពុជា។ ការអនុវត្តផែនទីចង្អុលផ្លូវនេះ គួបផ្សំនឹងការបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅតាមបណ្ដាខេត្តសំខាន់មួយចំនួនរួមមានខេត្តសៀមរាបនិងព្រះសីហនុជាដើម នឹងជំរុញសកម្មភាពធ្វើដំណើរ និងទេសចរណ៍ឱ្យត្រលប់មករកប្រក្រតីភាពវិញក្នុងរយៈពេលមធ្យម។

**ដើម្បីគាំទ្រដល់ពាណិជ្ជកម្មនិងការវិនិយោគ កម្ពុជាបានពង្រីកកិច្ចសហប្រតិបត្តិការ ដូចជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA) និងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP)។** ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន (CCFTA) និងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ នាពេលថ្មីៗនេះ នឹងជំរុញបន្ថែមទៀតនូវការវិនិយោគនិងពាណិជ្ជកម្មក្នុងតំបន់ ដែលនឹងផ្ដល់អត្ថប្រយោជន៍ដល់ប្រទេសកម្ពុជា ជាពិសេសក្នុងរយៈពេលមធ្យមនិងវែង នៅពេលដែលកម្ពុជាអាចទាញយកអត្ថប្រយោជន៍ពីកាលានុវត្តភាពនេះ ដើម្បីធ្វើទំនើបកម្មនិងពិពិធកម្មរចនាសម្ព័ន្ធសេដ្ឋកិច្ចបន្ថែមទៀត ទៅកាន់វិស័យសំខាន់ៗដទៃទៀត។

**វិស័យធនាគារនិងហិរញ្ញវត្ថុ នឹងបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រដល់ការស្ដារសេដ្ឋកិច្ចឡើងវិញ ដូច្នេះការបន្តរក្សាសុខភាពនិងភាពធន់នៃវិស័យធនាគារនិងហិរញ្ញវត្ថុ នឹងនៅតែជាការងារអាទិភាពសម្រាប់ធនាគារជាតិនៃកម្ពុជា។** ភាពធន់នៃប្រព័ន្ធធនាគារបានដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រដល់សកម្មភាពសេដ្ឋកិច្ច រួមមានការបន្តរក្សាបាននូវកំណើនឥណទាន និងការរៀបចំឥណទានឡើងវិញ ដែលបានរួមចំណែកកាត់បន្ថយសម្ពាធពីវិបត្តិសកលនៃជំងឺកូវីដ-១៩ មកលើសេដ្ឋកិច្ចនិងសង្គមកម្ពុជា។ ធនាគារជាតិនៃកម្ពុជានឹងរក្សាស្ថិរភាពហិរញ្ញវត្ថុប្រកបដោយភាពបុរេសកម្ម តាមរយៈការត្រួតពិនិត្យដោយហ្មត់ចត់លើប្រព័ន្ធធនាគារ ការលើកកម្ពស់ការយល់ដឹងផ្នែកហិរញ្ញវត្ថុរបស់សាធារណជន និងការពង្រឹងកិច្ចការពារអតិថិជននិងគុណភាពនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន។

ធនាគារជាតិនៃកម្ពុជាក៏បានត្រៀមខ្លួនក្នុងការដាក់ចេញវិធានការគាំទ្របន្ថែម ផ្អែកលើស្ថានភាពជាក់ស្តែង និងស្របតាមផែនការស្តារសេដ្ឋកិច្ចឡើងវិញរបស់រាជរដ្ឋាភិបាល។

**ដោយសារបច្ចេកវិទ្យាហិរញ្ញវត្ថុ គឺជាប្រភពកំណើនថ្មីមួយ និងជាមូលដ្ឋានគាំទ្រដល់សេដ្ឋកិច្ចឌីជីថល ប្រព័ន្ធទូទាត់នឹងត្រូវបន្តអភិវឌ្ឍស្របតាមបច្ចេកវិទ្យាថ្មីៗ ដើម្បីលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងសម្រួលដល់ប្រតិបត្តិការពាណិជ្ជកម្មនិងវិនិយោគ។** ការទូទាត់និងការផ្ទេរប្រាក់តាមប្រព័ន្ធឌីជីថលត្រូវបានចាត់ទុកថាជាមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ចឌីជីថល និងជាកត្តាសំខាន់ក្នុងការជំរុញឱ្យប្រជាពលរដ្ឋនៅតាមតំបន់ដាច់ស្រយាលនិងពលករចំណាកស្រុកដែលមានប្រាក់ចំណូលទាប ងាកមកប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការដែលមានភាពងាយស្រួល តម្លៃសមរម្យ និងមានសុវត្ថិភាព។ ក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលបានផ្ទេរសាច់ប្រាក់ដល់កម្មករ និយោជិតនៅក្នុងវិស័យដែលទទួលរងផលប៉ះពាល់ខ្លាំងនិងក្រុមគ្រួសារក្រីក្រ តាមរយៈភ្នាក់ងារផ្ទេរប្រាក់ចល័ត។ ការប្រើប្រាស់ការផ្ទេរប្រាក់តាមប្រព័ន្ធឌីជីថលនេះ បានផ្តល់លទ្ធភាពឱ្យរាជរដ្ឋាភិបាល អាចផ្តល់ជំនួយសង្គមបានទាន់ពេលវេលា និងបានកាត់បន្ថយផលប៉ះពាល់នៃជំងឺកូវីដ-១៩។ ក្នុងយុគសម័យឌីជីថលនិងក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩ ដែលបានជះឥទ្ធិពលដល់ឥរិយាបថបុគ្គលនិងសហគ្រាសឱ្យឈានទៅរកការប្រើប្រាស់ប្រព័ន្ធឌីជីថលកាន់តែច្រើនជាងមុន ធនាគារជាតិនៃកម្ពុជានឹងបន្តគាំទ្រការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលនៅក្នុងវិស័យធនាគារ ដែលនឹងរួមចំណែកដល់ការជំរុញពាណិជ្ជកម្ម និងការវិនិយោគផងដែរ។

# ឧបសម្ព័ន្ធ

## ប្រតិបត្តិការរបស់ក្រុមហ៊ុនចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជា

### ធនាគារ អេស៊ីលីដា ភីអិលស៊ី




### ផេសចិក (ខេមបូឌា)




### ភ្នំពេញអេសអ៊ីហ្សិត ភីអិលស៊ី




### កំពង់ផែស្វយ័តក្រុងព្រះសីហនុ




### កំពង់ផែស្វយ័តភ្នំពេញ




### រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ






| ក្រុមហ៊ុនចុះបញ្ជី | តម្លៃ/ភាគហ៊ុន ២០១៩ | តម្លៃ/ភាគហ៊ុន ២០២០ | កំណើន |
|---|---|---|---|
| កំពង់ផែស្វយ័តក្រុងព្រះសីហនុ | ១៨.៩៨០ | ១៤.២០០ | -២៥,២% |
| រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ | ៦.០០០ | ៦.១០០ | ១,៧% |
| កំពង់ផែស្វយ័តភ្នំពេញ | ១២.៥០០ | ១១.៧០០ | -៦,៤% |
| ភ្នំពេញអេសអ៊ីហ្សិត ភីអិលស៊ី | ២.៥៨០ | ១.១៨០ | -៥៤,៣% |
| ប្រេ្គន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី | ៤.៤០០ | ៣.២០០ | -២៧,៣% |
| **ក្រុមហ៊ុនចុះបញ្ជី** | **តម្លៃជួញដូរដំបូង** | **តម្លៃ/ភាគហ៊ុន ២០២០** | **កំណើន** |
| ធនាគារ អេស៊ីលីដា ភីអិលស៊ី | ១៦.៥០០ | ១៧.១០០ | ៣,៦% |
| ក្រុមហ៊ុន ផេសថិក (ខេមបូឌា) | ៣.៧១០ | ២.៩០០ | -២១,៨% |